ងួ សារី

# ព្រះគុណម៉ែ



បុត្រធីតាទាំងឡាយ ត្រូវតែគោរពបូជា តបស្នងសងគុណ
ចំពោះមាតាបិតារបស់ខ្លួនមិនត្រូវអាក់ខានឡើយ

ព.ស.២៥៤៨ គ.ស.២០០៤

www.elibraryofcambodia.org

# ព្រះគុណម៉ែ

រៀបរៀងដោយ

0000017933

ឈូ សារី

វត្តប្រយុរវង្ស

សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន

រាជធានីភ្នំពេញ

បោះពុម្ពលើកទី១ចំនួន ៥០០ ក្បាល

សម្រាប់ចែកជាធម្មទាន

រក្សាសិទ្ធិ

ហាមទិញ-លក់

ព.ស ២៥៤៨ គ.ស ២០០៤

www.elibraryofcambodia.org



ភិក្ខុ ជុំ សារី

www.elibraryofcambodia.org



## លោកឪពុក ផូ ជាម

លោកគឺជាអ្នកមានគុណ ជាបូជនីយបុគ្គល ដែលខ្ញុំមិនអាចបំភ្លេចចោលបានឡើយ ក្នុងមួយជីវិតនេះ។ ខ្ញុំត្រូវតែគោរព ត្រូវតែតបស្នងសងគុណលោកវិញ នូវរាល់សកម្មភាព ដែលលោកបានធ្វើមកលើរូបខ្ញុំ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រហ្មវិហារធម៌របស់លោក ដែលខំចិញ្ចឹមបីបាច់ថែរក្សារូបខ្ញុំគ្រប់បែបយ៉ាង និងប្រឹងប្រែងនូវអស់កម្លាំងកាយចិត្ត ក្នុងការទំនុកបំរុងផ្គុំផ្គើមឱ្យបានសិក្សារៀនសូត្រ និងរក្សាការពារឥតមានធុញទ្រាន់ និងត្អូញត្អែរឡើយ។

www.elibraryofcambodia.org

# សេចក្ដីថ្លែងអំណរគុណ

ជាបឋមខ្ញុំព្រះករុណា សូមសំដែងនូវកតញ្ញូកតវេទិតាធម៌ ដ៏ជ្រាលជ្រៅចំពោះព្រះតេជគុណព្រះចៅអធិការព្រះនាម **ម៉ាន សៀម** ដែលព្រះអង្គមានសមានចិត្តជួយជ្រោមជ្រែង ឱ្យខ្ញុំព្រះករុណាបានអំពាវនាវញាតិញោមពុទ្ធបរិស័ទ ដើម្បីរកបច្ច័យក្នុងការបោះពុម្ពសៀវភៅ "**ព្រះគុណម៉ែ** " នេះ ។

សូមថ្លែងអំណរគុណ **ភិក្ខុ ហុង បញ្ញាធុឡ** ញោម **ម៉ាំ** លោក **សំ ឆា** និងលោក **លឹម ឈឿម** ដែលបានជួយខ្នះខ្នែង ក្នុងការផ្ទៀងផ្ទាត់ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ ឃ្លា ល្បះ ក្នុងសៀវភៅនេះ ។

សូមថ្លែងអំណរគុណ អស់លោកញាតិញោមពុទ្ធបរិស័ទទាំងឡាយ ដែលមានសទ្ធាជ្រះថ្លា បានចូលរួមចាប់មគ្គផលក្នុងការបោះពុម្ពសៀវភៅនេះ ឱ្យបានសម្រេចជាស្ថាពរ ។

ជាអាវសាន្ត ខ្ញុំសូមលើកនូវមហាកុសលនេះ ឧទ្ទិសជូនដល់ដួងវិញ្ញាណខន្ធ នៃបុព្វការីជនរបស់ញាតិញោមជាពុទ្ធបរិស័ទទាំងឡាយដែលបានធ្វើមរណៈកាលហើយនោះ សូមបានទទួលនូវចំណែកបុណ្យកុសលនេះមួយចំណែក និងមួយចំណែកទៀតចែកជូនដល់ញាតិញោមពុទ្ធបរិស័ទទាំងឡាយ បានជួបប្រទះតែនូវសេចក្ដីសុខ និងសេចក្ដីចម្រើន ជាពិសេស សូមជួបតែនូវពុទ្ធពរទាំងឡាយបួនប្រការ គឺ អាយុ វណ្ណៈ សុខ ពល កុំបីឃ្លៀងឃ្លាត ឡើយ ។

វត្តប្រយូរវង្ស ថ្ងៃព្រហស្បតិ៍ ទី ២០ ខែ តុលា ឆ្នាំ ២០០៤

www.elibraryofcambodia.org

# ឧទ្ទិសកថា

ដោយការខិតខំព្យាយាមចងក្រងសៀវភៅ " **ព្រះគុណម៉ែ** " នេះ ខ្ញុំសូមឧទ្ទិសជូនដល់ដួងវិញ្ញាណក្ខន្ធនៃបុព្វការីជនទាំងឡាយមាន អ្នកម្តាយ **តុប យឿន** លោកតា **គល់ ជិន** លោកយាយ **នៃ លេន** បងស្រី **ផូ សារ៉ាវី** អ្នកមីង **តុប យឿក** លោកតា **អ៊ុក ឡុន** បង **យ៉ា** បង **រុំ** ព្រមទាំងញាតិការទាំងប្រាំពីរសណ្តាន ដែលបានចែកឋាន លះលោកនេះទៅកាន់លោកខាងមុខហើយនោះ ។ សូមចំណែកបុណ្យកុសល ដែលកើតអំពីអានិសង្សនៃការខិតខំធ្វើសៀវភៅនេះ សូមជួយឃីតយោងសណ្តាងវិញ្ញាណក្ខន្ធ នៃបុព្វការីជនទាំងឡាយនោះ ឲ្យបានជួបប្រទះតែសេចក្តីសុខ និងសេចក្តីចំរើនគ្រប់ពេលវេលា ។ម្យ៉ាងទៀតសូមឲ្យដួងវិញ្ញាណក្ខន្ធ នៃបុព្វការីជនទាំងនោះ បានទៅសោយសុខក្នុង សុគតិភពពោលគឺស្ថានសួគ៌ ស្ថានសុខ ស្ថាននិព្វន គ្រប់ៗគ្នាកុំបីឃ្លៀងឃ្លាតឡើយ ។

ផូ សារី

www.elibraryofcambodia.org

# ប្រវត្តិរូបសង្ខេប

លោក **ផូ សារី** ជាបុត្ររបស់លោកតា **ផូ ជាម** និងលោកយាយ **តុប យឿន** ។ លោកកើតនៅថ្ងៃ១៣ រោជ ខែចេត្រ ឆ្នាំខាល ឆស័ក ព.ស ២៥១៧ ត្រូវនិងថ្ងៃ សៅរ៍ទី ២០ ខែ មេសា ឆ្នាំ ១៩៧៤ នៅភូមិ ប្រិយពីរ ឃុំ ស្រែជា ខាងជើង ស្រុក កំពង់ត្រាច ខេត្ត កំពត ។

អាយុ ៨ឆ្នាំ ទៅរៀននៅសាលាវត្តស្រែជា ជាមួយ លោកគ្រូយេន ។ អាយុ ១២ឆ្នាំ អ្នកម្តាយទទួលមរណៈកាល រស់នៅជាមួយឪពុកនិងបងៗ ខំរៀនរហូតដល់បានប្រឡងជាប់ ចូលរៀននៅអនុវិទ្យាល័យស្រុកដងទង់ ឆ្នាំ ១៩៨៨ ។

ឆ្នាំ១៩៩០ បានចូលបួសរៀននៅវត្តស្រែជា ឃុំស្រែជា ខាងជើង ស្រុក ដងទង់ ខេត្ត កំពត ជាមួយលោក គ្រូ **ស ឆាត់** ។ បួសស្របច្បាប់នៅវត្តដងទង់ថ្មី ជាមួយលោកគ្រូ **និត សេស** ក្នុងឆ្នាំដដែល ។

ឆ្នាំ ១៩៩២ បានចូលទៅសិក្សាព្រះបរិយត្តិធម៌នៅវត្ត ត្រើយកោះ ស្រុក កំពង់បាយ ខេត្តកំពត ក្រោមការគ្រប់គ្រង

www.elibraryofcambodia.org

របស់ព្រះតេជគុណ **នៀវ សុភារុណា** និងសិក្សាជាមួយ
លោកគ្រូ **អ៊ុង ត្រលន់** ។

ឆ្នាំ ១៩៩៤ បានប្រឡងជាប់សញ្ញាបត្រ ពុទ្ធិកបឋមសិក្សា (សាលារង) នៅវត្តសំរោងអណ្តែត ។

ឆ្នាំ ១៩៩៥ បានប្រឡងជាប់ចូលរៀននៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងភ្នំពេញ ។

ឆ្នាំ ១៩៩៨ បានប្រឡងជាប់សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ( ឌីប្លូម ) ។

ឆ្នាំ ២០០២ បានប្រឡងជាប់សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ( បាក់ឌុប ) ។

ឆ្នាំ ២០០៣ បានចូលរៀននៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ផ្នែកវិទ្យាសាស្ត្រអប់រំ ។

ជូ សារី

www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅ " **ព្រះគុណម៉ែ** " នេះកើតឡើងដោយកំលាំងសទ្ធាចេតនាសិកដ៏ក្លៀវក្លារបស់ខ្ញុំ ក្នុងការជួយដោះស្រាយបញ្ហាស្មារតីកូនចៅខ្មែរយើងមួយចំនួន ដែលកំពុងតែប្រព្រឹត្តអំពើថ្នាំថ្នក់ខុសគន្លងធម៌ មិនគោរពតាមដំបូន្មាន ឪវាទ ឪពុកម្តាយប្រមាថមើលងាយមើលថោក គំរាមកំហែងឪពុកម្តាយ ថែមទាំងហ៊ានលួចយកទ្រព្យសម្បត្តិឪពុកម្តាយ យកទៅចាយវាយខ្ជះខ្ជាយផ្តេសផ្តាសជាមួយមិត្តពាលាអាវ៉ាសែទៀតផង ។

ម្យ៉ាងទៀតសៀវភៅ " **ព្រះគុណម៉ែ** " នេះ មានគោលសំខាន់ៗ ៤យ៉ាងគឺ :

- ដើម្បីណែនាំ ពន្យល់ដាស់តឿនក្រើនរំលឹកកូនប្រុសស្រីទាំងឡាយឲ្យបានជ្រាបនូវគុណូបការគុណ របស់មាតាបិតា ដែលបានធ្វើមកលើខ្លួនឲ្យកាន់តែច្បាស់ និងបានធ្វើនូវការតបស្នងសងគុណលោកវិញ ដោយចិត្តស្មោះស្ម័គ្រ ។

-ដើម្បីជួយអប់រំ គូស្វាមីភរិយាឲ្យចេះស្រលាញ់គ្នា ចេះយល់ចិត្តគំនិតគ្នា ចេះយល់អធ្យាស្រ័យគ្នា ចេះអត់ឪនឲ្យគ្នា

www.elibraryofcambodia.org

ចេះជួយគ្នាក្នុងគ្រាមានអាសន្ន ចេះគោរពគ្នាទៅតាមតួនាទីរបស់ខ្លួនក្នុងនាមជាស្វាមីភរិយា ។

-ដើម្បីជួយអប់រំមនុស្ស ដែលកំពុងតែរស់នៅក្នុងសង្គម ឲ្យបានយល់ដឹងអំពីសង្គម និងប្រព្រឹត្តត្រូវទៅតាមសង្គមដែលខ្លួនកំពុងតែរស់នៅជាមួយ ។

-ដើម្បីជួយកែលំអរចរិតលក្ខណៈកូនប្រុសស្រី ដែលកំពុងតែប្រព្រឹត្តអំពើថ្គាំថ្គង ឲ្យត្រឡប់ដើរទៅរកផ្លូវត្រូវប្រកបដោយគន្លងធម៌ ចេះស្ដាប់ដំបូន្មានឪពុកម្ដាយ ស្គាល់ចាស់ព្រឹទ្ធាចារ្យ ញាតិមិត្តមីងមា បងប្អូនយាយតាជាដើម ។

មាតាបិតាលោកមានគុណូបការគុណយ៉ាងជ្រាលជ្រៅចំពោះកូនគ្រប់គ្នាជាអនេកប្បការ ដោយរកអ្វីមកប្រៀបផ្ទឹមឲ្យស្មើពុំបានឡើយ ។ គួរកូនប្រុសស្រីគ្រប់គ្នាយកចិត្តទុកដាក់គោរពបូជា តបស្នងសងគុណ ប្រតិបត្តិបម្រើលោកទាំងពីរឲ្យបានល្អប្រសើរ ។ កុំដូចជាកូនមួយចំនួន ដែលមិនជឿគុណឬថាមិនដឹងគុណមាតាបិតារបស់ខ្លួនថាមានប៉ុនណា ហើយ

www.elibraryofcambodia.org

មានការប្រតិបត្តិខុសចំពោះលោក ឬមានការលះបង់ចោលឪពុកម្តាយរបស់ខ្លួន នៅខណៈពេលដែលឪពុកម្តាយលោកពឹងខ្លួនឯងមិនបាន ដូចជាពេលលោកមានអាពាធ ជំងឺឈឺថ្កាត់ជាដើម មកបៀតបៀនដល់សរីរកាយរបស់ផងគាត់ កូនបែបនេះលោកហៅថាកូនអកតញ្ញូ គឺកូនដែលមិនគោរពប្រតិបត្តិឪពុកម្តាយ មានតែការធ្វើឲ្យឪពុកម្តាយគ្រាំគ្រាចិត្ត លំបាកចិត្ត ខ្វាយខ្វល់ចិត្តគ្រប់ពេលវេលា ។

ជាការពិតណាស់ ឪពុកម្តាយជាអ្នកមានគុណយ៉ាងច្រើនចំពោះបុត្រធីតាទាំងឡាយ ដូច្នេះកូនត្រូវតែរកឱកាសដើម្បីតបស្នងសងគុណលោកវិញ ព្រោះលោកជាអ្នកឲ្យកំណើត ជាអ្នកពផ្ទៃ ជាអ្នកចិញ្ចឹមបីបាច់ថែរក្សា ចាប់តាំងពីពេលដែលលោកមានគភ៌រហូតមក ជាអ្នកឲ្យនូវអាហារស្រស់ពោលគឺទឹកដោះដែលហូរចេញពីក្នុងទ្រូងក្តៅៗ ព្រមទាំងជាមិត្តសម្លាញ់របស់កូនគ្រប់គ្នា ទាំងពេលដែលមានសុខ និងពេលដែលមានសេចក្តីទុក្ខ ជាគ្រូអាចារ្យ ជាអ្នកផ្តល់នូវការ

www.elibraryofcambodia.org

កក់ក្តៅដល់កូនគ្រប់គ្នា ។ ម៉ែឪលោកមានការព្រួយបារម្ភចំពោះកូនរបស់ខ្លួន ច្រើនជាងការព្រួយបារម្ភចំពោះខ្លួនលោកទៅទៀត ។ ម៉ែឪលោកសុខចិត្តរងទុក្ខលំបាកគ្រប់បែបយ៉ាងដើម្បីកូន សូម្បីតែជីវិតរបស់ខ្លួនក៏សុខចិត្តលះបង់ដែរ ដោយមិនគិតស្តាយស្រណោះអ្វីទាំងអស់ ដោយលោកប្រថុយនិងគ្រោះថ្នាក់ជាច្រើនប្រការដូចជាពេលឆ្លងទន្លេជាដើម ។

ម៉ែឪរបស់យើង ទោះបីលោកជាមនុស្សប្រភេទណាក៏ដោយ ក៏លោកនៅតែជាម៉ែឪយើងដែរ គាត់ស្រលាញ់យើងមិនថាជាយើងស្ថិតនៅក្នុងសភាពបែបណាឡើយ លោកនៅតែមិនលះបង់បោលកូន ថែមទាំងស្រលាញ់កូនទ្វេឡើងទៀត ដោយគាត់យល់ឃើញថា ជាសាច់ ជាឈាមរបស់គាត់មិនអាចកាត់ផ្តាច់បានឡើយ ដូចជាសុភាសិតបុរាណ លោកពោលថា " កាត់ទឹកមិនដាច់ កាត់សាច់មិនបាន " ។

ដូច្នេះយើងជាកូនគ្រប់គ្នា ត្រូវតែស្រលាញ់គោរពម៉ែឪតបស្នងសងគុណលោកទាំងពីរឲ្យបានល្អប្រសើរ ទៅតាម

www.elibraryofcambodia.org

សមត្ថភាពដែលខ្លួនមាន និងអាចធ្វើបាន មិនត្រូវធ្វេសប្រហែសបណ្តែតបណ្តោយ ឲ្យពេលវេលាកន្លងផុតទៅទើបទឹកស្តាយក្រោយនោះឡើយ ។ ដូចសុភាសិតលោកពោលថា " ធ្វើបុណ្យទាន់ខែភ្លឺ កុំចាំគាត់ឈឺស្លាប់មរណា ទើបនាំបងប្អូនមកវេតារ ដល់គុណរូបាអាត្មាគាត់ ។ ធ្វើបុណ្យដូច្នេះហៅខែងងឹត កាលនៅជីវិតមិនមានមាត់ ដល់ពេលស្លាប់ហើយទើបទឹកគាត់ យកធាតុដាក់វត្តឲ្យស្តាប់ធម៌ ។ កាលម្តាយឪពុកនៅហូបបាន កូនចៅប៉ុន្មានមិនត្រេកអរ យកបាយប្អូនម្ហូបសម្ល មិនមែនត្រេកអរបូជាឡើយ " ។

សៀវភៅ " **ព្រះគុណម៉ែ** " នេះផងដែរ ខ្ញុំសង្ឃឹមថានឹងបានជាប្រយោជន៍ ដល់បុត្រីបុត្រាបុត្រប្រសាបុត្របង្កើតគ្រប់គ្នាដែលបានយកចិត្តទុកដាក់ ក្នុងការទំនុកបំរុងចិញ្ចឹមមាតាបិតារបស់ខ្លួនមិនខាន ។ម្យ៉ាងទៀតសូមឲ្យមាតាបិតាទាំងឡាយបានទទួលតែនូវវត្ថុដែលគួរជាទីប្រាថ្នា ជាទីពេញចិត្ត

www.elibraryofcambodia.org

និងបានជួបតែកូនប្រកបដោយធម៌ ចេះគោរពស្តាប់បង្គាប់ ជំប៊ូន្មានឪពុកម្តាយ គ្រប់ពេលវេលា ។

ម្យ៉ាងទៀតខ្ញុំសូមអភ័ទោសរាល់កំហុសឆ្គងផ្សេងៗ ដែលអាចកើតមានឡើងដោយអចេតនាក្នុងការសរសេរនេះ ក្រែងមានខុសត្រង់ឃ្លាប្រយោគណាទីមួយ ពាក្យពេចន៍ណា ដែលមិនសមរម្យ ពុំគាប់អាធ្យាស្រ័យព្រះទ័យទឹកចិត្តអស់លោកសប្បុរស និងមិត្តអ្នកអាននោះ សូមខន្តីអភ័យទោសនូវរាល់កំហុសឆ្គងនោះផង និងសូមជួយកែសម្រួលដោយសេចក្តីអនុគ្រោះផងចុះ ។ ខ្ញុំរង់ចាំទទួលនូវការស្តាបទាភិះគន់គ្រប់ពេលវេលាអំពីអស់លោកអ្នក ។

សូមអរគុណទុកជាមុន

ផូ សារី

www.elibraryofcambodia.org

# មាតិការឿង


| ល.រ | មាតិការ | ទំព័រ |
|---|---|---|
| ១- | ពាក្យថា ម៉ែ | ១ |
| ២- | តួនាទីមាតាបិតាចំពោះបុត្រធីតា | ២ |
| ៣- | ពេលមុនមានកូនមកចាប់បដិសន្ធិ | ៥ |
| ៤- | ការមានទម្ងន់ ឬការពាផ្ទៃ | ៧ |
| ៥- | ការសម្រាលកូន ឬការឆ្លងទន្លេ | ២២ |
| ៦- | ការចិញ្ចឹមបីបាច់ថែរក្សាកូន | ៣៥ |
| ៧- | ការកិច្ចមាតាបិតាក្នុងការសង្គ្រោះបុត្រធីតា | ៧៥ |
| ៨- | បណ្តាំមាតា | ១១២ |
| ៩- | សង្គហៈធម៌មាតាបិតា | ១២៤ |


www.elibraryofcambodia.org

# ពាក្យថា " ម៉ែ "

ពាក្យថា "ម៉ែ" គឺជាពាក្យដែលមានអត្ថន័យ និងអត្ថសេយ្យាងជ្រាលជ្រៅ ទូលំទូលាយ និងជាពាក្យដែលពីរោះជាទីបំផុតចំពោះបុត្រធីតាទាំងឡាយក្នុងលោក ។ ពាក្យនេះ ជាពាក្យដែលសើមជ្រួតជ្រាបចូលទៅក្នុងក្រអៅបេះដូងកូនយ៉ាងជ្រៅគ្រប់គ្នាទាំងអស់ ។ ព្រោះម៉ែ ជាអ្នកមានឧបការគុណយ៉ាងធំធេងក្រៃលែង រកអ្វីមកប្រៀបផ្ទឹម ថ្លឹងរាស់ឲ្យស្មើរពុំបានឡើយ ។ ដូចបុរាណលោកពោលទុកមកថា " ម៉ែឪមានគុណ គុណមានទំងន់ ធ្ងន់លើសប្រថពី គ្មានអ្វីទឹងសង គុណលោកទាំងពីរ មាសប៉ុនគីរីថ្លៃពុំស្មើរផង " ។ ព្រោះម៉ែ ជាអ្នកផ្តល់កំណើតផង ជាអ្នកផ្តល់នូវសេចក្តីអាណិតស្រលាញ់សន្តោសប្រោសប្រណីផង ជាអ្នកផ្តល់នូវទ្រព្យសម្បត្តិកេរ្តិ៍មរតកផង និងជាអ្នកទំនុកបម្រុងផ្ចុងផ្តើម ឲ្យបានទទួលការសិក្សារៀនសូត្រចំណេះវិជ្ជាផ្សេងៗផង ជាទីប្រឹក្សារបស់កូនផង ជាអ្នកចិញ្ចឹមបីបាច់ថែរក្សាផង ជាអ្នកដែលមានឱកាសបាននៅបទិត្យជិតស្និទ្ធ

www.elibraryofcambodia.org

ទឹងកូនច្រើនជាងអ្នកណាទាំងអស់នៅលើលោកនេះផង ។ ម្យ៉ាងទៀតពាក្យថា "ម៉ែ" នេះ គឺជាពាក្យដែលមានចំណាស់ចាស់គម្រិលណាស់ហើយ តែនៅមានអត្ថន័យបំផុតចំពោះបុត្រធីតាគ្រប់រូប បុត្រធីតាទាំងឡាយ និយាយពាក្យនេះជាប់ជានិច្ច ឥតមានធុញទ្រាន់ឡើយ ។

## គុនាទីចំពោះបុត្រធីតា

មាតាបិតា មិនមែនគ្រាន់តែបេះបង្កើតមនុស្សលោកឲ្យកើតយ៉ាងវិសេស ដែលគ្មានវត្ថុសក្តិសិទ្ធិណា អាចបង្កើតបាននោះប៉ុណ្ណោះទេ ។ លោកប៉ុនប្រសព្វគ្រប់យ៉ាងខាងការចិញ្ចឹមរក្សាថ្នាក់ថ្នម លើកទឹកចិត្ត អប់រំ ទំនុកបំរុងដែលសុទ្ធតែប្រកបដោយព្រហ្មវិហារធម៌ ។ ទោះបីជាមានពួកអ្នកជំនាញខាងការចិញ្ចឹមបីបាច់ថែរក្សាយ៉ាងណា ក៏មិនអាចធ្វើជំនួសបានប្រសើរគ្រប់យ៉ាងដូចមាតាបិតាដែរ ។ បើទុកជាជួលដោយវត្ថុមានតម្លៃយ៉ាងណា ក៏អ្នកស៊ីឈ្នួល

www.elibraryofcambodia.org

ធ្វើឲ្យល្អវិសេស ដូចមាតាបិតាមិនបានទាល់តែសោះ ព្រោះមិនមែនជាមាតាបិតាបង្កើត ។

បុត្រធីតាទាំងឡាយ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះមាតាបិតាគ្រប់រូប ព្រោះលោកយល់ថា កូនជាអ្នកបន្តមត៌កមនុស្សជាតិ និងជាផលិតផលអនុស្សាវរីយ៍តែមួយគត់ ដែលបង្កើតឡើង ដោយការរួមកាយរួមចិត្តរបស់មាតាបិតា ។ សារៈសំខាន់របស់បុត្រធីតា យ៉ាងហោចណាស់ ក៏មាន ៣ ចំណែក យ៉ាងធំ ដែរគឺ ៖

- ជាអ្នកបន្តពូជពង្សមនុស្សជាតិ
- ជាអ្នកបន្តវង្សត្រកូល
- ជាចំណងមេត្រីភាពរវាងមាតាបិតា កុំឲ្យមានការបែកបាក់ព្រាត់ប្រាសពីគ្នា ។

មាតាបិតា ដោយសារសំឡឹងឃើញនូវសារៈសំខាន់ ៣ យ៉ាងនេះហើយ ទើបសុខចិត្តទ្រាំទ្រនូវការលំបាកទាំងពួង ដើម្បីការលូតលាស់របស់បុត្រ ។ ដូច្នេះជាការ ដែលមិនអាចចៀសបានឡើយ ដែលមាតាបិតាគ្រប់រូប ត្រូវ

www.elibraryofcambodia.org

ទទួលខុសត្រូវចំពោះវាសនាអនាគតកូនរបស់ខ្លួន ដែលជាផលិតផលមានជីវិតម្យ៉ាង រួមនូវជីវិតពីរមកបង្កើតជាជីវិតមួយ ។

ការទទួលខុសត្រូវរបស់មាតាបិតា មិនមែនត្រឹមតែកើតមានឡើង នៅពេលដែលកូនប្រសូត្រហើយនោះទេ តាមពិត មានតាំងពីកូនមិនទាន់មកចាប់បដិសន្ធិមកម្ល៉េះ ។ ហេតុអ្វីបានជាដូច្នេះ ព្រោះថា បើយើងពិនិត្យពិច័យនៃការមានជីវិតរបស់កូន យើងអាចបែងចែកការមានជីវិតរបស់កូន និងការទទួលខុសត្រូវរបស់មាតាបិតាជាបី ចំណែកគឺ ៖

- ចំណែកទីមួយ មុនពេលចាប់បដិសន្ធិ
- ចំណែកទីពីរ ពេលកូនមកទំនៅក្នុងផ្ទៃ រហូតដល់ថ្ងៃប្រសូត្រ ។
- ចំណែកទីបី ការលូតលាស់របស់កូន រហូតដល់ថ្ងៃយើងលាចាកលោកលែងឃើញមុខកូន ។

www.elibraryofcambodia.org

# ពេលមុនមានកូនមកចាប់បដិសន្ធិ

ចាប់តាំងពីពេលដែលគូស្វាមីភរិយា បានរៀបអាពាហ៍ពិពាហ៍រួចមក និងបានរួមរស់នៅជាមួយគ្នាក្នុងឋានៈជាស្វាមីភរិយាពេញច្បាប់ហើយ មិនយូរប៉ុន្មាន អ្នកទាំងពីរក៏ចាប់ផ្ដើមមានបុត្រមកជ្រកនៅជាមួយ ៗ ដូច្នេះ គួរគិតគូរឲ្យមែនទែនផងដែរ ចំពោះការសម្រេចចិត្ត ដែលមានតែម្ដងរបស់អ្នក ដែលមិនត្រឹមតែប៉ះពាល់ដល់ជីវិតរបស់អ្នកទេ តែចំពោះកូនអ្នកផង ព្រោះការរៀបអាពាហ៍ពិពាហ៍ពីក្មេងពេក បើតាមក្បួនវេជ្ជសាស្ត្រគេនិយាយថា នឹងនាំឲ្យកូនមានសុខភាពមិនមាំទាំ ព្រោះមេជីវិតរបស់បុរសស្ត្រីមិនទាន់មានកំលាំងមាំមួន ៗ ក្បួនវេជ្ជសាស្ត្របាននិយាយទៀតថា បុរសស្ត្រី គួររៀបអាពាហ៍ពិពាហ៍ពេលបុរសបានអាយុ ២៥ឆ្នាំ នឹងស្ត្រី២៣ឆ្នាំ ៗ ម្យ៉ាងទៀត អាយុប៉ុណ្ណោះក៏ជារយៈពេលដែលបានទទួលការសិក្សាល្មម នឹងចិញ្ចឹមជីវិតរបស់ខ្លួនបាន នឹងស្គាល់សុខទុក្ខរបស់ជីវិតគួរសម

www.elibraryofcambodia.org

ហើយ ។ ការរៀបអាពាហ៍ពិពាហ៍ ពីអាយុ១៦ ឬ១៨ឆ្នាំ ពេលនេះ ជាពេលដែលកំពុងតែជាប់ការសិក្សារៀនសូត្រ នៅឡើយ បើរៀបអាពាហ៍ពិពាហ៍ហើយ នឹងមិនអាចរៀនសូត្រតទៅទៀតបានឡើយ ។ បើតាមច្បាប់ប្រទេសខ្លះ គេកំណត់យកអាយុ ១៨ឆ្នាំ និងប្រទេសខ្លះទៀត គេកំណត់យកអាយុ ២០ឆ្នាំ ទើបអាចពេញលក្ខណៈជាមនុស្ស ដែលច្បាប់ទទួលស្គាល់ ។

ម្យ៉ាងទៀត គូស្រករដែលមានមាឌតូចៗ លុះបានកូនមកកូននោះ ក៏នឹងមិនមានមាឌធំជាងឪពុកម្ដាយដែរ ។ ចំណែកឯការយកសាច់ញាតិជិតៗពេក មកធ្វើជាគ្រួសារ ពេលមានកូនមកមិនសូវមានសតិបញ្ញាខ្លាំងពូកែទេ ព្រោះហ្សែនរបស់យើងមិនមានការអភិវឌ្ឍន៍ ។ បើសិនជាមាតាបិតាជាអ្នកមានជំងឺប្រចាំកាយផងនោះ ជំងឺនោះអាចឆ្លងដល់កូន នឹងអាចធ្វើឲ្យកូនមានពិការភាព ឬមានសតិបញ្ញាទន់ខ្សោយទៀតផង ។

www.elibraryofcambodia.org

# ការមានទម្ងន់ ឬការពផ្ទៃ

តាមទំនៀមខ្មែរយើងពីបុរាណកាលមក លោកហៅស្ត្រីមានគភ៌ថា “មានផ្ទៃ” ឬ “មានទំងន់” តាមដែលគភ៌ជាភារៈមួយដ៏ធ្ងន់ពិបាកថែរក្សា ។

បើតាមការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ ទៅលើធម្មជាតិ តាមបែបជីវសាស្ត្រនោះ គេបានសិក្សាយ៉ាងមមាញឹកបំផុត ពិសេសទៅលើរូបសាស្ត្រ ដែលគេនាំគ្នាតាមដានដោយសម្ភារៈបច្ចេកទេសយ៉ាងទំនើបៗ ហើយបានលទ្ធផលគួរឲ្យគាប់ចិត្តមែនទូវចំណែកខ្លះៗ ទាំងនោះ ។

ដូចជាការវិភាគទៅលើប្រដាប់បន្តពូជ របស់មនុស្សយើង មានតួនាទី២យ៉ាងគឺ ផលិតហ្គាម៉ែត ស្ពែម៉ាតូសូអ៊ីត ឬអូវុល និងផលិតអរម៉ូនភេទ ដែលជាហេតុធ្វើឲ្យមនុស្សប្រុស និងស្រីមានលក្ខណៈខុសគ្នា ក្នុងការរួមគ្នាបង្កើតធម្មជាតិជីវិតឲ្យបានបរិបូណ៌ ។

សភាពនៃមនុស្សប្រុស មុខងារសេរីរាង្គរបស់

www.elibraryofcambodia.org

មនុស្សប្រុសបង្កើតកោសិកានៃមេជីវិត ដែលមានឈ្មោះថា ស្ពែម៉ាតូសូអ៊ីត ហើយនៅពេលណាគេរួមភេទជាមួយនិងមនុស្សស្រី ស្ពែម៉ាតូសូអ៊ីត ឬតួអសុចិនេះ ហូរចូលទៅក្នុងសំបុកកូនរបស់ស្ត្រី ធ្វើឱ្យការប្រសព្វគ្នារវាងអសុចិ នៃភេទទាំងពីរ តាមការសម្ព័ន្ធជាតុរបស់ធម្មជាតិ នៃជីវិតក្នុងគ្រាបដិសន្ធិដំបូង ។

សភាពមនុស្សស្រី ការប្រជុំគ្នានៃភាវៈជាស្រី គឺសរីរាង្គរបស់ភេទស្រី មានមុខងារផលិតអូវ៉ុល ព្រមទាំងការពារ ធ្វើការបង្ករឲ្យដល់កំណើត និងសភាពចំរើនឡើងនៃគភ៌ជាលំដាប់ ។ ទឹកពងរបស់ស្រី ដែលហៅថាអូវ៉ុល (ពង) វាជាធម្មជាតិដែលកើតមានស្រាប់ តាំងពីស្ត្រីមានអាយុគ្រប់ការ (មានរដូវ) គឺជាដំណាក់កាលមួយ ដែលហៅថាពងទុំ មានការលូតលាស់ទីងផុកក្នុងអូវ៉ែរី គឺសំបុកពងរបស់ស្ត្រី ។ សភាពនៃចលនារបស់សំបុកពង របស់ស្ត្រី មានមុខងារបញ្ចេញពងរបស់ខ្លួនមកខាងក្រៅ រហូតដល់រយៈពេលដែលស្ត្រីមានអាយុគ្រប់រដូវ ។ តាមការ

www.elibraryofcambodia.org

វិភាគរបស់អ្នកវិទ្យាសាស្ត្រផ្នែករូបវិទ្យា គេសង្កេតឃើញ ពងដែលផុកនៅក្នុងសំបុកពងរបស់ស្ត្រី មានទំហំធំជាង អសុចិរបស់បុរសជាច្រើនដង ។

សភាពនៃការបង្កកំណើត ការសេពសន្ថវៈ រវាងភេទឈ្មោល និងភេទញី វាជាសភាពធម្មតារបស់ សត្វ ហើយវាក៏ជាប្រតិបត្តិការណ៍មួយ ដែលធ្វើឲ្យសត្វចុះ ចាប់កំណើតបាន នៅពេលមានការសម្ព័ន្ធគ្នារវាងធាតុទាំង ពីរ ។

តាមការសិក្សាស្រាវជ្រាវ របស់អ្នកជីវសាស្ត្រ បាន ឲ្យដឹងថា ពងដែលមាននៅក្នុងសំបុកពងរបស់ស្ត្រី វាជា ធម្មជាតិដែលកើតពីរន្ធស្បោងតូចៗ ក្នុងសំបុកពង ហើយ កូនស្បោងតូចៗទាំងនោះ វាកើតមានពកចេញពីសំបុក ពង ។ ជាធម្មតា សភាពរបស់កូនស្បោងតូចៗទាំងនោះ វា តែងតែបែក ដែលជាហេតុធ្វើឲ្យឃ្លាតចេញពីសំបុក ។ ការ បំបែកពីគ្នាបែបនេះ ហៅថា (ដំណើរនៃពង) ។ ពងដែល បំបែកចេញពីសំបុកហើយ វាទាំងនោះត្រូវបានស្រូបចូល

www.elibraryofcambodia.org

ទៅតាមបំពង់មួយ ឈ្មោះថាបំពង់ដៃស្បូន ។ ទៅពេលរួមភេទ ទឹកអសុចិរបស់បុរស ដែលឈ្មោះថា ស្ពែម៉ាតូសូអ៊ីត ដែលបានបញ្ចេញទៅ ក៏ហូរចូលទៅតាមបំពង់ដៃស្បូន ធ្វើការបោមភោមនូវពងនីមួយៗ (ពងរបស់ស្ត្រី) យ៉ាងច្រើន ហើយដោយទ្រង់ទ្រាយសណ្ឋានរបស់អសុចិ តូចជាងពង ដែលមាននៅក្នុងបំពង់ដៃស្បូន វាក៏អាចចូលទៅក្នុងពងនោះបានជាច្រើន កផ្ចិតនៃអាតូមដែលហៅថា ណៃយូ ឬក៏ស្នូលនៃអសុចិ និងពងទាំងនោះ រំលាយបញ្ចូលគ្នាដោយស្វ័យប្រវត្តិ ។ ដូច្នេះ នេះជាដំណាក់កាលមួយ ដែលធ្វើការបង្កកំណើត ដោយសមាសធម៌នៃធាតុទាំងពីរ ។ ការសម្ព័ន្ធគ្នារវាងធាតុទាំងពីរ ក៏មានឈ្មោះមួយហៅថាពងបង្ករកំណើត ការវិវឌ្ឍន៍របស់ពងបង្កកំណើតនេះ ក៏ចេះតែចំរើនឡើងៗ មានការប្រមូលផ្តុំគ្នានូវកោសិកាតូចៗ ប្រហែលជាង១០០ពង នៅពេលនោះ គេឲ្យឈ្មោះថា ពន្លកកំណើត ពន្លកកំណើតទាំងនេះ ត្រូវបានហូរចុះទៅកាន់ស្បូន ឬសំបុកកូននៃស្បូន ។ ការវិវឌ្ឍន៍របស់ធម្មជាតិ មានសភាពពុំប្រក្រតីឡើយ នៅពេលពន្លកកំណើត វាហាក់ផ្ទេរមជទៅក្នុងស្បូន

www.elibraryofcambodia.org

ការៈរបស់វា គឺធ្វើការបន្តរជាសំបុកក្នុងស្រទាប់ក្រាស់ នៃភ្នាសស្រោមរបស់ស្បូន ហើយបឺតជញ្ជក់រសជាតិអាហារ និងស្រូបយកខ្យល់អុកស៊ីហ្សែនពីសរសៃឈាមតូចៗ ដែលមានទៅក្នុងភ្នាសស្រោម ស្បូនរបស់មាតា ក៏បានដល់នូវកាពវិវឌ្ឍនាការណ៍ ចំរើនលូតលាស់តាមច្បាប់ធម្មជាតិ ក្លាយទៅជាទារកយ៉ាងពិតប្រាកដ ។

សភាពលូតលាស់ ក្រោយពេលចាប់កំណើត: ការចាប់កំណើតរបស់សត្វ ដែលអាស្រ័យដោយគក៏នោះ ក៏ព្រោះសភាពធម្មជាតិនៃគក៏មានការរក្សានូវកំណើតតាមធម្មជាតិ ដោយការស្រូបយកសារជាតិផ្សេងៗ និងអុកស៊ីហ្សែនមកចិញ្ចឹមពងកំណើតឲ្យរីកលូតលាស់ ព្រមទាំងបញ្ចេញចោលនូវកាកសំណល់ តាមរយៈសរសៃឈាមនៃគក៏នោះ ។ ការថែរក្សាបំប៉នពងកំណើតបានអាស្រ័យដោយសុក គឺឈាមដែលមាននៅក្នុងសុកនៃម្ដាយ ព្រមទៅដោយអុកស៊ីហ្សែន បានផ្ដល់ទៅឲ្យគក៏

www.elibraryofcambodia.org

តាមរយៈសុកមិនដាច់រយៈឡើយ ។ រួចហើយឈាមរបស់គភ៌ដឹកនាំឧស្ម័នកាបូនិច និងរាល់កាកសំណល់ផ្សេងៗ ទៀតទៅកាន់សុកតាមរយៈសរសៃឈាម ដែលមាននៅក្នុងទងសុក ។ នៅពេលដែលឱជាទាំងឡាយ និងអុកស៊ីហ្សែន (ខ្យល់) ហូរចូលទៅក្នុងឈាមគភ៌ គឺប្រព្រឹត្តទៅតាមរយៈផ្ទៃស្តើងរបស់សរសៃឈាមក្រមៅ ហើយនៅពេលនោះកាកសំណល់ក៏ចេញពីឈាមគភ៌ត្រឡប់ទៅវិញផងដែរ ។

បើតាមទ្រឹស្តីព្រះពុទ្ធសាសនាវិញ លោកនិយាយថាសត្វទាំងឡាយទាំងពួង ដែលនឹងឈានចូលមកចាប់បដិសន្ធិក្នុងផ្ទៃនៃមាតានោះ លុះតែមានកិច្ចជាទីប្រជុំប្រកបដោយអង្គបីប្រការមកជួបប្រជុំព្រមផង ទើបអាចកើតបាន បើខ្វះអង្គណាមួយហើយ ក៏មិនអាចកើតបានដែរ ឯអង្គបីប្រការនោះគឺ :

១- មាតាបិតាបានធ្វើសេវនកិច្ចជាមួយគ្នា ដោយសេចក្តីតម្រេកត្រេកត្រអាលតែម្យ៉ាងផង ។

២- ចំណែកខាងមាតា ក៏មានឧតុសម័យដ៏ស្រួល

www.elibraryofcambodia.org

បួល គឺមានទឹកទ្លេងសម្រាប់សត្វ ដែលកើតក្នុងផ្ទៃនោះក៏ជាទីស្អាតបរិសុទ្ធល្អ ល្មមសត្វនឹងចូលទៅកើតបានផង ព្រោះឈាមសម្រាប់រដូវនោះ ក៏បែកហូរហៀរចេញអស់ហើយផង ។

៣- សត្វដែលបម្រុងនឹងកើតក្នុងទីនោះ ក៏មានប្រាកដផង ។

ម្យ៉ាងវិញទៀត បើមាតាបិតាបានរួមធ្វើសេវនកិច្ចជាមួយគ្នាហើយ តែចំណែកខាងមាតាមិនមានឧតុសម័យស្រួលបួល ទាំងសត្វដែលបម្រុងនឹងចូលមកកើតនោះទៀតក៏មិនមានផង យ៉ាងនេះសត្វក៏មិនអាចកើតបាន ។ បើមាតាបិតាបានរួមធ្វើសេវនកិច្ចជាមួយគ្នា ទាំងមាតាក៏មានឧតុ-សម័យដ៏ស្រួល តែចំណែកខាងសត្វដែលបម្រុងនឹងកើតពុំមាន សត្វក៏មិនអាចនឹងកើតបានដែរ ។ លុះតែមាតាបិតាបានធ្វើសន្និបាតកិច្ចជាមួយគ្នា១ ចំណែកខាងមាតាក៏មានឧតុសម័យដ៏ស្រួលបួល១ សត្វដែលបម្រុងនឹងកើតក៏មានមកប្រាកដ១ បានប្រកបដោយអង្គបីប្រការនេះហើយ ទើបសម្រេចកំណើតសត្វបាន បើខ្វះអង្គណាមួយហើយ មិន

www.elibraryofcambodia.org

អាចនឹងកើតឡើងបានឡើយ ។

ចាប់តាំងពីពេលដែលម៉ែដឹងថា មានសត្វគឺកូនមកចាប់បដិសន្ធិក្នុងផ្ទៃកាលណាមក ម៉ែតែងតែថែរក្សាគភ៌ជានិច្ច ទោះបីជាមានអាការប្លែកៗ នៅក្នុងខ្លួនយ៉ាងណាក៏ដោយ ក៏មិនរាថយនឹងការទំនុកបំរុងកូន ដែលនៅក្នុងគភ៌នោះដែរ ។ ឯអាការៈដែលស្ត្រីមានគភ៌មិនដូចគ្នាទេ អាស្រ័យទៅលើសុខភាព និងចំណីអាហារ ស្ត្រីខ្លះមានអាការៈអស់កំលាំងល្ហិតល្ហៃ វិលមុខ ក្អួតចង្អោរ មិនស្រឡះក្នុងប្រាណដូចធម្មតាទេ ។ ខ្លះទៀតមានអាការៈចង់បរិភោគរបស់ដែលប្លែក និងពិបាករក ដូចជាទឹកចង់បរិភោគឈាមស្រស់ សំបកឈើ ដី ធ្យូងជាដើម ។ល។ អាការៈប្លែកៗទាំងអស់នេះ បុរាណាចារ្យលោកហៅថា " អាការៈចាញ់កូន " ។

តមកទៀត ម៉ែមិនដែលធ្វេសប្រហែសម្តងណាឡើយ ម៉ែតែងតែប្រុងប្រយ័ត្នគ្រប់ឥរិយាបថទាំងបួន ដេក ដើរ ឈរ អង្គុយ ក្នុងការថែរក្សាកូនដែលនៅក្នុងគភ៌ ។

ពេលដេកៈ ម៉ែមិនហ៊ានប្រះខ្លួនដេកខ្ទាំងដូចកាល

www.elibraryofcambodia.org

នៅទំនេរឡើយ ។ ម៉ែដេកចាប់ភ្ញាក់ ចាប់ក្រោក ដេកមិន ស្កប់បានពេញភ្នែក មិនហ៊ានទំនេរខ្លួនទៅតាមការងងុយ ងោកងក់ទេ ព្រោះម៉ែបារម្ភខ្លាចមានទម្លាប់មិនល្អដល់អត្ត- ចរិតរបស់កូន ។ ពេលថ្ងៃ ទោះបីជាម៉ែងងុយយ៉ាងណា ក៏ម៉ែមិនហ៊ានដេកឲ្យលង់លក់ដែរ ព្រោះក្រែងមិនស្រួល ដល់ពេលចូលទន្លេ ។

ម្យ៉ាងទៀត ម៉ែមិនហ៊ានដេកផ្កាប់មុខ ឬដេកសង្កត់ គល់លើអ្វីៗ ដែលជាវត្ថុរឹងទេ ក្រែងមិនបានសុខស្រួល ដល់កូនក្នុងផ្ទៃ ម្យ៉ាងក្រែងមានអន្តរាយដល់ជីវិតកូន ។ ម៉ែ មិនដែលបានដេកពេញភ្នែក ឬស្កប់ស្កល់ស្រួល ដូចកាល ពីនៅក្រមុំ ឬមិនទាន់មានគភ៌នោះឡើយ ។

ពេលដើរ ម៉ែមិនហ៊ានបោះជំហានវែងៗ តាម ទម្លាប់រាំសរវៃរបស់ម៉ែដែរ ហើយម៉ែក៏មិនហ៊ានដើរខ្លាំង ដើរលឿនឲ្យពេញទំហាប់ជើង ដូចដែលម៉ែធ្លាប់ធ្វើពីមុន មកទេ ម៉ែត្រូវដើរយ៉ាងប្រុងប្រយ័ត្នជានិច្ច ទោះបីជាមាន ហេតុភេទគួរឲ្យភ័យខ្លាច តក់ស្លុតរន្ធត់យ៉ាងណាក៏ដោយ

www.elibraryofcambodia.org

ក៏ម៉ែមិនហ៊ានស្ទុះរត់វីង ទៅតាមកំលាំងនៃការភ័យខ្លាច នោះដែរ ស៊ូទ្រាំដើរដោយប្រុងប្រយ័ត្នគ្រប់ពេលវេលា ។ ម៉ែឈប់ហ៊ានដើរឡើងទីខ្ពស់ ឬឡើងបេះផ្លែឈើទោះទាបខ្ពស់ ព្រោះខ្លាចក្រែងភ្លាត់រអិលជើងដួល បណ្ដាលឲ្យមានការកើតភ័យដល់កូនក្នុងផ្ទៃ ឬខ្លាចក្រែងមានអន្តរាយ ដល់ជីវិតកូន ដែលកំពុងតែដេកនៅក្នុងផ្ទៃ ។ ម៉ែមិនហ៊ានឡើងដើមឈើ មិនហ៊ានឡើងឬចុះប្រាំងចោទ មិនហ៊ានហក់កន្ទង់ផ្ទះទោះបីធំតូច ដូចកាលពីម៉ែនៅមិនទាន់មាន កូនមកជ្រកក្នុងផ្ទៃទេ ម៉ែដើរដោយប្រុងប្រយ័ត្នជានិច្ច ។

ពេលឈរ ម៉ែមិនដែលហ៊ានឈរដូចកាលពីនៅមិនទាន់មានគភ៌ ឬនៅក្រមុំនោះឡើយ ម៉ែតែងឈរដោយប្រុងប្រយ័ត្នជានិច្ច មិនហ៊ានឈរប្រេងើងប្រង៉ាង ឈរបង់ជំទាញ ឬឈរយូរជ្រុលពេកទេ និងមិនហ៊ានឈោងស្រវាចាប់វត្ថុអ្វីដែលខ្ពស់ផុតជំហរ ថែមទាំងមិនហ៊ានលើកដាក់វត្ថុអ្វីដែលមានទម្ងន់ធ្ងន់ពេកដែរ ។ ក្រែងលោមានហេតុនាំបណ្ដាលឲ្យមានអន្តរាយដល់ជីវិតកូន ព្រមទាំងមិនមាន

www.elibraryofcambodia.org

សេចក្តីសុខស្រួលដល់កូន ដែលកំពុងតែដេកនៅក្នុងផ្ទៃ ។

ពេលអង្គុយ ម៉ែមិនហ៊ានទម្លាក់អង្គុយខ្លាំង មិនហ៊ានអង្គុយច្រហោង មិនហ៊ានអង្គុយបោះជើងកន្ទាំង ឬអង្គុយទ្រេតផ្អែកទៅលើវត្ថុអ្វីដែលរឹងទេ ក្រែងមិនបានសេចក្តីសុខស្រួលដល់កូនក្នុងផ្ទៃ ឬក្រែងមានហេតុអ្វីមួយបណ្តាលឲ្យអន្តរាយដល់ជីវិតកូន ។

ម្យ៉ាងទៀត ម៉ែតែងតែកាន់តាមទំនៀមចាស់ៗ ដែលគាត់តែងប្រាប់ម៉ែថា ពេលមានផ្ទៃ មិនត្រូវអង្គុយមាត់ជណ្តើរ មាត់ទ្វារ ដែលនាំឲ្យពិបាកឆ្លងទន្លេ ។

ម៉ែមិនគ្រាន់តែថែរក្សា ថ្នាក់ថ្នមកូនដោយឥរិយាបថទាំង៤ ប៉ុណ្ណោះទេ ។ ម៉ែថែមទាំងមិនហ៊ានបរិភោគចំណីអាហារ ដែលមានរសជាតិហឹរពេក ជូរពេក ប្រៃពេក ចត់ពេក ល្វីងពេក ក្តៅពេក ត្រជាក់ពេក ព្រមទាំងចំណីអាហារផ្សេងៗទៀត ដូចជាល្មៀស ខ្ទឹម បបរជាដើម ខ្លាចក្រែងមានជំងឺដល់ម៉ែ និងកូនទៅក្នុងផ្ទៃ ។

មួយទៀត ម៉ែមិនហ៊ានបរិភោគអាហារខុសពេល

www.elibraryofcambodia.org

វេលាជម្ងឺតា ពីព្រោះចាស់ៗតែងប្រាប់ថា នាំឲ្យកូនកើតឥតសណ្ដាប់ធ្នាប់ តំណាមមួយទៀត មិនឲ្យផឹកទឹកយប់ ដោយសារខ្លាចក្រែងកូនដែលនៅក្នុងផ្ទៃថ្ងាសពេក ពិបាកដល់ពេលឆ្លងទន្លេ ។ កូនអើយ ! ការតមមិនមែនអស់ត្រឹមតែប៉ុណ្ណោះទេ នៅមានច្រើនជាអនេកទៀតណាស់ ដែលម៉ែមិនអាចរៀបរាប់ប្រាប់កូនឲ្យអស់សេចក្ដីបាន ។

ម៉ែតស៊ូក្នុងការថែរក្សាគភ៌ ដោយការខំស្វះស្វែងរកថ្នាំមករក្សាគភ៌ទៀត បើម៉ែឮគេប្រាប់ថា ថ្នាំណាដែលរក្សាគភ៌បានសុខ ម៉ែខំដើរទៅរកយកមកប្រើឲ្យទាល់តែបាន ។ មានថ្នាំខ្លះដែលម៉ែមិនដែលចូលចិត្តប្រើសោះ ដូចជាថ្នាំមានជាតិស្រា ថ្នាំមានជាតិល្វីងជាដើម ម៉ែត្រដរផឹកដើម្បីកូនដែលនៅក្នុងផ្ទៃឲ្យមានសុខភាពបរិបូណ៌ ។

ថ្នាំរក្សាគភ៌មានច្រើនជាអនេកណាស់ អាស្រ័យទៅតាមស្រុកភូមិដែលនិយមប្រើ មានខ្លះដាំទឹកផ្កាឈូក ស្លឹកខ្ទឹសម្ពរ សំបកពងមាន់ មើមក្រវាញជ្រូកជាដើម សម្រាប់ជួយសំរួលដល់ផ្ទៃ ដើម្បីឆ្លងទន្លេងាយ ។

www.elibraryofcambodia.org

មិនត្រឹមតែរកថ្នាំរក្សាគភ៌ប៉ុណ្ណោះទេ ម៉ែថែមទាំងទៅរកលោកគ្រូ ដែលចេះមន្តអាគមឲ្យធ្វើខ្សែចង្កេះ ឬខ្សែក ដើម្បីការពាររន្ទាចព្រាយបិសាច មិនឲ្យមកយាយីបៀតបៀនកូន ដែលកំពុងតែដេកក្នុងផ្ទៃម្តាយ។

ខណៈពេលដែលម៉ែកំពុងតែពពោះ ម៉ែព្យាយាមវៀរបង់នូវសេចក្តីសប្បាយរីករាយទាំងឡាយណា ដែលនាំឲ្យមានភ័យដល់កូន ។

ម្យ៉ាងទៀត ម៉ែសែនចំបែងចិត្ត ដោយម៉ែចង់ដឹងថា តើកូនម៉ែដូចម្តេច? ប្រុសឬស្រី ខ្មៅឬស ល្អឬអាក្រក់ ល្ងង់ខ្លៅឬឆ្លៀវឆ្លាស មានបុណ្យឬឥតបុណ្យ ។ ម៉ែតែងតែបែបន់ព្រះសំពះទេវតា សូមឲ្យលោកជួយបីបាច់ថែរក្សាកូនម៉ែឲ្យបានជាកូនល្អ ជាកូនប្រសើរ ជាកូនប្រកបដោយធម៌ ។

ម៉ែព្យាយាមរក្សាគភ៌ ដោយសេចក្តីលំបាកគ្រប់បែបយ៉ាង ការពារអន្តរាយផ្សេងៗ វាំងប្រយ័ត្នគ្រប់ឥរិយាបថទាំងបួន ម៉ែធ្វើយ៉ាងនេះអស់រយៈពេល៩ខែ ឬ១០ខែ ដោយទឹកចិត្តតែមួយថា " ចង់ឲ្យកូនរស់ប្រកបដោយសុខភាពបរិបូណ៌ " ។

www.elibraryofcambodia.org

ការរៀបរាប់មកទាំងប៉ុន្មានខាងលើនេះ មិនបានល្អិតល្អន់គ្រប់ជ្រុងជ្រោយទេ ។ ដោយសារភាសាសរសេរ មិនដូចជាភាសាដែលរៀបរាប់ចេញពីទឹកចិត្តម៉ែ ដែលថ្នក់ថ្នមកូននោះទេ ។ តែបើយើង មើលឲ្យគ្រប់ជ្រុងជ្រោយទៅឃើញថា ភារៈដែលម៉ែថែរក្សាកូននេះ ពិតជាមានទំងន់ធ្ងន់មែន ធ្ងន់ដោយឥតអ្វីប្រៀបធៀប និងគណនារៀបរាប់ពុំបានឡើយ ។ អញ្ចឹងយើងជាកូនគ្រប់គ្នា ត្រូវតែគិតមើលឲ្យមែនទែនថា តើម៉ែថែរក្សាគភ៌រយៈពេល៩ខែ ឬ១០ខែហ្នឹងលំបាកអញ្ចឹងមែន ឬយ៉ាងណា ? បើយើងគិតឲ្យបានស៊ីជម្រៅទៅឃើញថា មិនមែនលំបាកតិចទេ គឺលំបាកខ្លាំងណាស់ ដូច្នេះហើយបានជាលោកពោលថា ភារៈម៉ែធ្ងន់ក្រៃលែងធ្ងន់ លំបាកក្រៃលែងលំបាក លើសជាងភារៈដទៃៗទាំងអស់ ។ ម្យ៉ាងទៀតភារៈនេះ ជាភារៈដែលគ្មាននរណាអាចជួយសំរាលបាន កូនដែលអាចរស់រានមានជីវិតទៅបាន ក៏អាស្រ័យដោយទឹកចិត្ត និងកម្លាំងកាយរបស់ម៉ែ ។ កម្លាំងកាយ និងកម្លាំងចិត្តម៉ែ ដែលថែរក្សា

www.elibraryofcambodia.org

កូននេះធំធេងណាស់ មិនអាចនឹងយកអ្វីទៅវាស់ និងវាយតម្លៃឲ្យស្មើបានឡើយ ។ បើទោះបីកូនជាកូនតាំងចិត្តថា នឹងសងលោកវិញ ក៏មិនដឹងថានឹងយកអ្វីមកធ្វើជាថ្នូរសងនូវកម្លាំងកាយ និងកម្លាំងចិត្តម៉ែបានដែរ ។ អញ្ចឹងកូនគ្រប់រូបត្រូវគិតឲ្យឃើញ ពីទម្ងន់នៃការពរផ្ទៃរបស់ម៉ែដែលថែរក្សាកូន ៩ខែ ឬ១០ខែនេះឲ្យឃើញថា សាច់ឈាមរាងកាយរបស់យើង សុទ្ធតែជាចំណែក និងដំណក់ឈាមស្រស់ៗរបស់ម៉ែ ។ ដូច្នេះ ត្រូវកូនគោរពប្រណិប័តន៍ម៉ែឪជាព្រះ ដែលខំពរផ្ទៃខ្លួនទៅតាមធម៌ ។

www.elibraryofcambodia.org

# ការសម្រាលកូន ឬ ការឆ្លងទន្លេ

តាមការនិយមប្រើពាក្យរបស់ខ្មែរយើង លោកហៅស្ត្រីដែលញុំាងទារកឲ្យកើត ឲ្យចេញចាកគភ៌ ហៅថា "សម្រាលកូន" នេះជាវោហាសម្រាលភារៈដ៏ធ្ងន់ឲ្យស្រាល ។ ម្យ៉ាងទៀត លោកហៅថា "ការឆ្លងទន្លេ" នេះជាវោហាប្រៀបធៀបទៅនឹងការធ្វើសំណើរឆ្លងទន្លេ សមុទ្រ ដែលជាផ្លូវពិបាកក្នុងការធ្វើដំណើរឆ្លងកាត់ ។

យើងក៏បានដឹងហើយថា ការធ្វើដំណើរតាមទន្លេដោយទូក តែងតែមានភ័យអន្តរាយដល់ជីវិត ដោយក្នុងផ្លូវខ្លះមានទឹកជំនន់ឡើងល្ហល្ហេវ ថែមទាំងមានខ្សែទឹកហូរកួចខ្ទួលខ្ទាញ់ និងមានព្យុះសង្ឃរា រលកបោកបែកផ្កាត្រែងមើលទៅគួរឲ្យភ័យតក់ស្លុតរន្ធត់ណាស់ ។ កាលដែលគេឆ្លងទន្លេរួចម្តងៗ ឈ្មោះថាមានកព្វសំណាងប្រសើរណាស់ ។ ហេតុដូច្នេះហើយ បានជាបូរាណលោកយកពាក្យ "ឆ្លង-ទន្លេ" នេះមកប្រដូចនឹងការប្រសូតិកូន ដែលម្តាយគ្រប់រូបតែងតែឆង ហើយជួបប្រទះនវគ្រោះមហន្តរាយដល់

www.elibraryofcambodia.org

អាយុជីវិតជារៀយៗ ដូចជាអ្នកធ្ងន់ទន្ទៃដែរ ។ អញ្ចឹងហើយ កាលដែលម៉ែធ្ងន់ទន្ទេកូនគ្រប់គ្នារូបម្តងៗ នោះឈ្មោះថាម៉ែមានកព្វសំណាងធំណាស់ ។

ក្នុងពេលជិតដល់ថ្ងៃប្រសូតិនោះ ម៉ែពោរពេញទៅដោយក្តីទុក្ខវេទនាយ៉ាងក្រៃលែង ដ៏រាបដល់ស្លុកមុខ ស្លេកស្លាំងក្រៀមក្រោះ ស្រងូតស្រងាត់ ដោយមានសេចក្តីទុក្ខព្រួយជាច្រើនយ៉ាងដូចជា :

-ព្រួយខ្លាចក្រែងកូនមិនបានរស់រានមានជីវិត រស់នៅក្នុងលោកដូចគេ ។

-ព្រួយខ្លាចក្រែងខ្លួនគ្មានជីវិតរស់នៅ បានថែរក្សាកូនឲ្យបានសុខស្រួលដូចគេ ។

ទន្ទឹមនឹងការព្រួយបារម្ភនេះផងដែរ ម៉ែក៏មិនព្រងើយកន្តើយ នៅទំនេរស្ងៀមឥតប្រយោជន៍ទេ ម៉ែរៀបចំផ្ទះសម្បែងទុកដាក់របស់របរឲ្យមានរបៀបរៀបរយល្អ ព្រោះក្នុងខណៈពេលនោះ ម៉ែមិនបានរៀបចំទុកដាក់ទៀតទេ ទុកការៈឲ្យឪកូនជាអ្នកមើលថែរក្សា និងរៀបចំទុកដាក់ម្តង ។ ម៉ែបានឲ្យឆ្មប ឬគ្រូពេទ្យពិនិត្យមើលដោយចង់ដឹងថា តើ

www.elibraryofcambodia.org

នៅប៉ុន្មានថ្ងៃទៀតនឹងដល់ពេលប្រសូតិ ។ ម៉ែផុតធូបបន់ព្រះសំពះទេវតា សូមឲ្យលោកជួយបីបាច់ថែរក្សាកូនម៉ែ សូមឲ្យការឆ្លងទន្លេបានដោយសុវត្ថិភាព ។ ម៉ែបានប្រាប់ដំណឹងនេះ ដល់មាតាបិតា ជីដូនជីតា និងអ្នកដែលស្និទ្ធស្នាល ព្រមទាំងអ្នកនៅជិតខាងឲ្យដឹង និងសុំឲ្យមកជួយជីវិតម៉ែ និងកូនម៉ែផង ។ ម៉ែភ័យអរៗជានិច្ច ដោយម៉ែធ្លាប់ឃើញអ្នកជិតខាង ខ្លះមានគ្រោះថ្នាក់បាត់បង់ជីវិត ព្រោះតែឆ្លងទន្លេនេះ ។

ចំណែកឯម៉ែអរមុខមាត់រីករាយ ព្រោះម៉ែជិតបានឃើញមុខមាត់កូន ដែលនៅពួនសំងំក្នុងផ្ទៃម្តាយរយៈពេល ៩ខែ១០ថ្ងៃ កន្លងមកហើយនោះ ។ ពេលប្រសូត្រ ជីវិតម៉ែហាក់ដូចជាគ្មានតម្លៃទេ ពីព្រោះវាជារយៈពេលដែលប្រកបដោយគ្រោះថ្នាក់ជាអនេកប្បការ ជារយៈពេលដែលជីវិតម៉ែអាចផុយស្រួយប្រៀបបានទៅនឹងសសៃអំបោះ ប្រៀបបានទៅនឹងដំណក់ទឹកលើស្លឹកឈូក ។ ពេលនេះជីវិតម៉ែកំពុងតែស្ថិតនៅក្នុងអំណាចនៃមច្ចុរាជអស់ទៅហើយ រូបកាយម៉ែជាប្ចុំទីរបស់ពួកពិ ... ពួនតែគ្រាពេលប៉ុក្កពាប់ហួស

www.elibraryofcambodia.org

ប្រមាណ ហាក់បីដូចជាត្រូវគេចៀរ គេកាត់ គេចិញ្ច្រាំ ជាកំណាត់តូចនិងកំណាត់ធំ ជួនកាលមានដល់ទៅសន្លប់បាត់ស្មារតីទើបប្រសូតរួច ។ ពេលម៉ែប្រឹងឆ្លងទន្លេ សរសៃតូចនិងសរសៃធំទាំងប៉ុន្មាន ដែលមាននៅក្នុងខ្លួនប្រាណម៉ែ ហាក់ដល់សរសៃធ្លាក់ៗ ដែលជាប់នៅគ្រប់គល់សក់ត្រូវរងើ ញើសញ័រញាក់គ្មានសល់ រីឯញើសគ្រប់រន្ធ ត្រូវហូរធ្លាយធ្លាក់មកជោគខ្លួន ជោគក្បាល និងមុខមាត់ ។ ទាំងអស់នេះហើយ ជាគ្រោះកំណាចយ៉ាងសាហាវប្រចាំគ្រួសារគ្រប់របេ ដែលពាក្យចាស់លោកហៅថា "ឆ្លងទន្លេ" នោះ ។ បើទោះបីជាម៉ែរងទុក្ខទោសវេទនាខ្លាចផ្សាយ៉ាងដូច្នេះក៏ដោយ ក៏ម៉ែមិនតូចចិត្ត ឬអាក់អន់ស្រពន់ចិត្តចំពោះកូនដែរ ម៉ែពេញចិត្ត និងទទួលនូវភារៈនេះ ដោយឥតប្រកែកឡើយ ។

ដោយសារឆ្លងទន្លេចេះតែមានការភ័យខ្លាច បានជាពេលឆ្លងទន្លេម្តងៗ ឃើញមានមាតាបិតា ជីដូនជីតា ញាតិមិត្ត មកជួបជុំគ្នារហង់ត្រៀមខ្លួនប្រុងជួយ ដោយមុខក្រៀមក្រំ មិនស្រស់ស្រស់បស់ប៉ុន្មានឡើយ ។ ហើយចេះតែខ្សឹបខ្សៀវពិគ្រោះគ្នាជានិច្ចថា "ទំជួយក្លាឲ្យមែនទែន កុំឲ្យប្រថុះ

www.elibraryofcambodia.org

ដោយឲ្យសោះ ប្រយ័ត្នមានគ្រោះកាចមកបៀតបៀន ។ ពេលម៉ែឆ្លងទន្លេរួចដោយសុវត្ថិភាពហើយ អ្នកទាំងអស់គ្នា មានទឹកមុខស្រស់បស់រីករាយដូចផ្កាឈូក សួរគ្នាអ៊ូរអរថា យ៉ាងម៉េចទៅហើយវើយ ប្រុស ឬស្រី ។ ចំណែកម៉ែវិញ គ្រាន់តែឮសំលេងកូនយំរ៉ាឡើងកាលណា ម៉ែហាក់ដូចជាបាត់ឈឺចុកចាប់ក្នុងសពាង្គកាយអស់រលីង ទឹកមុខម៉ែ ដែលកំពុងតែស្លឹតស្រពោន បែរប្រែក្លាយទៅជាស្រស់ញញឹម ។ ម៉ែទាសុំយកកូនមកមើល ព្រោះម៉ែចង់ឃើញមុខកូន តើស្រស់ស្អាតយ៉ាងណា ពេលម៉ែឃើញមុខកូនហើយ ម៉ែក្សាន្តចិត្តស្ទើរតែបាត់ឈឺចុកចាប់អស់រលីង ។ ប៉ុន្តែខ្លួនម៉ែហាក់បីដូចជាស្រោលស្ទើក ប្រៀបបានទៅនឹងស្បូវក្លាំងមួយក្ដាប់ ដែលត្រូតស្ងួតស្ងប់ស្ងាត់នឹងកំដៅព្រះអាទិត្យ ។ ម៉ែត្រេកអរណាស់ ហាក់ដូចជាបានចាប់កំណើតជាថ្មីម្ដងទៀតពួដ៏ហានសួគ៌ ដោយម៉ែបានពុះពារឆ្លងរួចនូវមហាគ្រោះថ្នាក់ដ៏សែនធំនេះ ។ជាពិសេស ម៉ែត្រេកអរចំពោះកូន ដែលបានកើតឃើញពន្លឺព្រះអាទិត្យដោយសុវត្ថិភាព ។

តទៅម៉ែរង់ទុក្ខវេទនា ដោយទ្រាំទិងការអាំងភ្លើងក្ដៅ

www.elibraryofcambodia.org

ដូចជាដុតទាំងរស់ រងើកភ្លើងដែលបញ្ចេញចំហាយមកត្រូវកងកាយខ្លួនប្រាណម៉ែ ក្ដៅរោលរាលស្ទើរតែមានចេញពងដុំៗ ។ ម៉ែទ្រាំផឹកទឹកអំបិលប្រៃនេះហៅសែនប្រៃ ម្ហូបអាហារដែលពោរពេញទៅដោយជាតិហឹរ មានម្រេច ខ្ទឹម គួបផ្សំនិងទឹកថ្នាំដែលបរិបូរណ៍ទៅដោយធាតុក្ដៅ សំរាប់ជំនួយដល់ការរំលាយឈាមដូចជា ក្រវ៉ាញ ដង្កោ ជីប៉ូ បំពង់ឡោមជាដើម ។ ម៉ែអត់ទ្រាំក្ដៅ អត់ទ្រាំផ្សែង ដោយមិនត្អូញត្អែ ព្រោះតែជីវិតកូន ។

ចំពោះឪពុកវិញ ចាប់តាំងតែពីពេលដែលដឹងថា ម៉ែមានគភ៌មក ពុកមានសេចក្ដីត្រេកអរក្នុងចិត្ត ពុកញញឹមញញែមដោយបើកភ្នែកសម្លឹងទៅរកជើងមេឃ ដ៏ធំទូលាយដែលហាក់បីដូចជាមានន័យអ្វីម្យ៉ាង មកបន្ថែមលើជីវិតពុក ។ ក៏ប៉ុន្តែសេចក្ដីរីករាយរបស់ពុក ត្រូវបានលាយឡំដោយក្ដីព្រួយបារម្ភធ្ងន់ត្រួតៗ លើគ្នា :

-ពុកអាណិតម៉ែកូន ដែលត្រូវទទួលការងារលំបាកក្នុងរយៈកាលនៃការពផ្ទៃ ។

-ព្រួយខ្លាចក្រែងកូន ដែលកំពុងតែដេកទៅក្នុងផ្ទៃ

www.elibraryofcambodia.org

របស់ម៉ែកូន ពុំបានបរិបូណ៌ដោយសុខភាព និងមិនបាន
រស់រានមានជីវិតបានឃើញពន្លឺព្រះអាទិត្យដូចកូនគេដទៃ ។

-ព្រួយក្រែងម៉ែកូនមានគ្រោះថ្នាក់ ដែលបណ្ដាល
មកពីមានគភ៌ ឬគ្រោះថ្នាក់បាត់បង់ជីវិតក្នុងពេលឆ្លងទន្លេ។

-ព្រួយក្រែងខ្លួនឪមានអន្តរាយផ្សេងៗ ដល់បាត់បង់
ជីវិត ឬរកទ្រព្យសម្បត្តិមកចិញ្ចឹមកូន និងម្ដាយកូនមិនបាន
នាំឲ្យកូន និងម្ដាយកូនមានការពិបាក ។

-ព្រួយម្យ៉ាងទៀតចំពោះបន្ទុកគ្រួសារ ដែលត្រូវ
បន្ថែម ពីព្រោះពុកត្រូវបង្កើនកម្លាំងស្មូងទ្វេដង ដើម្បីរក
ប្រាក់មកចិញ្ចឹមកូនប្រពន្ធ ។

ឪពុកត្រូវទទួលបន្ទុករកថ្នាំសង្កូវសេពប្រែបយ៉ាង ដើម្បី
ថែរក្សាគភ៌ម៉ែកូន និងថែរក្សាសុខភាពម៉ែកូន រហូតដល់
ពេលឆ្លងទន្លេ ព្រមទាំងរកថ្នាំព្យាបាលថែមទៀត សម្រាប់
រយៈកាលក្រោយពេលឆ្លងទន្លេ ។ បើមានមនុស្សណាម្នាក់
ប្រាប់ថាគ្រូនៅឯណោះពូកែ ថ្នាំនៅទីនោះសក្តិសិទ្ធិ ឪពុក
ច្បាស់ជាស្វះស្វែងទៅរកថ្នាំដល់ទីនោះភ្លាម ។ ម្យ៉ាងទៀត
ដោយក្ដីអាណិតអាសូរយ៉ាងជ្រាលជ្រៅចំពោះម៉ែកូន ឪខិត

www.elibraryofcambodia.org

ទំនេរចំណី ឬផ្លែឈើដែលម៉ែកូនចង់ពិសារ ទោះបីជាមានតម្លៃថ្លៃបន្តិចក៏ដោយ ។

ពេលដែលម៉ែកូនកំពុងឈួនទន្លេ ឪស្ទុះទៅដាំទឹកក្តៅដើម្បីផ្សំថ្នាំព្យាបាលការឈឺចុកចាប់ ទុកឲ្យម៉ែកូនពិសារក្រោយពេលឆ្លងទន្លេហើយភ្លាមៗ ។ ឪនៅចាំស្តាប់លទ្ធផលខាងក្រៅបន្ទប់ ចិត្តឪសែនអន្ទះសារ ដើរចុះដើរឡើង ចាំតែស្តាប់សំលេងកូន និងចង់ដឹងថាតើកូនប្រុសឬស្រី ហើយស្រស់បស់យ៉ាងណា? ពេលឮសម្លេងកូនយំរ៉ាឡើង ឪហាក់បីដូចជាស្រាលខ្លួនស្ញើក ធូទ្រូងខ្យាក ស្រឡះចិត្តមាត់ឪញញឹមញញែមបិទមិនជិត ឪថែមទាំងដឹងថា ទ្រព្យដ៏មានតម្លៃជាងជីវិតបានឃើញពន្លឺព្រះអាទិត្យហើយ ។

ចាប់តាំងពីពេលនោះមក ឪទទួលរ៉ាប់រងការងារទាំងអស់ក្នុងគ្រួសារ គឺការថែរក្សាម៉ែកូន ការងារបោកគក់សំពត់អាវនិងកន្ទប ដែលអ្នកជាទៃខ្ពើមរអើមជួយធ្វើជំនួសមិនបាន ធ្វើម្ហូបអាហារតម្រូវទៅតាមសុខភាពម៉ែកូន ជួយដាំថ្នាំឲ្យម៉ែកូនពិសារ និងបោសជូតផ្ទះសម្បែងផង ។ ដោយសារជីវភាពគ្រួសារមិនសូវធូធាផង ឪត្រូវតែក្រោកតាំងពី

www.elibraryofcambodia.org

ព្រលឹមស្រាងៗ បំពេញការងារផ្ទះឲ្យហើយស្រេចបាច់ ទើប ពុកផ្ញើម៉ែកូនទិងញាតិជិតខាងឲ្យជួយរាំងថែរក្សា ទើបពុក ចេញទៅប្រកបការងារ ដើម្បីរកចំណូលមកផ្គត់ផ្គង់គ្រួសារ ពេលចប់ការងារភ្លាម ឪក៏ខំរូតរះរលះរលាំងត្រឡប់មកផ្ទះ វិញ ។ ពេលឪកំពុងធ្វើការ អារម្មណ៍របស់ពុកដក់ជាប់តែ នឹងផ្ទះជានិច្ច សម្លេងកូនហាក់បីដូចជាលាន់រងំក្នុងត្រចៀក ពុក ។ ចំណែកឯកិច្ចការទាំងឡាយណា ដែលពុកពិបាកធ្វើ ឬមិនធ្លាប់ធ្វើ ពុកត្រូវតែខំធ្វើឲ្យអស់ពីកំលាំងកាយចិត្ត ពេលខ្លះទៀតពុកក៏បានពឹងពាក់បងប្អូន ញាតិសណ្ដាន ឬ ជួលគេឲ្យជួយធ្វើជំនួសម្ដងម្កាល ។ ឪប្រើគ្រប់មធ្យោបាយ ទាំងអស់ ដើម្បីកូនទិងម៉ែកូន ទោះបីជាលំបាកយ៉ាងណា ក៏ពុកមិនរាថយដែរ ។ ពុកខំព្យាយាមខ្នះខ្នែងរកទ្រព្យសម្បត្តិ មកផ្គត់ផ្គង់បំពេញថវិការគ្រួសារផង មើលថែរក្សាម៉ែរបស់ កូនផង មើលថែរក្សាកូនផង មើលថែរក្សាទ្រព្យសម្បត្តិ ក្នុងផ្ទះនិងក្រៅផ្ទះផង ពុកព្រួយលំបាកគ្រប់ឥរិយាបថទាំង បួន ដេកមិនបានពេញភ្នែក ដើរ ឈរ អង្គុយក៏មិនបាន សុខស្រួល ដបក្បាលពីទៅកមោះ ឬកាលពីម៉ែកូនមិន

www.elibraryofcambodia.org

ទាន់មានគតក៏នោះឡើយ ។ ពុកវិតតែទុក្ខព្រួយថែមទៀត ប្រសិនបើម៉ែកូនឈឺ ឬក៏កូនឈឺ ពុកក៏ទទួលការឈឺចាប់នោះជាមួយម៉ែកូន ឬជាមួយនិងកូនផងដែរ ។ បើទោះបីជាឪមានទុក្ខព្រួយយ៉ាងណាក៏ដោយ ក៏ឪនៅតែធ្វៀតឱកាសរកទ្រព្យសម្បត្តិសម្រាប់ជាស្បៀងអាហារ ជាសំលៀកបំពាក់ និងជាថ្នាំកែរោគផ្សេងៗ ថែមទៀតផង ។ ទាំងអស់នេះហើយជាទុក្ខរកម្មរបស់ឪ ដែលអ្នកដទៃមិនមែនជាឪធ្វើតាមមិនបាន ។

ភារៈដ៏ធ្ងន់បំផុតរបស់ឪ គឺការគ្រប់គ្រងថែរក្សារបស់របរទ្រទៅ គ្រប់បែបយ៉ាងនៅក្នុងគ្រួសារ ចំណែកភារៈដ៏ធ្ងន់បំផុតរបស់ម៉ែកូន គឺការគ្រប់គ្រងថែរក្សាកូនគ្រប់គ្នាដោយផ្ទាល់ ។

ទោះបីជាម៉ែស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ក៏នៅតែថែរក្សាការពារកូនយ៉ាងម៉ត់ចត់ អស់ពីចិត្តពីថ្លើមដែលសុទ្ធតែប្រកបដោយព្រហ្មវិហារធម៌ ។ តែទោះបីជាមានការរក្សាយ៉ាងម៉ត់ចត់យ៉ាងណាក៏ដោយ ក៏នៅតែមានការវិនាសអន្តរាយដល់ជីវិតម៉ែ និងកូនខ្លះៗ ជាធម្មតា ។

www.elibraryofcambodia.org

ជួនកាលកូនខ្លះ ទើបនឹងចាប់បដិសន្ធិបានតែបី ឬបួនខែប៉ុណ្ណោះ ក៏បានស្លាប់នៅក្នុងផ្ទៃក៏មាន ខ្លះទៀតដល់ពេលប្រសូតិមកហើយ ស្លាប់ទៅក៏មាន ខ្លះម៉ែស្លាប់ទាំងកូនដែលកំពុងនៅក្នុងផ្ទៃក៏មាន ខ្លះទៀតប្រសូតិមកមាតាត្រូវស្លាប់ តែទារកនៅរស់ក៏មាន ខ្លះទៀតក្នុងពេលប្រសូតិស្លាប់ទាំងពីរនាក់ម្តាយនិងកូនក៏មាន ទាំងអស់នេះ សុទ្ធតែជាគ្រោះថ្នាក់ ដែលជៀសវាងមិនផុត ព្រោះអីជីវិតរបស់សត្វលោកទាំងអស់មិនទៀងទាត់ មិនស្ថិតស្ថេរ គ្មានកាលបរិច្ឆេទពិតប្រាកដ ។

អញ្ចឹងកូនម៉ែទាំងអស់គ្នា ដែលកើតមករស់រានមានជីវិតប្រកបដោយសុខភាពបរិបូណ៌នេះ សុទ្ធតែជាអ្នកមានសំណាង ឬជាអ្នកមានបុណ្យធំណាស់ ។ មិនតែប៉ុណ្ណោះសោតថែមទាំងមិនកំព្រាឪពុកម្តាយទៀត កូនកើតមកមានម្តាយឪពុកថែរក្សា ម៉ែព ម៉ែបី ម៉ែថ្នាក់ថ្នម ម៉ែគ្រប់គ្រងម៉ែឱប ម៉ែបបោសអង្អែលលួងលោម ម៉ែបំពេរ ម៉ែចិញ្ចឹមឲ្យទាល់តែមានវ័យវឌ្ឍនាការធំដឹងក្តីឡើង ។ កូនដែលមានម៉ែថែរក្សា ប្រសិនបើយើងគិតឲ្យសព្វគ្រប់ទៅឃើញថា

www.elibraryofcambodia.org

ម៉ែមិនគ្រាន់តែជាម៉ែទេ គឺម៉ែជាបុណ្យរបស់កូនផង ព្រោះកូនបានរស់រានមានជីវិតធំធាត់ឡើងបាន ដោយអាស្រ័យម៉ែជួយទំនុកបំរុង ។ បើសិនជាមិនមានម៉ែជួយទំនុកបំរុងទេ សមកូនទាំងឡាយនឹងរងទុក្ខវេទនាពិតឥតសង្ស័យឡើយ។ ព្រោះកូនកំព្រា ដែលមិនមានម៉ែឪថែរក្សា តែងតែជួបទូរសេចក្តីទុក្ខគ្រប់បែបយ៉ាង ដូចជាកូនបានដឹង និងបានឃើញគ្រប់ៗ គ្នាហើយ ។

តពីពេលឆ្លងទន្លេមក ម៉ែឪតែងមានធ្វើពិធីផ្សេងៗជាច្រើនទៀតទៅតាមប្រពៃណីនិយម ដើម្បីឲ្យកូនមានមង្គលសិរីសួស្តី និងមានអាយុវែង ។ ឯមង្គលដែលត្រូវធ្វើនោះមានជាអាទិ៍ គឺមង្គលកាត់សក់ព្រៃ មង្គលបំបើកភ្នែក មង្គលឲ្យនាមជាដើម ។ មង្គលទាំងអស់នេះ ខណៈពេលដែលម៉ែឪធ្វើ បានអញ្ជើញចាស់ទុំមកជួបជុំគ្នាហើយប្រសិទ្ធពរជ័យចងដៃឲ្យកូន ដើម្បីឲ្យកូនបានជាកូនល្អ ជាកូនប្រសើរ ជាកូនប្រកបដោយគុណធម៌តទៅថ្ងៃអនាគត ។ ពិធីការណាដែលនាំឲ្យកូនបានសុខចំរើន ម៉ែឪធ្វើតាមទាំងអស់ ការធ្វើកិច្ចការទាំងអស់នេះ និងជាម៉ែឪឆោតល្ងង់ក៏

www.elibraryofcambodia.org

ថាបាន ។ តែដោយពិតទៅ ម៉ែឪធ្វើទៅតាមប្រពៃណី និយម ដែលចាស់បុរាណធ្លាប់ធ្វើតៗ គ្នាមក ។ ដោយពួក គាត់ជឿជាក់ថា បានគាប់ប្រសើរ បានសុខចម្រើន និងរស់ នៅមានអាយុយឺនយូរវែងឆ្ងាយ ។ បើសិនជាម៉ែមានការផ្តាំ ផ្ញើ ក៏គួរអភ័យទោសដល់ម៉ែដែរ បើម៉ែមានការសិក្សា បរិបូណ៌យល់ការអស់នេះពិតប្រាកដ មុខជាម៉ែគ្រប់រូបមិន ព្រមធ្វើឲ្យខុសឃ្លាតពីតម្រាទេ ។ និយាយដោយសង្ខេប ប៉ុណ្ណោះគង់យើងទាំងអស់គ្នា បានឃើញចិត្តម៉ែហើយថា ម៉ែមានចិត្តតែមួយ គឺចង់ឲ្យកូនរស់ប្រកបដោយសេចក្តី សុខ ។ ដូច្នេះហើយ បានជាលោកពោលទុកមកថា "បណ្តា ម៉ែឪទាំងពីរនាក់នេះ ម៉ែធ្វើការកម្រជាងឪពុក" គឺពពោះផង ឆ្លងទន្លេផង ចិញ្ចឹមបីបាច់ថែរក្សាផង តែម្នាក់ឯង ។

# ការចិញ្ចឹមបីបាច់ថែរក្សាកូន

ចាប់តាំងពីពេលដែលកូនប្រសូតិមក ម៉ែឪបាន ស្រាកស្រាន្តការព្រួយបារម្ភខ្លះ ប៉ុន្តែក៏នៅមានករណីយកិច្ចចំពោះកូនកាន់តែខ្លាំងឡើងទ្វេដង គ្មានទីបំផុតថែមទៀត ។ ម៉ែទទួលការឈឺចាប់ត្រាំត្រា ក្នុងពេលប្រសូតិរហូតមកអស់វេលាជាច្រើនថ្ងៃ ម៉ែខំទ្រាំអាំងភ្លើងក្ដៅ ដូចគេដុតទាំងរស់ ទ្រាំផឹកថ្នាំមានជាតិប្រៃល្វីងជូរចត់ សែនពិបាកលេប ទ្រាំតមអាហារខ្លះដែលម៉ែចូលចិត្ត ខ្លាចក្រែងទាស់ចំណីអាហារ នាំឲ្យពិបាកដល់កូន ។ ការចិញ្ចឹមកូនឲ្យរស់មិនមែនជាការងាយទេ គឺជាភារៈមួយកម្រក្រៃពេលណាស់ ។ ក្នុងការចិញ្ចឹមកូន ម៉ែត្រូវប្រើការព្យាយាមជាទីបំផុត ត្រូវប្រើទាំងកម្លាំងកាយ កម្លាំងចិត្ត គួបផ្សំនិងកម្លាំងទ្រព្យសម្បត្តិផង កម្លាំងប្រាជ្ញាផង ទើបអាចចិញ្ចឹមកូនឲ្យល្អទៅបាន ។ ស្ត្រីដែលមិនមានជាម៉ែ ក៏អាចចិញ្ចឹមកូនឲ្យរស់បានដែរ តែក៏មិនបានប្រហែល និងម៉ែបង្កើតខ្លួនឯងទេ ព្រោះខ្វះទឹកចិត្តប្រកបដោយព្រហ្មវិហារធម៌ ។

www.elibraryofcambodia.org

ម៉ែឪខំថ្នាក់ថ្នមថែរក្សា គ្មានធ្វេសប្រហែសទេ ទាំងចិត្ត ទាំងវិញ្ញាណនៅជាប់នឹងរូបកូនគ្រប់ពេលវេលា ។ ពេលដេកទោះបីជាងងុយងោកងក់យ៉ាងណា ក៏ស៊ូទ្រាំនៅដកបដល់កូនដេកលក់ស៊ប់ ទើបហ៊ានដេក ។ ពេលកំពុងដេកលក់ គ្រាន់តែឮមាត់កូនយំ ឬឮកូនបំរះម៉ែភ្ញាក់ភ្លាមម៉ែស្ទុះក្រោកទៅស្ទាបអង្រែល រកមើលទាយអាយសព្វគ្រប់ ក្រែងមានសត្វអីមកខាំទិចកូន ម៉ែថ្នាក់ថ្នមលើកកូនដោយដៃទាំងពីរឱបផ្ទប់ទិនឱក៏ បបោសអង្រែលលួងលោមបំពេរ ឲ្យកូនបានដេកលក់ទៅវិញ ទើបម៉ែដាក់កូនទៅក្នុងអង្រឹង ឬលើដំណេកវិញ ។ ពេលកូនជុះអាចម៍ ជុះនោមម៉ែគ្មានខ្ពើមរអើមទេ ជូតជុះលាងដោយដៃទាំងពីរផ្ទាល់យ៉ាងស្និទ្ធអស់ពីចិត្តពីថ្លើម។វេលាថ្ងៃទេត្រាទាំងគូរខំពិនិត្យរំពៃគយគន់មើលស្រមោច ស្រមើល មូស សុច រុយជាដើម ខ្លាចវាចូលមកទិច ឬខាំកូន គ្រាន់តែសត្វទាំងនោះមកក្បែរ ម៉ែខំប្រវេប្រវារបោសបក់ ហាក់ដូចជាភ័យខ្លាចខ្លាដំរី មកប្រហារជីវិតកូនអញ្ចឹង ។

www.elibraryofcambodia.org

ម៉ែឪចិញ្ចឹមកូនមានច្រើនប្រការណាស់ យើងបាន ឃើញទីងក្លែកគ្រប់គ្នាហើយថា តាំងពីចូងទន្ទេរូបមក ម៉ែចិញ្ចឹមកូនដោយទឹកដោះម៉ែ ទឹកដោះដែលម៉ែបំបៅកូន គឺជាអាហារទិព្វ ដែលធម្មជាតិនៃរូបកាយម៉ែ បម្លែងចេញអំពីឈាមរបស់ម៉ែ ឲ្យក្លាយទៅជាទឹកអម្រិតដ៏សក្តិសិទ្ធ សំរាប់ចិញ្ចឹមជីវិតកូន ៗ ប្រសិនបើយប់ថ្ងៃណា ដែលកូនបៅច្រើន យប់ថ្ងៃនោះខ្លួនម៉ែក្លាយជាស្រាលស្ងើក ព្រោះត្រូវកូនបឺតយកទឹកដោះស្ទើតែខ្សោះអស់ពីក្នុងទ្រូងម៉ែ ៗ ម៉ែខំរកចំណីអាហារណា ដែលជាជំនួយដល់ការបង្កើនទឹកដោះ ដើម្បីជួយឲ្យទឹកដោះមានកំណើនឡើងវិញ ក្នុងការបំបៅកូនតទៅទៀត ៗ ជាតិលោហិតក្នុងហឫទ័យម៉ែ ហូរចេញមកជាពណ៌ស កើតជាអាហារសម្រាប់កូន ៗ ម៉ែបង្ហូរលោហិតពីក្នុងហឫទ័យមកចិញ្ចឹមកូន មិនមែនអស់តិចទេ ច្រើនខែណាស់ ខ្លះបំបៅរហូតដល់អាយុបីបួនឆ្នាំក៏មាន អស់ទឹកដោះរាប់រយពាន់លីត្រ ទំរាំតែកូនចេះបរិភោគអាហារដោយខ្លួនឯងបានពេញលេញបរិបូណ៌ ៗ ម៉ែធ្វើយ៉ាងនេះរហូតដល់កូនចេះក្រឡាប់ ចេះញញឹម ចេះ

www.elibraryofcambodia.org

អង្គុយ ចេះក្រោក ចេះឈរ ចេះដើរផ្លូវ ចេះនិយាយ ចេះដើរ ចេះរត់ជាដើម ។ ម៉ែមិនមែនគ្រាន់តែចិញ្ចឹមបីបាច់ថែរក្សាកូនឲ្យបានធាត់ធំប៉ុណ្ណឹងទេ ម៉ែខំបង្ហាត់បង្រៀនកូនឲ្យចេះសើច ចេះនិយាយសំដីគួរសម ចេះក្រាបសំពះគោរពចាស់ទុំ ត្រកូលរៀមច្បង និងចេះអំពីសុជីវធម៌ វប្បធម៌ អារ្យធម៌ និងវឌ្ឍនធម៌គ្រប់ផ្នែកទៀតផង ។ ម៉ែអត់ទ្រាំនឹងទុក្ខវេទនា ដោយសារការចិញ្ចឹមកូននេះ អស់វេលាជាច្រើនឆ្នាំមិនមែនអស់វេលាតិចទេ ។ ម៉ែប្រកបដោយព្រហ្មវិហារធម៌ច្រើនណាស់ មិនមែនតិចទេ ប្រសិនបើម៉ែមិនមានព្រហ្មវិហារធម៌វិញ គ្រាន់តែបង្កើតមកហើយបោះទុកចោលទៅគៀនជញ្ជាំងស្លាប់បាត់ទៅហើយ មិនមានជីវិតរស់នៅឃើញពន្លឺព្រះអាទិត្យដូចសព្វថ្ងៃនេះទេ ។ យើងមើល ! កាលពីម៉ែមិនទាន់មានកូន ម៉ែមិនដែលដេកភ័យ ដេកស្ដុតស្មារតីទេ ម៉ែដេកសប្បាយ ដេកពេញភ្នែក ។ កាលដែលម៉ែមានកូនមកដេកក្បែរខ្លួនម៉ែហើយ ម៉ែលែងបានដេកសុខស្រួលទៀតហើយ ដោយសារ ម៉ែត្រូវតែប្រុងប្រយ័តរាំងមើលកូនគ្រប់ពេលវេលា ដូចជាពេល

www.elibraryofcambodia.org

ដេក ម៉ែត្រូវល្ពងលោមកូនឲ្យដេកមុនសិន កូនមិនទាន់ដេកដរាបណា ម៉ែធ្មេចភ្នែកដេកមិនលក់ដរាបនោះ ម៉ែឃើញកូនដេកលង់លក់ហើយ ទើបម៉ែដេកជាក្រោយ ។ ជួនកាល ម៉ែមិនទាន់ទាំងបានប្រាស់ខ្លួនដល់កន្ទេលផង ស្រាប់តែកូនភ្ញាក់ឡើងយំ ម៉ែស្ទុះទៅមើលកូនទាំងទទឹងខ្លួន ម៉ែភ័យនិងកូនណាស់ ។ ម៉ែបបោសអង្អែលល្ពងលោមកូនឲ្យដេកទៅវិញ ទើបម៉ែធ្មេចភ្នែកដេកលក់បាន ។

ម៉ែចិញ្ចឹមបីបាច់ថែរក្សាអប់រំកូន នឿយលំបាកពិតមែន តែម៉ែមិនថ្ងូរ មិនធុញទ្រាន់ មិនបោះបង់ចោលកូនទេ ។ មួយថ្ងៃៗម៉ែនៅតែមានឱកាសប្រលែងលេងនឹងកូន ហៅកូនឲ្យសើច ឲ្យនិយាយ ឲ្យឆ្លើយជាដើម ។ បើកូនគ្រាន់តែញញឹមរក ឬលាន់មាត់ឬសំលេងកែ!ក! ដែលជាសញ្ញាឲ្យដឹងថា កូននិយាយរកខ្លួនតែបន្តិចប៉ុណ្ណោះ ក៏ធូរទ្រូងខ្សាកសប្បាយក្រៃណាសប្បាយ មានកំលាំងព្រឹស ភ្លេចអស់លើសនូវការព្រួយលំបាកទាំងប៉ុន្មាន មានកក្ដ្រាប្រកបដោយទឹកដមព្រហ្មវិហារធម៌ស្រស់ប៉ប្រែ ហត្ថាទាំងទ្វេទ្រស្ទួយកូនឡើងថើបផប់ បញ្ចើចបញ្ចើ ហើយអួតសរសើរ

www.elibraryofcambodia.org

ប្រាប់ក្រុមគ្រួសារ និងញាតិមិត្តរបស់ខ្លួនថែមទៀតថា កូនខ្លួនបេះដូងវៃឆ្លាតណាស់ ។

បើបែរជាកូនឈឺវិញ គ្រាន់តែក្តៅខ្លួន ឬយំច្រើនមិនដេក មិនបៅដូចធម្មតានោះ ម៉ែឪទុក្ខព្រួយស្ទើរលេតំបាត់ស្មារតីអស់ទៅហើយ ភ្លេចបាយ ភ្លេចទឹក តឹងទ្រូងស្ទើរប្រេះ លុះតែកូនបានធូស្រាកស្រាន្តឡើងវិញ ទើបស្រស់មុខទឹកឃើញបាយទឹកវិញ ។

កាលម៉ែមិនទាន់មានកូន ម៉ែតែងថែរក្សាសំអាតខ្លួនការពារខ្លួន ស្រលាញ់ខ្លួនមិនហ៊ានឲ្យសៅហ្មងទេ ។ ដល់ម៉ែមានកូន ម៉ែយកកាយស្អាតរបស់ម៉ែមកធ្វើជាកន្ទោរ ជាបង្គន់ ជាកាជន៍ចាប់គ្រឿងស្មោគគ្រោកកូន កូនបន្ទោរបង់លាមក មូត កំអួតសំបោរដាក់លើម៉ែបានតាមចិត្ត ម៉ែមិនធ្វើមុខជូរទេ ។ កាលពីម៉ែមិនទាន់មានកូន ម៉ែខ្ពើមរអើមគ្រឿងស្មោគគ្រោគទាំងអស់នេះណាស់ បើម៉ែឃើញមាននៅទីណាហើយ ម៉ែគេចចៀសវាងចេញឆ្ងាយពីទីនោះភ្លាម តែតាំងពីពេលដែលម៉ែមានកូនមក ម៉ែផ្លាស់ចិត្តនោះចេញចោលស្រឡះ ។ ទាំងអស់នេះ មិនមែនម៉ែសោគគ្រោកទេ

www.elibraryofcambodia.org

ព្រោះតែម៉ែស្រលាញ់កូន អាណិតកូន មេត្តាកូន ចង់ឲ្យកូនស្អាត ។ កាលបើឃើញកូនមានមន្ទិលសៅហ្មងទាំងនេះហើយ ម៉ែមិនគេចចេញដូចកាលពីមុនទេ ម៉ែបែរហ៊ានជាចូលទៅដោយទឹកមុខញញឹមរីករាយ ទៅប្រវេប្រវាប៉ីបមថ្នាក់ថ្នមលាងជូត សំអាតដោយដៃស្អាតរបស់ម៉ែ ។ ម៉ែយកដៃទៅចាប់ ពាល់ ទៅកាន់គ្រឿងស្មោគគ្រោកទាំងនេះ យ៉ាងស្និទ្ធ ហាក់ដូចជារបស់អស់ទាំងនេះ ជារបស់ក្រអូប ជារបស់ប្រហើរទៅវិញ នេះហើយហៅថាម៉ែ មិនមែនម៉ែគេដូចម៉ែខ្លួនឯងនោះទេ ។

តាមសេចក្តីពិត ស្ត្រីគ្រប់រូបនៅក្នុងលោក តែងតែមានការប្រកាន់ខ្លួន មានការអៀនខ្មាស់ច្រើនជាធម្មតា មិនដែលឲ្យអ្នកណាចាប់ពាល់កាយបានដោយងាយៗទេ។ នេះជាគុណសម្បត្តិ ជាកិត្តិយសរបស់ស្ត្រីគ្រប់រូប ត្រូវតែស្ងួនគ្រងរក្សាដូចរក្សាជីវិត តែចំពោះកូនគ្រប់គ្នា ម៉ែអនុញ្ញាតឲ្យចាប់ប៉ះពាល់បាន ដើរជាន់បាន ម៉ែមិនប្រកាន់ ទោសពៃរ៍ទេ ។ បើកូនទាចៅកណ្តាលហ្វូងមនុស្ស ដោយម៉ែអាណិតកូន ម៉ែភ្លេចអៀនខ្មាស់ ភ្លេចប្រកាន់ខ្លួនអស់ ។

www.elibraryofcambodia.org

ឈាមក្នុងខ្លួនម៉ែពិតៗ ក្លាយជាទឹកក្បែរដោយព្រហ្មវិហារធម៌ ម៉ែត្រេកអរឲ្យកូនបៅៗ ទាល់តែខ្លួនម៉ែរីងស្គាំងស្គមបើទុកជាម៉ែរោយចុកស្រពន់ ក៏ម៉ែនៅតែករុណាកូនជរាប ។

ក្នុងការណ៍ ដែលម៉ែថែរក្សាកូនឃើញថា វាលំបាកដូចដែលយើងបានឃើញ ការរៀបរាប់មកខាងលើខ្លះៗហើយថា ម៉ែថៃទាំតាំងពីលើកដាក់ បីព បំបៅដោះ បញ្ចុកបបរបាយ ផុតទឹក ប៉ោកគក់ជុះលាងមូតលាមក ដោយផ្ទាល់ដៃ រៀបចំទីដំណេក គ្រែពូកកន្ទេលខ្នើយដ៏ស្អាត និងរូបរាងកាយម៉ែក្លាយទៅជាបង្គន់សម្រាប់កូន តែម៉ែមិនធុញទ្រាន់អាក់អន់ចិត្តនិងកូនទេ ព្រោះកូនជាដួងជីវិត បណ្តូលចិត្តទៅហើយ ។ ម៉ែទ្រាំទ្រភារៈដ៏ធ្ងន់យ៉ាងនេះ រាប់សិបឆ្នាំរហូតដល់កូនមានអាយុ២-៣ឆ្នាំ ចេះដើរ ចេះរត់ ទើបបានធូរថយក្នុងការបីព លើកដាក់ខ្លះ តែក៏នៅតែមានការរក្សាប្រុងប្រយ័ត្ន រឹតតែលំបាកខ្លាំងឡើងថែមទៀត ។ សតិស្មារតីម៉ែនៅតែបិតនៅនិងរូបកូន ប្រុងប្រយ័ត្នរក្សាការពារជាងជុំពេជ្រទាំងគ្រាប់ទៅទៀត ខ្លាចក្រែងកូនអើលដួលធ្លាក់ឬចាប់ទាញអ្វីៗ សង្កត់លើ ធ្លាក់បែកបាក់មុតដៃជើង

www.elibraryofcambodia.org

ឬខ្លាចកូនចាប់រើអ្វីៗ ដែលមិនមែនជាចំណីមកស៊ី ឬខ្លាចកូនចេញទៅក្រៅរបងផ្ទះក្រែងខ្ចៃធ្នា ឬសត្វដទៃខាំនាំឲ្យមានគ្រោះថ្នាក់ដល់កូនជាដើម ។

ម្យ៉ាងទៀតសត្វតូចតាច ដូចជាស្រមោច ស្រមើលមូស រុយ សុចជាដើម កាលពីដើមម៉ែហាក់ដូចជាមិនសូវស្អប់ ឬមិនយកជាសត្រូវទេ លុះដល់ម៉ែមានកូនហើយ ម៉ែយកវាជាសត្រូវ ។ ម៉ែគ្រាន់តែឃើញសត្វទាំងនោះហើរមកជិតកូន ម៉ែខ្នាញ់ជាទីបំផុត ភ័យខ្លាចក្រែងសត្វទាំងនោះវាទៅទិចទៅខាំកូន ។ មានជួនកាល ម៉ែទប់ចិត្តមិនបានក្ដាត់ធ្វើបាបណាមួយដងមួយកាលទៅ សូម្បីកូនទៅក្នុងមុងហើយ ម៉ែនៅតែមិនទាន់ទុកចិត្តទៀត ។ បើមានសត្វអ្វីមួយខាំកូនម៉ែយំ ម៉ែភ័យណាស់ ហើយក្រេវក្រោធជេរស្ដីប្រទេចសត្វនោះ ហើយរកប្រេងម្សៅទៅស្រលាបឲ្យកូន ម៉ែរាំងប្រយ័ត្នគយគន់រំពៃរ មើលមិនឲ្យសត្វចង្រៃទាំងនោះ មកខាំកូនម៉ែបានទៀតឡើយ ។

ពេលឮសម្លេងកូនយំ ម៉ែហាក់ដូចជាមានអ្វីមកចាក់ចុចដើមទ្រូងម៉ែឲ្យឈឺខ្លោចផ្សា ឬហាក់ដូចជាសូវរំពាត់

www.elibraryofcambodia.org

ដែលធ្លាក់ទៅលើខ្លួនម៉ែ ។ ម៉ែធ្វើព្រងើយពុំបានឡើយ ម៉ែត្រូវតែក្រោកស្ទុះទៅរកកូនភ្លាម ទៅបីត្រកងថ្នាក់ថ្នមកូនមកឱបនៅដើមទ្រូង ដែបបោសអង្អែល មាត់លួងលោមដោយសំដីទន់ផ្អែម ។ ម៉ែមិនខុសសោះ តែម៉ែធ្វើជាខុស ម៉ែជេរស្តីបន្ទោសផ្តែផ្តាតែផ្តាសទៅវិញ ឲ្យតែកូនបាត់មាត់លែងយំ ទើបម៉ែនៅជាប្រក្រតីបាន ។

បើជូនជាកូនឈឺ ម៉ែក៏ហាក់បីដូចជាឈឺជាមួយនឹងកូនដែរ ជួនកាល ម៉ែអត់ទ្រាំមិនបាន យំខ្សឹកខ្សួលអួលអាក់ទៀតផង ។ ពេលខ្លះ ម៉ែទៅបែរបន់ព្រះសំពះទេវតាសូមឲ្យលោកជួយកូនឲ្យឆាប់បានជាសះស្បើយ ។ មានកាលខ្លះ កូនស៊ីមិនបាន ម៉ែក៏ស៊ីមិនបានដែរ កូនដេកមិនលក់ ម៉ែក៏ដេកមិនលក់ដែរ កូនស្គាំងស្គម ចិត្តម៉ែក៏ស្គាំងស្គម ដូចជាកូនដែរ ។ ចិត្តម៉ែសង្រេងដូចជាមេអក បើសិនជាម៉ែអាចទទួលយកជំងឺកូនបាន ម៉ែសុខចិត្តទទួលយកមកឈឺជំនួសកូនទៅហើយ ម៉ែមិនចង់ឲ្យកូនឈឺសោះ ។ កូនឈឺម្តងៗ ម៉ែកើតទុក្ខធំ ដេកមិនលក់បក់មិនល្ហើយ ចិត្តម៉ែក្រៀមក្រំជានិច ព្រោះតែជីវិតកូនសំលាញ់ ។ ម៉ែចិញ្ចឹមកូន

www.elibraryofcambodia.org

ម៉ែព្យាបាលកូន ម៉ែបីបមថ្នាក់ថ្នមបបោសអង្អែលលួងលោមកូន ឲ្យកូនទៅបានសុខស្រួលមិនឲ្យរលកជន្លំចិត្តឡើយ ។

រឿងម៉ែចិញ្ចឹមបីបាច់ថែរក្សាកូននេះ មានសេចក្តីប្លែកៗពីគ្នាណាស់ អាស្រ័យទៅលើម៉ែមានទ្រព្យសម្បត្តិនិងម៉ែគ្មានទ្រព្យសម្បត្តិ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ការចិញ្ចឹមកូនសុទ្ធតែប្រកបដោយទឹកចិត្តដូចគ្នា ប្លែកគ្នាតែទ្រព្យសម្បត្តិប៉ុណ្ណោះ ។ ម៉ែគេអ្នកមានទ្រព្យសម្បត្តិអាចផ្គាប់កូនបានគ្រប់យ៉ាងតាមចិត្តចង់ ឯម៉ែដែលក្រីក្រវិញ ធ្វើមិនបានតាមចិត្តដែលកូនចង់នោះទេ ។ ម៉ែក្រីក្រមិនមានគ្រឿងស្លៀកពាក់ល្អ មិនមានអាហារល្អបរិភោគប្រកបដោយអនាម័យ មិនមានផ្ទះសម្បែងកន្លែងលំនៅបានសមរម្យ មិនមានថ្នាំឱសថវិសេសសម្រាប់ព្យាបាលថែរក្សារោគទេ ។ ម៉ែដែលមានជីវិតក្រីក្រ ចិញ្ចឹមជីវិតកូនតាមមានតាមបាន តែអស់ពីពោះពីពុង មិនមានលាក់លៀមទេ ម៉ែរងទុក្ខវេទនាខ្លាំងណាស់ ដូចជាពកូនដើររកស៊ីហាលថ្ងៃ ហាលខ្យល់ ហាលភ្លៀង ហាលក្តៅរងាជាដើម មិនថាយប់ មិនថាថ្ងៃ ។ ពេលក្តៅម៉ែគ្មានឆ័ត្របាំងយកដៃ

www.elibraryofcambodia.org

ម៉ែបាំងកូន ពេលរងា មិនមានភួយដណ្តប់ យកដៃឱបកូន ពេលដើររកស៊ីដៃម្ខាងពកូន ដៃម្ខាងទូលកញ្ចើ ។ មានពេលខ្លះម៉ែទូលកញ្ចើបណ្តើរ បំបៅកូនបណ្តើរ ម៉ែធ្វើគ្រប់បែបយ៉ាង ដើម្បីកូនឥតត្អូញត្អែរឡើយ ។ ពេលកូនឈឺម្តងៗ ម៉ែមិនមានថ្នាំវិសេសសម្រាប់ព្យាបាលកូនទេ ម៉ែប្រើថ្នាំតែផ្តេសផ្តាសតាមមានតាមបាន បើជួនជាទាល់គំនិត ម៉ែដុតធូបបន់ព្រះសំពះទេវតា សូមឲ្យលោកជួយឲ្យកូនម៉ែបានជាសះស្បើយពីរោគាពាធ ម៉ែក្រុងកូនក្នុងរង្វង់ដៃ ដូចសត្វក្រាបក្រុងកូនរបស់វាអញ្ចឹងដែរ ។ ទិដ្ឋភាពដូចនេះ មុខគួរឲ្យវេទនាណាស់ សំរាប់ជីវិតម៉ែដែលក្រីក្រ នៅតាមជនបទស្រុកស្រែចំការក្តី នៅតាមទីប្រជុំជនក្តី នៅតាមទីក្រុងក្តី សុទ្ធតែលំបាករកអ្វីមកប្រៀបផ្ទឹមគ្មានឡើយ ។ ទឹកចិត្តម៉ែឪគ្រប់គ្នា មិនមែនមានចិត្តអាក្រក់ចំពោះកូនទេ ម៉ែឪចង់បំពេញចិត្តកូនណាស់ តែធ្វើម្តេចបើម៉ែក្រីក្រគោកយ៉ាកយ៉ាងហ្នឹង ។ សេចក្តីក្រីក្រនេះហើយ ដែលជាមារមករារាំងចិត្តម៉ែឪ មិនឲ្យធូរស្រាលចិត្តសោះឡើយ ។ជីវិតម៉ែឪនៅតាមស្រែកស្រែចំការ សៀក

www.elibraryofcambodia.org

ពាក់មិនសូវបានល្អទេ ក្បាលទូលកញ្ជើ ដៃម្ខាងពកូន ដៃម្ខាងកាន់ខ្សែគោពីរបី ដើរទៅស្រែ ជួនកាលគោទាញទៅមុខទៅក្រោយ បើជួនជាមានភ្លៀងផង ទទឹកជោគទាំងកូនទាំងម៉ែ ពេលទៅដល់ស្រែ ម៉ែចងអង្រឹងឲ្យកូនដេក យោលបណ្តើធ្វើការបណ្តើរ ម៉ែមិនសូវបានមើលល្បែងកំប្លែងគ្រាន់លំហែរចិត្តនឹងគេទេ ។ ម៉ែអ្នកក្រីក្រទាំងឡាយ កាលបើឃើញកូនគេអ្នកមានទ្រព្យសម្បត្តិ មានជីវភាពខ្ពង់ខ្ពស់មានសម្លៀកបំពាក់ល្អ មានមាសពេជ្រពាក់ ស៊ីស្រួលដេកស្រួល តែងទឹកតូចចិត្តនឹងសំណាងខ្លួនឯងជានិច្ចថាហេតុអីក៏កើតមកមិនប្រឡូនឹងគេ ។

រឿងម៉ែចិញ្ចឹមកូនជារឿងវិចិត្រណាស់ និយាយមិនមានទីបំផុតទេ បើនិយាយកាត់ខ្លីពេក ហាក់ដូចជាកាត់ខ្លឹមសាររបស់ម៉ែអស់ តែបើនិយាយវែងហួសប្រមាណពេកក្រែងអ្នកផងនិយាយថាអួតហួសខ្នាតពេក ។ តែបើតាមការពិនិត្យអង្កេតមើលឲ្យគ្រប់ជ្រុងជ្រោយទៅឃើញថា ខ្លឹមសារនៃការទំនុកបំរុង ចិញ្ចឹមបីបាច់ថែរក្សារបស់ម៉ែ ពុំគ្មានទីបំផុតទេ ។ ព្រោះទឹកចិត្តរបស់គាត់ ដែលខិតខំចិញ្ចឹម

www.elibraryofcambodia.org

កូនគឺចង់ឲ្យកូនរស់ ឲ្យបានធាត់ធំ ទោះបីជាកូនកើតមកមានសភាពបែបយ៉ាងមនុស្សគថ្លង់ ខ្វាក់ខ្វិនខ្វង់ វិកលវិការយ៉ាងណាក៏ដោយ ក៏ម៉ែនៅតែខិតខំថែរក្សា ចិញ្ចឹមបីបាច់ឲ្យបានធាត់ធំដូចកូនគេដទៃទៀតដែរ ។ ព្រោះគោលបំណងរបស់ម៉ែមានតែមួយគត់ គឺធ្វើយ៉ាងណា ឲ្យតែកូនរស់ ធំធាត់ប្រកបដោយសុខភាពបរិបូណ៌ កំលាំងពលំមាំមួនតែប៉ុណ្ណោះ មិនគិតខាតបង់ មិនគិតនឿយហត់អ្វីទាំងអស់នេះហើយទឹកចិត្តម៉ែដែលស្រលាញ់កូន ។

មិនតែប៉ុណ្ណោះសោត កាលបើកូនចេះនិយាយហើយ ម៉ែឪតែងតែបង្រៀនប្រៀនប្រដៅកូន ឲ្យចេះភាសាជាតិរបស់ខ្លួន បង្រៀនឲ្យចេះហៅឪ ហៅម៉ែ ហៅយាយតាមីងមាបងប្អូន ហៅអ្វីៗ ដែលនៅក្បែរខ្លួន ដូចជាហៅគោ ក្របីដី សេះ ផ្ទះ ដើមឈើ ថ្ងៃខែឆ្នាំជាដើម ។ បង្រៀនឲ្យចេះដឹងថ្ងៃខែឆ្នាំកំណើតរបស់កូន បង្រៀនហើយប្រាប់ឲ្យកូនត្រាប់ថាតាម ។ ឯការបង្រៀននេះសោត ច្រើនតែម្តាយជាអ្នកបង្រៀនដោយផ្ទាល់ ចំណែកឪពុកមិនសូវជាមានពេលវេលាក្នុងការបង្រៀនកូនទេ ដោយសារកិច្ចការ

www.elibraryofcambodia.org

ងារមមាញឹក ឬក៏ជាប់រវល់ក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ បើម៉ែបង្គាប់ឲ្យកូនធ្វើតាម ហើយកូនធ្វើតាមបាន ម៉ែត្រេកអរណាស់ ។ បើមានបងប្អូនមកលេង ម៉ែប្រឡងកូនល្បងមើល ម៉ែសូមឲ្យបងប្អូនសួរថា នាងឈ្មោះអ្វី កើតឆ្នាំអ្វី? ខែអ្វី? ថ្ងៃអ្វី? ជាដើម បើកូនម៉ែឆ្លើយត្រូវ ម៉ែអរទឹបរខុបរីកកាយសប្បាយចិត្តឥតឧបមា ហើយម៉ែអួតប្រាប់គេឯងថា កូនម៉ែមានប្រាជ្ញាឆ្លាតណាស់ ។

ក្នុងការបង្រៀននេះ មិនមែនត្រឹមតែបង្រៀនភាសាប៉ុណ្ណោះទេ ម៉ែឪបង្រៀនទាំងសណ្តាប់ធ្នាប់ របៀបរៀបរយសុជីវធម៌ សីលធម៌ ចរិយាធម៌ ដូចជាការបង្រៀនឲ្យចេះលើកដៃសំពះយាយតា មាមីង បងប្អូន ឬក្រាបសំពះភិក្ខុសាមណេរជាដើម ។ ថែមទាំងបង្រៀនឲ្យចេះស៊ី ឲ្យចេះដើរ ឲ្យដឹងទាបខ្ពស់ ឲ្យចេះស្គាល់ចាស់ទុំ ឲ្យចេះដឹងបន្តិចៗទៅដរាបដល់កូនធំបោះឡើង ល្មមទៅរៀននៅសាលា ឬទៅរៀននៅវត្ត ។ ការណ៍ទាំងអស់នេះ ម៉ែឪប្រើវិធីគ្រប់យ៉ាងបណ្តោយតាមចិត្តកូនខ្លះ បញ្ចោរកូនខ្លះ យកចិត្តកូនខ្លះផ្លួលកូនខ្លះ ឲ្យបំណាច់ផ្ញើនខ្លះ តាំឡើងទឹកចិត្តខ្លះ តាមតែ

www.elibraryofcambodia.org

ការគួរ ឲ្យតែកូនបានបេះ បានទៅជាមនុស្សល្អ មនុស្សប្រសើរ មានចរិយាខ្ពង់ខ្ពស់ ។ ជួនកាលម៉ែឪប្រើវិធីក្ដៅខ្លះដែរ ប្រសិនបើមើលឃើញថា កូនមិនព្រមស្ដាប់បង្គាប់ គឺប្រើវិធីកំញើញ បង្ខិតបង្ខំដោយពាក្យសម្ដី តែអាការទាំងអស់នេះ គ្រាន់តែជាអាការៈខាងក្រៅទេ គឺស្ដីតែមាត់តែចិត្តមិនទេ ចិត្តម៉ែឪនៅតែមានមេត្តាដរាប ។ ពេលណាម៉ែឪជ្រុលជេរ ឬវាយបន្ទិចបន្ទួចម្ដងម្កាល ចិត្តម៉ែឪឈឺផ្សាអន់ស្រពន់ទោទន់ទៅរកកូន ទឹកអាណិតអាសូរកូនខ្លោចចិត្ត ជួនកាលដល់ទៅស្រក់ទឹកភ្នែកផងក៏សឹងមាន ។ សេចក្ដីនេះសបញ្ជាក់ឲ្យឃើញថា កាយវាចាក្ដី ចិត្តក្ដី ការជេរស្ដីក្ដី ការវាយក្ដី សុទ្ធតែជាកាយវិការដែលម៉ែឪអប់រំកូនឲ្យបេះដឹងគួរសម ឲ្យបេះគោរពចាស់ទុំជាដើម ហើយកាយវិការទាំងអស់នេះ ជាកាយវិការប្រកបទៅដោយព្រហ្មវិហារធម៌ មានមេត្តាជាដើម ។

៧ ការបង្ហាត់បង្រៀន និងការថែរក្សារបស់ម៉ែឪមិនមែនតិចឆ្នាំទេ ឃើញថាច្រើនឆ្នាំណាស់ ដរាបដល់កូនអាយុប្រាំ ឬប្រាំមួយឆ្នាំ មានសាលាតែរឹងបឹងលម្មទៅរៀនវិជ្ជាកើត ទើប

www.elibraryofcambodia.org

ងាររមមាញឹក ឬក៏ជាប់រវល់ក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ បើម៉ែបង្គាប់ឲ្យកូនធ្វើតាម ហើយកូនធ្វើតាមបាន ម៉ែត្រេកអរណាស់ ។ បើមានបងប្អូនមកលេង ម៉ែប្រឡងកូនល្បងមើល ម៉ែសូមឲ្យបងប្អូនសួរថា នាងឈ្មោះអ្វី កើតឆ្នាំអ្វី? ខែអ្វី? ថ្ងៃអ្វី? ជាដើម បើកូនម៉ែឆ្លើយត្រូវ ម៉ែអរទេវបរខុបរីកកាយសប្បាយចិត្តឥតឧបមា ហើយម៉ែអួតប្រាប់គេឯងថា កូនម៉ែមានប្រាជ្ញាឆ្លាតណាស់ ។

ក្នុងការបង្រៀននេះ មិនមែនត្រឹមតែបង្រៀនភាសាប៉ុណ្ណឹងទេ ម៉ែឪបង្រៀនទាំងសណ្តាប់ធ្នាប់ របៀបរៀបរយសុជីវធម៌ សីលធម៌ ចរិយាធម៌ ដូចជាការបង្រៀនឲ្យចេះលើកដៃសំពះយាយតា មាមីង បងប្អូន ឬក្រាបសំពះភិក្ខុសាមណេរជាដើម ។ ថែមទាំងបង្រៀនឲ្យចេះស៊ី ឲ្យចេះដើរ ឲ្យដឹងទាបខ្ពស់ ឲ្យចេះស្គាល់ចាស់ទុំ ឲ្យចេះដឹងបន្តិចៗទៅដរាបដល់កូនធំបោះឡើង ល្មមទៅរៀនទៅសាលា ឬទៅរៀននៅវត្ត ។ ការណ៍ទាំងអស់នេះ ម៉ែឪប្រើវិធីគ្រប់យ៉ាងបណ្តោយតាមចិត្តកូនខ្លះ បញ្ជោរកូនខ្លះ យកចិត្តកូនខ្លះ ជួលកូនខ្លះ ឲ្យបំណាច់រង្វាន់ខ្លះ តំឡើងទឹកចិត្តខ្លះ តាមតែ

www.elibraryofcambodia.org

ការគួរ ឲ្យតែកូនបានចេះ បានទៅជាមនុស្សល្អ មនុស្សប្រសើរ មានចរិយាខ្ពង់ខ្ពស់ ។ ជួនកាលម៉ែឪប្រើវិធីក្ដៅខ្លះដែរ ប្រសិនបើមើលឃើញថា កូនមិនព្រមស្ដាប់បង្គាប់ គឺប្រើវិធីកំហឹញ បង្ខិតបង្ខំដោយពាក្យសម្ដី តែអាការទាំងអស់នេះ គ្រាន់តែជាអាការៈខាងក្រៅទេ គឺស្ដីតែមាត់តែចិត្តមិនទេ ចិត្តម៉ែឪនៅតែមានមេត្តាដរាប ។ ពេលណាម៉ែឪជ្រុលដៃរ ឬវាយបន្ដិចបន្ដួចម្ដងម្កាល ចិត្តម៉ែឪឈឺផ្សាអន់ស្រពន់ទោទន់ទៅរកកូន ទឹកអាណិតអាសូរកូនខ្លោចចិត្ត ជួនកាលដល់ទៅស្រក់ទឹកភ្នែកផងក៏សឹងមាន ។ សេចក្ដីនេះសបញ្ជាក់ឲ្យឃើញថា កាយវាចាក្ដី ចិត្តក្ដី ការជេរស្ដីក្ដី ការវាយក្ដី សុទ្ធតែជាកាយវិការដែលម៉ែឪអប់រំកូនឲ្យចេះដឹងគួរសម ឲ្យចេះគោរពចាស់ទុំជាដើម ហើយកាយវិការទាំងអស់នេះ ជាកាយវិការប្រកបទៅដោយព្រហ្មវិហារធម៌ មានមេត្តាជាដើម ។

ការបង្ហាត់បង្រៀន និងការថែរក្សារបស់ម៉ែឪមិនមែនតិចឆ្នាំទេ ឃើញថាច្រើនឆ្នាំណាស់ ដរាបដល់កូនអាយុប្រាំ ឬប្រាំមួយឆ្នាំ មានស្មារតីរឹងប៉ឹងល្មមទៅរៀនវិជ្ជាកើត ទើប

www.elibraryofcambodia.org

រៀបចំគ្រឿងសិក្ខុបករណ៍មានក្តារឈ្នួន ដីសជាដើម នាំកូនទៅចូលសាលារៀន ។ មុននឹងឲ្យកូនទៅរៀននោះ ម៉ែឪខំផ្សាំចិត្តគំនិតកូន ក្នុងការសិក្សាជាច្រើនខែ មានបង្ហាត់បង្រៀនឲ្យចេះសរសេរ ចេះរាប់ខ្ទះៗ និងនិយាយសម្រួលចិត្តកូនឲ្យមានបំណងចង់សិក្សា ដោយពន្យល់ហេតុផលនៃចំណេះវិជ្ជា កាត់សម្លៀកបំពាក់ឲ្យ និងឲ្យរបស់អ្វីៗ ជាគ្រឿងលើកទឹកចិត្តថែមទៀតផង ។

ថ្ងៃចូលរៀន ម៉ែឪជូនកូនទៅប្រគល់ជូនលោកគ្រូអ្នកគ្រូ ឬព្រះសង្ឃ ដែលជាគ្រូអាចារ្យ បើកូនមានចិត្តក្លាហានក្នុងការរៀនសូត្រ មិនយំតាមមកផ្ទះវិញ ម៉ែឪសែនសប្បាយចិត្តណាស់ ហាក់ដូចជាកូនចេះវិជ្ជាស្រេចទៅហើយ បើកូនមិនចង់រៀន យំតាមមកផ្ទះ ឬគេចសាលានោះ ម៉ែឪតឹងទ្រូងស្ទើរប្រេះ ហាក់ដូចជាអស់សង្ឃឹមថាកូននឹងបានទៅជាអ្នកចេះដឹងនឹងគេ ។

តាំងពីកូនចូលរៀនមក ម៉ែឪក៏ហាក់ដូចជាចូលរៀនជាមួយនឹងកូនដែរ ពេលម៉ោងចូលរៀនជូនកូនទៅ ពេលម៉ោងចេញពីរៀនទៅទទួលកូន មួយថ្ងៃៗបីបួនដង ។ ម៉ែឪ

www.elibraryofcambodia.org

ធ្វើដូច្នេះជាច្រើនឆ្នាំ ទំរាំកូនធំដឹងក្តីអាចទៅរៀនដោយខ្លួនឯងបាន ទើបហ៊ានបណ្តោយ ព្រោះខ្លាចទៅតាមផ្លូវមានសត្វសាហាវខាំ ឬមានគ្រោះថ្នាក់ផ្សេងៗ ដោយប្រការណាមួយ ។

ករណីយកិច្ចម៉ែឪចំពោះកូនក្នុងការសិក្សា មិនមែនចប់ត្រឹមជូនកូនទៅសាលារៀនប៉ុណ្ណោះទេ ពេលកូនត្រឡប់មកពីសាលាវិញ ខំពិនិត្យសាកសួរ តើគ្រូឲ្យរៀនពីអ្វីខ្លះ បើកូនមិនទាន់យល់ជួយបង្ហាត់ពន្យល់ថែមទៀត ដាស់តឿនកូនឲ្យខំរៀន ខំទន្ទេញ ឲ្យបានយល់ចេះចាំ កុំឲ្យគ្រូស្តីបន្ទោស ។ ពេលយប់ដេកមិនលក់ទេ ចាំដល់កូនឈប់រៀនដេកលក់ លបទៅមើលកូន ក្រែងដេកមិនបានជណ្តប់ ឬដេកប្រឆេងប្រឆាង រៀបចំជណ្តប់ឲ្យ ទើបម៉ែឪធ្មេចភ្នែកដេកលក់បាន ។ ឯថេរវេលាដែលម៉ែឪឲ្យកូនសិក្សារៀនសូត្រចំណេះវិជ្ជានេះ មិនមែនខ្លីទេ ចំនួនដប់ឆ្នាំឯណោះ តាំងពីកូននៅកុមារកុមារី រហូតដល់ពេញកំឡោះក្រមុំ បើកូនរៀនពូកែ ចេះតែឲ្យរៀនតទៅទៀត ហើយរ៉ាប់រងទំនុកបំរុងគ្រឿងសិក្ខូបករណ៍ គ្រប់បែបយ៉ាងទាំងអស់ តាំងពី

www.elibraryofcambodia.org

សម្លៀកបំពាក់ ប្រដាប់ប្រដារៀនសូត្រ ចំណីអាហារ លុយកាក់ប្រាក់កាសជាដើម ។

ពេលកូនប្រឡងម្ដងៗ ជួនកាលម៉ែឪដុតធូបបែបន់ព្រះសំពះទេវតា បួងសួងសុំឲ្យលោកជួយកូនឲ្យបានប្រឡងជាប់ បើបានជាប់មែនម៉ែឪសប្បាយចិត្តណាស់ អួតសរសើរ ឲ្យរង្វាន់លើកទឹកចិត្តកូន ឲ្យខំរៀនថែមទៀត តែបើបែជាធ្លាក់វិញ ម៉ែឪព្រួយចិត្តក្រៃលែង ក្រែងកូនខូចចិត្តទញ់ត្អូញគំនិត ខំនិយាយលួងលោមឲ្យកូនបានក្សេមក្សាន្តចិត្តខំប្រឹងរៀនតទៅទៀត ។

ក្នុងការអប់រំកូននេះសោតទៀត ជីដូនជីតាក៏មានការជួយរំលែកភារៈម៉ែឪខ្លះដែរ មានឱកាសទំនេរ ជីដូនជីតានាំនិទានផ្សេងៗ ជាគតិលោក ជាគតិធម៌ រឿងព្រេងនាយរឿងបច្ចុប្បន្ន រឿងកំសាន្ត រឿងត្លុកកំប្លែង រឿងដែលនាំឲ្យកើតគំនិតប្រាជ្ញា មកឲ្យចៅស្ដាប់ជាការកំសាន្តផង ជាប្រយោជន៍ឲ្យចៅយកតម្រាប់តាមផង ។ ពេលមានបុណ្យទានប្រចាំឆ្នាំនៅវត្តម្ដងៗ ជីដូនជីតាម៉ែឪតែងនាំកូនចៅទៅលេងវត្ត ទៅដល់ហើយ នាំកូនទៅក្រាបសំពះព្រះសង្ឃ

www.elibraryofcambodia.org

ព្រះពុទ្ធរូប ហើយស្ដាប់ព្រះសង្ឃចំរើនព្រះបរិត្តជាពុទ្ធជ័យមង្គល ស្ដាប់ព្រះធម៌ទេសនាជាដើម ។ ជួនកាលជីដូនជីតាដែលមានការចេះដឹងខាងផ្លូវលោកផ្លូវធម៌ច្រើន ជួយពន្យល់កូនចៅថែមទៀត ដើម្បីឲ្យយល់សេចក្ដី ដោយមានបំណងចង់ឲ្យកូនចៅប្រព្រឹត្តតាមចរិយាព្រះពុទ្ធ ដែលជាហេតុនាំឲ្យធ្វើត្រាប់តាម និងបានទៅជាអ្នកប្រសើរនៅនាលោកិយនេះ ។ បើឃើញថា កូនមានចរិយាមិនល្អវិញ ម៉ែឪសែនចំបែងចិត្តស្ទើរប្រេះទ្រូង ម្លោះហើយ ម៉ែឪប្រើវិធីគ្រប់យ៉ាងវិធីក្ដៅខ្លះ ត្រជាក់ខ្លះ អង្វរករខ្លះ ឬពឹងពាក់អ្នកចេះដឹងឲ្យជួយទូន្មានប្រៀនប្រដៅ បើឃើញថាកូនមានចរិយាល្អហើយចេះដឹងគួរសមស្គាល់ចាស់ទុំ ចេះឱនលំទោន ចេះស្គាល់ល្អអាក្រក់ មានប្រាជ្ញាភ្លៀវក្លាមោះមុត រៀនសូត្រឆាប់ចាំឆាប់ចេះ មានកេរ្តិ៍ឈ្មោះល្អ មានគេឯងស្រលាញ់រាប់អានច្រើន ម៉ែឪសប្បាយចិត្តឥតគណនា ។ បើម៉ែឪចេះដឹងថា បែបបទណាល្អ ម៉ែឪបង្រៀនប្រដៅកូនភ្លាម ម៉ែឪតែងតែប្រដៅថា កូនអើយ ! ចូរកូនធ្វើយ៉ាងនេះទើបបានជាកូនល្អ គរគេគោរពស្រលាញ់រាប់អានច្រើន ។

www.elibraryofcambodia.org

ដល់ពេលកូនធំពេញកំឡោះក្រមុំ ត្រូវទៅបំពេញវិជ្ជាជាន់ខ្ពស់នៅទីឆ្ងាយពីខ្លួន មាននៅទីក្រុងឬនៅបរទេសជាដើម ម៉ែឪគិតគូច្រើនណាស់ និយាយទូន្មានផ្តែផ្តាំកូនសព្វយ៉ាង ឲ្យកូនបានស្ថិតនៅក្នុងសេចក្តីថ្លៃថ្នូ តាមគតិបណ្ឌិត និងរៀបចំប្រដាប់ប្រដាសំលៀកបំពាក់ អាហារូបករណ៍ជាដើម ជូនដំណើរកូនទៅផ្ញើទុកដាក់ឲ្យអ្នកដែលកូនត្រូវស្នាក់អាស្រ័យជាមួយ ។

ពេលត្រឡប់ពីជូនកូនមកផ្ទះវិញ ម៉ែឪអាឡោះអាល័យណាស់ មិនចង់ឲ្យកូនឃ្លាតផុតពីរង្វង់ចក្ខុទេ ទោះពេញកំឡោះក្រមុំហើយក៏ដោយ ក្រែងមិនបានសុខស្រួល ដូចជានៅក្នុងការគ្រប់គ្រងរក្សារបស់ខ្លួន ។ មានម៉ែឪខ្លះអាឡោះអាល័យកូនខ្លាំងពេក រហូតដល់ស្រក់ទឹកភ្នែកក៏មានដែរ ។

តែមានកូនខ្លះ គ្មានទឹកយើញដល់រឿងនេះទេ បានធំខ្លួនពេញកំឡោះក្រមុំហើយ ក៏គិតតែភ្លើតភ្លើនក្នុងអំពើពាលាអាវ៉ាបាសែ តាមមិត្តពាលម្សៀត ម៉ែឪបញ្ជូនឲ្យទៅរៀនវិជ្ជា គិតតែពីស្នេហា ស៊ីផឹក ដើរលេងសប្បាយហើយកុហកបោកបញ្ឆោតម៉ែឪ ដែលជាព្រះបង្កើត

www.elibraryofcambodia.org

ក្បាលខ្លួន ដោយយកការរៀនសូត្រមកធ្វើជាខែលបាំងមុខ លំអុកសុំលុយកាក់ម៉ែឪថាយកទៅរៀន ឯម៉ែឪវិញមិនឲ្យកូនសុំធូនមាត់ទេ ខំខ្វះកកាយពីទូហិបឲ្យកូន បើមិនគ្រប់គ្រាន់តាមចំនួនដែលសុំទេ ស៊ីបួរលក់បញ្ចាំកេរ្តិ៍កោះស្រែចំការយកប្រាក់មកឲ្យកូនទៀត ។ ឯអាកូនចង្រៃ កូនអកញ្ញូ កូនបកស្បែកម៉ែឪលក់ ដល់បានប្រាក់ហើយ យកទៅហ៊ឺហា ទិញខោអាវស្បែកជើងទឹកអប់ស្អិតស្អាងខ្លួន ដើម្បីដើរចង់ស្រី យកប្រាក់ដែលកើតពីញើសឈាមម៉ែឪ ទៅចិញ្ចឹមស្រីឯណោះវិញព្រងើយ ។

ចំណែកម៉ែឪនឹកសង្ឃឹមថា កូនបានប្រាក់ទៅមុខជាខំរៀនសូត្រហើយ ដល់កូនទៅផុត ខំអុចធូបបន់ព្រះសំពះទេវតា ឲ្យពរកូន ឲ្យបានរៀនចេះដឹងប្រឡងជាប់ តើព្រះឯណាហ៊ានជួយទៀត បើកូនអកតញ្ញូ បោកបញ្ឆោតម៉ែឪ ដែលបង្កើតក្បាលខ្លួនទៅហើយនោះ ។

ម៉ែឪកាលបើបានដឹងថាកូនប្រព្រឹត្តដូច្នោះ ព្រួយចិត្តណាស់ សេចក្តីសង្ឃឹមទាំងប៉ុន្មាន ត្រូវរលត់អស់ អាម៉ាស់មុខខ្មាសញាតិមិត្តជិតខាង តែទោះបីជាយ៉ាងណាក៏ដោយ

www.elibraryofcambodia.org

ក៏ម៉ែឪមិនចោលកូនដដែល ព្រោះមិនទាន់អស់ចិត្តពីកូនទេ ខិតខំរកមធ្យោបាយអប់រំកូនទៀត ក្រែងកូនកែខ្លួនបានល្អឡើងវិញ ។

នេះហើយជាកស្តុតាង និងហឫទ័យប្រកបដោយព្រហ្មវិហារធម៌ដ៏បរិសុទ្ធស្អាតរបស់ម៉ែឪ ដែលប្រោះព្រំទៅលើកូនគ្មានរើសមុខ ទោះបីជាកូនល្អក្តី អាក្រក់ក្តី ខ្វិនខ្វាក់ក្តី គថ្លង់ក្តី ឆ្កួតលីលាដូចម្តេចក្តី ក៏សុទ្ធតែជាកូនសំលាញ់បណ្តូលចិត្តម៉ែឪទាំងអស់ ។ ឧបមាបីដូចជាទឹកភ្លៀង ដែលធ្លាក់ចុះពីលើអាកាសមកលើផែនដី មិនរើសថាទីល្អអាក្រក់ ទាបខ្ពស់ទេ តែងតែធ្លាក់ស្រោចស្រប់ប្រោះព្រំស្មើគ្នាទាំងអស់គ្រប់ទីស្ថាន ។

កាលកូនធំពេញកំលោះក្រមុំ ចេះដឹងគួរសមហើយ គួរតែម៉ែឪស្រាលការៈបន្តិច តែមិនដូច្នោះទេ ម៉ែឪនៅតែប្រុងប្រយ័ត្នជានិច្ច មិនបណ្តែតបណ្តោយឲ្យកូនកើតកើនទៅតាមកាមារម្មណ៍ គឺអំពើអមនុស្សធម៌ស៊ី ឬដុះចាក់ទូវចិត្តគំនិតចរិយាមាយាទកូនទេ តែតែមានការៈធ្ងន់ៗ ក្នុងការគ្រប់គ្រងរក្សាអប់រំ ដុសខាត់ចិត្តគំនិតមារយាទ ច្រើន

www.elibraryofcambodia.org

ប្រការទៀត ព្រោះកូនធំហើយ ចិត្តគំនិតក៏ធំដែរ ប្លែកពីកុមារកុមារី មានសរសៃវិញ្ញាណក្លាហាន អាចទាញគំនិតចរិយាមារយាទ ឲ្យលង់លុះទៅក្នុងអបាយមុខមានស្រីស្រា ល្បែងភ្នាល់ ដែលជាប្រភពឲ្យកើតអមនុស្សធម៌គ្រប់យ៉ាង មានលួចប្លន់ ចាក់កាប់ កុហកឆបោកជាដើម ដែលជាហេតុនាំឲ្យ អាប់ឱនកេរ្តិ៍ឈ្មោះបោះសំឡេង វង្សត្រកូល ។

កាលនៅពីតូច ម៉ែឪនឿយព្រួយលំបាករញ៉ិករញ៉ុកទាំងយប់ទាំងថ្ងៃមែន តែទុកដូចជាការយល់សប្តិទេ គ្រាន់តែកូនញញឹមរកបន្តិចបន្តួច ក៏ភ្លេចទុក្ខព្រួយនោះអស់ទៅហើយ ឯកូនធំពេញកំឡោះក្រមុំ មិនស្តាប់ប្រកបដោយគន្លងធម៌នោះ ទើបកើតទុក្ខធំ ធំជាប់មិនរសាយ ស៊ីមិនបានដេកមិនលក់ បក់មិនរហើយ អាម៉ាស់មុខ ដូចគេទទូរស្បែកថ្ពក ឬដូចជាគេយកភ្លើងមកដុតក្នុងចិត្តម៉ែ ។

ពេលថ្ងៃឬយប់ កាលបើឃើញកូនចេញដើរទៅណាមកណា ខុសកាលវេលា ទឹកមុខម៉ែមិនស្រស់ នៅមិនសុខដេកមិនលក់ ស៊ូទ្រាំចាំទ្វារ បើហួសពេលធម្មតា ខំបើកទ្វារ

www.elibraryofcambodia.org

បណ្ដុចអើតមើលផ្លូវកូន សំឡឹងមើលស្ទើរជ្រុះគ្រាប់ភ្នែក ត្រចៀកទាំងគូរប្រឹងស្ដាប់ ឮអស់ហើយសម្លេងសូរស័ព្ទអ្វីៗ ចំណែកខាងអារម្មណ៍ ខំប្រឹងជ្រើសរើសរាវរកសម្លេងកូន បើជួនជាឮថា មានគេឈ្លោះទាស់ទែងគ្នា ឬមានហេតុអន្តរាយផ្សេងៗនោះ ម៉ែឪតក់ស្លុតស្មារតីអស់ ទុក្ខព្រួយអន្ទះសារ ដូចមាន់រកពង ភ័យក្រែងកូនទៅជួបនឹងហេតុអន្តរាយនោះៗ បើទុកជាចាស់ជរាភ្នែកងងឹតហើយក៏ស្ទុះទៅរកកូន ឬក៏ពឹងពាក់គេឯងឲ្យទៅរកជំនួស លុះតែកូនបានមកដល់ផ្ទះវិញទើបធ្មេចភ្នែកជិត ។

ឯកូនប្រុស និងកូនស្រីទាំងពីរពួកនេះ ដែលពេញកំឡោះក្រមុំហើយ ម៉ែឪព្រួយថែរក្សាដូចគ្នា គ្មានលើសខ្វះទេ ព្រោះភេទស្រី ធម្មជាតិតាក់តែងមកឲ្យ ប្រកបដោយធាតុទន់ខ្សោយ ហើយច្រើនសុភាពទាំងចិត្តគំនិត និងកាយវិការ មិនរឡេមរឡាមដើរលេងមានមិត្តភក្ត្រ ជ្រួលជ្រើមក្នុងអបាយមុខស៊ីផឹក កាប់ចាក់ជាដើម ដូចភេទប្រុសទេ ព្រួយធំតែម្យ៉ាង ក្រែងកូនមិនចេះថែរក្សាព្រហ្មចារី ដែលជាហេតុនាំឲ្យខូចអនាគតខ្លួន និងថោកទាបដល់វង្សត្រកូល ។

www.elibraryofcambodia.org

ប៉ុន្តែម៉ែឪមិនហាមប្រាមឃាត់បិទសិទ្ធកូន មិនឲ្យទាក់ទងនិងបុរសកំឡោះនោះទេ គឺបើកឲ្យមានសេរីភាពចំពោះមនុស្សលោកទូទៅគ្រប់ប្រភេទ ដូចជាឲ្យទៅរៀនវិជ្ជា ឲ្យធ្វើជាអ្នកកីឡាករ និងធ្វើការនៅក្នុងក្រសួងនានាជាដើម ដោយសេរី ទាំងមិនហាមឃាត់សេចក្តីស្នេហារបស់កូនទៀត ។ ព្រោះការទាក់ទងរាប់អាន និងសេចក្តីស្នេហា ជាការចាំបាច់របស់មនុស្សលោក កុំឲ្យតែប្រព្រឹត្តកន្លងប្រពៃណី ខូចព្រហ្មចារី ដែលប្រពៃណីតែងតែតិះដៀលប៉ុណ្ណោះ ។ ឯវិជ្ជានិងការងារទាំងឡាយ មិនមែននាំឲ្យខូចព្រហ្មចារីស្ត្រីទេ គឺជាជំនួយយ៉ាងសំខាន់ អាចឲ្យស្ត្រីស្គាល់តម្លៃខ្លួនឯង ចេះរក្សាព្រហ្មចារីឲ្យបានបរិសុទ្ធ មិនចោតល្ងង់ចាញ់បោកប្រុសព្រាន ។ ឯគំនិតមាយាទ គ្មានសិល្បៈ គ្មានចំណេះវិជ្ជា ចោតល្ងង់នោះទេតើ ដែលនាំឲ្យខូចព្រហ្មចារីរបស់ស្ត្រីទាំងឡាយ ។ ឧទាហរណ៍ ដូចជាស្រីក្រមុំជំនាន់ដើម ដែលគ្មានការសិក្សា ម៉ែឪមិនហ៊ានបណ្តោយឲ្យទៅណាទេ ឃុំទុកតែក្នុងផ្ទះ បើទៅណាម្តងម្កាល ទាល់តែមានមនុស្សបណ្តើរម្នាក់ ឬពីរនាក់ទើបទៅ

www.elibraryofcambodia.org

បាន ខ្ទាចក្រែងកូនចោតល្ងង់ បើកដៃឲ្យប្រុសឈ្មោល បោកបញ្ឆោតមើលងាយ ។ ឯសព្វថ្ងៃនេះ ក៏ដូច្នោះដែរ បើស្រីក្រមុំណាគ្មានការសិក្សា ឬសិក្សាហើយ តែមិនបានចេះដឹងនៅល្ងង់ខ្លៅ ក៏ម៉ែឪមិនសូវហ៊ានបើកសិទ្ធឲ្យរួចពីការឃុំឃាំង និងការបណ្ដឹរនោះដែរ បើទុកជាហួសសម័យកុំព្យូទ័រនេះទៅមុខទៀត ក៏ត្រូវតែធ្វើដូច្នេះ ព្រោះស្រីក្រមុំដែលខ្វះការសិក្សា គ្មានសិល្បៈក្នុងគំនិត ប្រៀបដូចជាមាសពេជ្រដែលនៅកណ្ដាលវាលក្រៅផ្ទះ ចោរអាចលួចប្លន់បានដោយងាយ អនាគត និងវង្សត្រកូលរបស់ស្រីនោះក៏វិនាសអាប់ឱនទៅដោយងាយដែរ ។

អាស្រ័យហេតុនេះ ទើបម៉ែឪខំប្រៀនប្រដៅ ពន្យល់អប់រំកូនស្រីឲ្យចេះថែរក្សាខ្លួន និងប្រាប់ឲ្យដឹងថា ស្រីក្រមុំទាំងឡាយ បើចេះថែរក្សាព្រហ្មចារីរបស់ខ្លួនឲ្យបានបរិសុទ្ធទើបមានតម្លៃដូចពេជ្រទាំងគ្រាប់ ឬដូចមាសទឹកដប់ មានសិរីសួស្ដី មានឫទ្ធានុភាព អាចផ្ចាញ់សត្រូវ គឺបុរសខ្សែះខ្សោះបានគ្រប់ទិសទី ឲ្យបាក់បបខ្វបខ្វាច សូម្បីតែពពួកទេព្ដាក៏សរសើរ ឲ្យពរជ័យដែរ ។ ព្រហ្មចារីនេះហើយ ជា

www.elibraryofcambodia.org

ជូនព្រលឹងរបស់ស្រីក្រមុំ ជាកំណាប់ទ្រព្យ និងជាយីហោរបស់ស្ត្រីក្នុងលោក បើព្រហ្មចារីវិនាសទៅដោយខុសគន្លងប្រពៃណីហើយ ជីវិតរបស់ស្រីនោះ ក៏ឈ្មោះថាបាត់បង់ទៅដែរ សិរីសួស្ដីគ្រប់ជំពូក ក៏រលត់រលាយទៅដែរ ទេព្ដាស្អប់ខ្ពើម តែងផ្ដន្ទាទោសគ្រប់ពេល សត្រូវហ៊ានមើលងាយគ្រប់ទិសទី ។

ស្ត្រីក្រមុំ ដែលគ្មានការតស៊ូរក្សាព្រហ្មចារីរបស់ខ្លួនឲ្យបានគង់វង្សឈ្មោះថាស្លាប់ទាំងរស់ ស្អុយទាំងស្រស់ទៅទីណាមានរុយក្បាលខៀវ គឺប្រុសពាលាតាមញាំញីគ្រប់ទិសទី ស្ត្រីនោះបើទុកជាស្លៀកពាក់សំពត់ហូលព្រៃបួនដប់ជាន់ រចនាដោយមាសពេជ្រយ៉ាងណា ក៏ទុកដូចជាស្រាតលែងខ្លួនទទេទៅចំពោះមុខមហាជនដែរ ។ ទំនៀមទំលាប់ប្រពៃណីពីបុរាណកាលមក លោកសន្មត់ទុកស្ត្រីនោះជាញី ថោកទាបដូចសត្តិរច្ឆាន ។

អាស្រ័យហេតុនេះហើយ ស្ត្រីក្រមុំទាំងឡាយ គួរតែស្គាល់សិទ្ធ មហាអំណាចរបស់ខ្លួន ដែលជាម្ចាស់ជីវិត នៃសេចក្ដីស្នេហារបស់ប្រុសក្នុងលោក ចម្លងសេចក្ដីស្នេហា

www.elibraryofcambodia.org

របស់បុរស លុះតែស្ត្រីដាក់ទានឲ្យទើបមានជីវិត មានសកម្មភាពឡើងបាន បើគ្មានការដាក់ទានពីស្ត្រីផងទេ នោះសេចក្តីស្នេហារបស់បុរសក៏គ្មានដែរ ។

ស្រីក្រមុំនេះហើយ ជារាជិនីនៃសេចក្តីស្នេហារបស់មនុស្សលោកគ្រប់រូប សោយរាជ្យក្នុងនគរកាមទេព មានឫទ្ធានុភាពធំអស្ចារ្យ ជាស្តេចចក្រពត្រាធិរាជកាន់អំណាចផ្តាច់ការខាងស្នេហាបានគ្រប់យ៉ាងទាំងអស់ គ្មានបុរសណាអាចច្បាំងយកជ័យជំនះបានទេ ។ម្យ៉ាងទៀតស្ត្រីលោកទុកជាកូនសោរនៃសេចក្តីស្នេហារបស់បុរស បើស្ត្រីចាក់សោរជិត កាន់កូនសោរជាប់នៅដៃហើយ សូម្បីបុរសក្នុងពិភពលោកទាំងមូល ដែលប្រដាប់ដោយអាវុធបរមាណូនាំគ្នាមកច្បាំងដណ្តើមយកស្នេហានេះ ក៏មិនបានដែរ លុះតែស្ត្រីឲ្យដៃ ទើបប្រុសហ៊ានចូលក្នុងព្រំដែនស្នេហាបាន ដូចសុភាសិតលោកពោលទុកមកថា "ទំពក់វាទៅ ទើបញ្ចៀវាមក "ឬ" ខ្មោចស្រុកឲ្យដៃ ទើបខ្មោចព្រៃវាហ៊ាន" ។

ព្រោះហេតុនោះ ស្រីក្រមុំពិតជាមានសិទ្ធផ្តាច់មុខក្នុងការរក្សាព្រហ្មចារីរបស់ខ្លួន គ្មានអ្នកណាអាចចូលជ្រៀត

www.elibraryofcambodia.org

ជ្រែករារាំងបានទេ បើព្រហ្មចារីបរិសុទ្ធ គឺខ្លួនឯងទេដែល ធ្វើឲ្យបរិសុទ្ធនោះ ហើយបើមិនបរិសុទ្ធទេ ក៏ជាស្នាដៃរបស់ខ្លួននោះដែរ ។ ព្រោះធម្មជាតិបានប្រគល់សិទ្ធអំណាចស្នេហាគ្រប់ទាំងអស់ ក្នុងកណ្ដាប់ដៃខ្លួនហើយ ។

គួរកញ្ញាទាំងឡាយ កុំត្រាប់តាមស្រ្តីក្រមុំខ្លះ ថោកទាបមិនស្គាល់តម្លៃខ្លួន ដែលធម្មជាតិបង្កើតមកជារាជិនីនៃសេចក្ដីស្នេហា ហើយគ្រាន់តែកម្លោះលាមកក្ដក់ប៉ក់ ក៏ដោយតាមរ៉ុយ ដូចសត្វតិរច្ឆានដោយញីដោយឈ្មោលនោះឡើយ នាំឲ្យថោកទាបវង្សត្រកូល និងប្រទេសជាតិ ។ ពួកស្រ្តីធុនហ្នឹងហើយ ដែលបង្កើតពូជស្រ្តីផ្កាមាសពាសពេញពិភពលោករហូតមកដល់សព្វថ្ងៃនេះ ។ម៉ែឪមិនដែលធ្វេសប្រហែសក្នុងរឿងនេះទេ កាលណាបើកូនគ្រប់ការហើយ លោកពន្យល់ប្រាប់ភ្លាម អំពីការអាថ៌កំបាំងទាំងប៉ុន្មាន សម្រាប់ការពារទុកមុនឲ្យហើយ តាមដំណើរនៃជីវិតមនុស្សដែលលោកបានឆ្លងកាត់ បានពិសោធន៍មុនក្រែងកូនទៅចោតល្ងង់ នាំឲ្យខូចអនាគត និងវង្សត្រកូល ។

www.elibraryofcambodia.org

ម៉ែបានតាំងខ្លួន ជាមិត្តយ៉ាងជិតស្និទ្ធរបស់កូនស្រី និយាយប្រាប់អាថ៌កំបាំងរបស់ស្ត្រីភេទគ្រប់យ៉ាង ដល់កូន ធ្វើឲ្យកូនទុកចិត្តដូចជីវិតតែមួយ អាចហ៊ានប្រាប់អាថ៌កំបាំងដល់លោកបាន ដូចជាប្រាប់អំពីការមានផ្កាវដូវជាដើម ។ លុះដល់ពេលមានរដូវហើយ លោកតែងសាកសួរពិនិត្យហេតុផល បើកូនរាំងរដូវដោយមានរោគអ្វីៗមកបៀតបៀន ម៉ែឪភ័យណាស់ ខំរកពេទ្យឆ្មបឲ្យពិនិត្យមើល រកថ្នាំមកព្យាបាលឲ្យបានស្រួលមានប្រក្រតីទៀងទាត់ឡើងវិញ ។

ហេតុការណ៍ ដែលម៉ែត្រួតពិនិត្យកាលបរិច្ឆេទនៃផ្ការដូវកូនយ៉ាងនេះ ដើម្បីការពារហេតុពីរយ៉ាងគឺ ការពារសុខភាព១ ការពារអនាគត ក្រែងកូនភ្លាំងភ្លាត់ក្នុងសេចក្ដីស្នេហាដល់មានគភ៌១ ម៉ែបានដឹងភ្លាម មិនឲ្យហួសពេលវេលា អាចជួយសម្រួលអនាគតកូនបានមិនអាម៉ាស់មុខ ។

ឱនាងកញ្ញាទាំងឡាយអើយ! នាងចាំជាមានសំណាងមែន ដែលបានមកកើតក្នុងគ្រួសារ ដែលមានម៉ែឪជាគ្រូគ្មានគ្រូឯណាប្រសើរឯក សក្ដិសិទ្ធអាចជួយនាងបាន ក្នុងពេលដែលនាងភ្លាំងភ្លាត់ ធ្លាក់ទៅក្នុងរង្វង់នៃសេចក្ដីស្នេហា

www.elibraryofcambodia.org

ទេ មានតែម៉ែឪនេះហើយជាមហាឫសី អាចជប់អនាគតដ៏រុងរឿងឲ្យនាងបាន ដូច្នេះបូរនាងស្មោះត្រង់ កុំខ្មាស់អៀនកុំលាក់លៀម បិទបាំងអាថ៌កំបាំងរបស់នាងចំពោះម៉ែឪឲ្យហួសកាលវេលាឡើយ ត្រូវជំរាបប្រាប់លោកភ្លាមៗព្រោះក្នុងលោកនេះ មានតែម៉ែឪទេ ជាព្រះដ៏ស័ក្តសិទ្ធរបស់នាង ។

ចំណែកឯកូនកំឡោះវិញ ពិតមែនតែគ្មានការព្រួយបារម្ភក្នុងការរក្សាព្រហ្មចារីពិតម៉ែន ក៏ប៉ុន្តែម៉ែឪមិនមែនហួតកន្ទុះលែងចោលដូចគោក្របីនោះទេ ។ ខំរំលឹកដាស់តឿនទូន្មានស្តីថា ប្រៀនប្រដៅរាល់ពេលវេលា ដោយផ្ទាល់ខ្លួនផង យកទៅផ្ញើនិងគ្រូអាចារ្យ ឬអ្នកដែលមានការពិសោធន៍ច្រើន ឲ្យជួយប្រៀនប្រដៅផង ដើម្បីឲ្យកូនមានបែបបទល្អជាបដល់ខ្លះទៀត បានឲ្យបួសក្នុងព្រះពុទ្ធសាសនាថែមទៀតផង ដើម្បីការពារអនាគតកូន កុំឲ្យកាន់ប្រឡូកទៅប្រព្រឹត្តអំពើពាលាអាវាសែ ដែលអាចឲ្យក្លាយទៅជាអ្នកប្រមឹក អ្នកលេង អ្នកលួចប្លន់ អ្នកឆបោក អ្នកកាប់ចាក់ជាដើម នាំឲ្យថោកទាបដល់វង្សត្រកូល និងប្រទេសជាតិ ។

www.elibraryofcambodia.org

ដូច្នេះកំឡោះទាំងឡាយ គួរអាណិតអាសូរទ្រូងម៉ែឪរបស់ខ្លួនផង កុំប្រព្រឹត្តអបាយមុខគ្រប់យ៉ាង មានលេងស្រី ដែលជាហេតុឲ្យខូចព្រហ្មចារីជាដើម ។ ឯព្រហ្មចារីរបស់បុរសងាយស្រួលក្នុងការថែរក្សាជាងស្ត្រី គ្មានទរណាវុកគួនតាមបៀតបៀន ដូចព្រហ្មចារីរបស់ស្ត្រីទេ គួរតែថែរក្សាឲ្យបានបរិសុទ្ធគង់វង្សនៅក្នុងភាពកំឡោះ បើមិនបានវិសេសលើសពួកកញ្ញា ដែលមានភេទទន់ខ្សោយជាងនោះក៏ឲ្យបានស្មើទៅចុះ កុំឲ្យចាញ់ប្រៀបពួកគេពេក ។

តាមការពិត មានកំឡោះភាគច្រើនណាស់ ដែលគ្មានការតស៊ូរក្សាព្រហ្មចារី បណ្តោយឲ្យអន្តរាយក្លាយខ្លួនទៅជាពោះម៉ាយទាំងក្មេង ដោយសារតែការភ្លើតភ្លើន ស្រើបស្រាលតាមមិត្តសំឡាញ់វិលខូច ដែលមានព្រហ្មចារីពុករលួយ វាទាំយកវ័យកំឡោះរបស់ខ្លួន ទៅប្រគល់ឲ្យស្រីពេស្យា ស្រីផ្កាមាសជាដើម ជាន់ឈ្លីឈ្លួចពន្លិចចោល ហើយវាបណ្តាលឲ្យចិត្តគំនិតរបស់វា ឲ្យស្រវឹងញៀនញ៉ាមញ៉យបណ្តោយឲ្យខូចសតិបញ្ញាការរៀនសូត្រ ខូចការងារគ្រប់យ៉ាង ខ្វះវាចំលងមេរោគទុកក្នុងខ្លួន ហើយយកទៅ

www.elibraryofcambodia.org

បំផ្លាញអនាគតកិរិយា និងកូនចៅរបស់ខ្លួនថែមទៀតផង ។ ដល់ពេលមានគ្រួសារទៅ នាំឲ្យខូចសេចក្ដីសន្ដោស ចំពោះភរិយា បណ្ដាលឲ្យមានស្រីញីផ្ដេសផ្ដាស ពាស វាលពាសកាលថែមទៀត នេះជាទោសនៃការខូចព្រហ្មចារី របស់បុរស ។ ពួកបុរសធុនហ្នឹងហើយ ដែលបង្កើតឲ្យ មានពូជប្រុសផ្កាប្រាក់ គឺសំផឹងប្រុសពាសពេញលោក ហើយចូលចិត្តនាំបបួលក្មេងកំឡោះៗទាំងឡាយ ឲ្យខូច ព្រហ្មចារី និងបោកបញ្ឆោតស្រីក្រមុំ ដែលនៅគោតល្វង់ ឲ្យខូចព្រហ្មចារី កើតជាស្រីផ្កាមាសថែមទៀតផង ។ រឿង នេះ មានកំឡោះភាគច្រើនយល់ថា ការលេងស្រីម្ដងម្កាល ជាការស្រស់ស្រូបកំសាន្តចិត្ត ឬជាការដកបទពិសោធន៍ ទំរាំមានគូស្រករ នេះពេញជាខុសធំ ប្រៀបថ្នាំពិសជាអាហារ ទិព្វ ព្រោះបើលេងស្រីហើយ ព្រហ្មចារីក៏វិនាសអន្តរធាន ទៅភ្លាមក្នុងពេលនោះដែរ ភាពកំឡោះក៏បាត់បង់ទៅ កើត ជាពោះម៉ាយអស់មួយជីវិត ដល់ពេលមានគូស្រករ ទោះបី ទំរៀបអាពាហ៍ពិពាហ៍មង្គលធំយ៉ាងណាក៏ដោយ ក៏ខ្លួននៅ តែជាពោះម៉ាយដដែល ហើយចលកនងការចបោកបទំ

www.elibraryofcambodia.org

ដោយទុកចិត្ត ចំពោះម៉ែឪទាំងសងខាង ដែលជាអ្នកមានគុណ ព្រមទាំងកិរិយាខ្លួនទៀតផង ព្រោះលោកទាំងនោះមិនដឹងអាថ៌កំបាំង ដែលខ្លួនទំលាក់ទុកនោះ សំគាល់ថាជាមនុស្សកំឡោះ ។ បើខ្លួនមិនបរិសុទ្ធហើយ លទ្ធផលរបស់ខ្លួនក៏មិនបរិសុទ្ធដែរ ដូចសុភាសិតថា “ នាងរត់រកអ្នកអាខាតលក្ខណ៍ រត់រកមេកំបាក់អន្ទា” ។ បើសិនជាយើងមិនមែនជានាងក្រមុំ អ្នកកំឡោះហើយ មុខជាជួបនិងមេខាតលក្ខណ៍ ឬអាកំបាក់អន្ទាពុំខាន បើមិនផ្ទាល់ខ្លួនយើងទេ ក៏តទៅកូនចៅយើងដែរ ។

ការដែលបុរសស្ត្រី បានស្ថិតនៅក្នុងភាពក្រមុំកំលោះនៅក្នុងពេលបច្ចុប្បន្ននេះ បើប្រៀបធៀបគ្នារកតុល្យភាពទៅឃើញថា ពួកស្រីក្រមុំមានប្រៀបជាង ប៉ុនរក្សាព្រហ្មចារីភាពបរិសុទ្ធ បានស្ថិតនៅក្នុងភាពក្រមុំ ប្រហែលជា២០ទៅ ៣០ ភាគរយ ទំរាំដល់ពេលមានប្ដី ។

ឯពួកប្រុសកំឡោះវិញកំសាកណាស់ ដើរលឿនហួសសម័យពេក រក្សាព្រហ្មចារីបរិសុទ្ធបានស្ថិតនៅក្នុងភាពកំឡោះ បានប្រហែលជា ៤ ឬ៥ ភាគរយតែប៉ុណ្ណោះ

www.elibraryofcambodia.org

ទំរាំដល់ពេលមានកិរិយា ។ នេះមកតែពីបុរសមិនសូវមានសុជីវធម៌ក្នុងរឿងនេះ ចំពោះស្ត្រីទាំងឡាយ ។ មួយវិញទៀត បុរសច្រើនប្រមាថមើលងាយ ដោយអាងថាការខូចព្រហ្មចារីរបស់ខ្លួនមិនសូវឮខ្ចរខ្ចាយខ្លាំងទេ អាចបន្ទំពាក់មុខកំឡោះ បោកប្រាស់យកប្រពន្ធក្រមុំបានដោយងាយ ។ មានកំឡោះភាគច្រើនក្នុងលោក មិនទាំងដឹងថាប្រព្រឹត្តដូច្នោះខូចព្រហ្មចារីខ្លួនផង ថែមទាំងមិនដែលគិតថា ខ្លួនមានព្រហ្មចារីបរិសុទ្ធ ទើបបានឈ្មោះថាកំឡោះនោះទេ ធ្លាប់ដឹងថា មានព្រហ្មចារីតែពពួកស្រីក្រមុំតែប៉ុណ្ណោះ ។ ឯខ្លួនចង់ប្រព្រឹត្តធ្វើដូចម្តេច ក៏នៅតែកំឡោះដដែល ព្រោះភាពកំឡោះរបស់ខ្លួន ស្ថិតជាប់ជាន់ដែកថែបទៅទៀត ។ ការយល់ដូច្នេះ ប្រកបដោយមោហៈធំណាស់ ទើបពពួកកំឡោះក្នុងលោកមានព្រហ្មចារីពុករលួយ ពោះម៉ាយទាំងក្មេងអស់ ៩៥ ឬ ៩៦ ភាគរយទៅហើយ ។

ដូច្នេះយើងឃើញថា ស្ត្រីក្រមុំទាំងឡាយ ច្រើនតែមានស្វាមីជាពោះម៉ាយ ឯបុរសពោះម៉ាយទាំងឡាយ ច្រើនតែមានកិរិយាក្រមុំ នេះជារឿងចំឡែកមួយក្នុងការលោក

www.elibraryofcambodia.org

យើងនេះ ។ អាស្រ័យហេតុនេះហើយ គួរកុំឡោះទាំងឡាយ មានសុជីវធម៌ក្នុងរឿងចំឡែកនេះ ចំពោះស្ត្រីក្រមុំទាំងឡាយខ្លះផង ព្រោះស្ត្រីនេះហើយ ជាមាតានៃលោកយើងនេះ មានតែអ្នកកំឡោះទាំងឡាយទេ ដែលជាចៅក្រមអាចរកយុត្តិធម៌ជូនមាតានៃពិភពលោកយើងនេះបាន ហើយ អាចបន្ថយចំនួនរឿងចំឡែកអកុសលនេះ ពីក្នុងពិភពលោកបានផង ។

ចំពោះឥរិយាបថមាតាបិតា ក្នុងការប្រៀនប្រដៅអប់រំបុត្រធីតា មិនមែនអស់ត្រឹមប៉ុណ្ណឹងទេ នៅមានច្រើនជាអនេកទៀតណាស់ ទោះបីជាកូនបានរៀនចេះដឹងហើយក៏ដោយ ក៏លោកនៅតែខ្វល់ខ្វាយ ប្រៀនប្រដៅអប់រំបន្ថែមឲ្យបានវិសេសវិសាលគ្រប់ផ្នែកទាំងអស់ មានបង្រៀនឲ្យចេះធ្វើការរកស៊ីចិញ្ចឹមជីវិត ឲ្យចេះដឹងអំពីសុជីវធម៌គ្រប់យ៉ាង ដូចជាពេលដេក លោកទូន្មានឲ្យដេកប្រកបដោយសុជីវធម៌ចាប់ក្រោកពីព្រលឹម ទោះបីជាមានការរវល់ក្ដីមិនមានការរវល់ក្ដី ត្រូវតែក្រោកឲ្យបានទៀងទាត់ពេលវេលា ដើម្បីឲ្យស្រួលដល់ការប្រាស្រ័យទាក់ទងគ្នា កុំឲ្យ

www.elibraryofcambodia.org

គេពិបាកចាំ កុំឲ្យគេខាតពេលវេលា ។ លុះក្រោកហើយ កុំអង្គុយសំកុក ត្រូវរៀបចំទីដំណេកឲ្យស្អាត កុំក្រោកតែខ្លួនបោលមុនកន្ទេលរប៉ាត់រប៉ាយដូចដំណេកសត្វ និងរៀបចំបោសប្រាសផ្ទះសម្បែង កុំប្រកាន់ថាខ្លួនជាអ្វី ព្រោះក្នុងគ្រួសារមួយៗ មានតែមាតាបិតា និងកូនចៅប៉ុណ្ណោះ យើងជាកូនចៅ ត្រូវតែធ្វើជំនួសលោកទាំងអស់ ព្រោះលោកចិញ្ចឹមយើងធំហើយ ។ បើសិនជាគ្រួសារ យើងមានអ្នកបំរើ ក៏គួរតែយើងជួយធ្វើកិច្ចការខ្លះ ចំពោះកិច្ចការ ដែលគួរធ្វើ មិនត្រូវដេកចាំតែប្រើបំរើគ្រប់មួយរយជំពូកនោះទេ ព្រោះអ្នកបំរើក៏ជាមនុស្សជាតិដូចជាយើងដែរ ។ កាលបើរៀបចំស្អាតបាតហើយ ត្រូវងូតទឹកដុះលាងខ្លួនប្រាណ ស្លៀកពាក់ស្អិតស្អាងឲ្យបានសមរម្យ តាមក្បួនអនាម័យ បើមិនទាន់ដល់ពេលទៅរៀន ឬទៅធ្វើការ ឬពេលស្រេសស្រូបចំណីអាហារទេ ត្រូវទន្ទេញមេរៀន ឬមើលសារពត៌មាន ទស្សនាវដ្ដីជាដើម ។ ព្រោះអីពេលព្រឹកព្រហាមនេះហើយ ដែលសតិបញ្ញាស្មារតីយើងកំពុងតែមានកំលាំង ព្រោះទើបនឹងសម្រាកហើយពេញមួយយប់ អាចចងចាំ

www.elibraryofcambodia.org

អ្វីៗបានដោយងាយ ។ បើសិនជាយើងបណ្ដោយឲ្យការ
ផ្ដោកផ្ដុយ វាទំពាស៊ីពេលវេលាដ៏មានតម្លៃនេះអស់ទៅ
ការបង់ខាតក្នុងដំណើរជីវិតយើងរឹតតែមានច្រើនឡើង ។

ការក្រោកពីព្រលឹមនេះ មិនមែនល្អវិសេសតែក្នុង
សម័យឥឡូវនេះទេ គឺល្អវិសេសតាំងពីសម័យព្រេងនាយ
មកម្ល៉េះ ហើយក៏មិនមែនល្អចំពោះតែកសិករកម្មករនោះទេ
គឺល្អគ្រប់ឋានៈមនុស្សលោកទាំងអស់ ។ ក្នុងសម័យ
កុំព្យូទ័រនេះ ឬហួសសម័យនេះទៅទៀតក៏នៅតែល្អ ឬរឹត
តែល្អឡើងទៀត ព្រោះពិភពលោកយើងកាន់តែចង្អៀត
ចំណែកឯអ្នកវិទ្យាសាស្ត្រ កំពុងតែបង្កើនចំណេះវិជ្ជាកាន់
តែខ្លាំងឡើងថែមទៀត មនុស្សលោកក៏ត្រូវតែរកពេល
វេលាឲ្យកាន់តែច្រើនដែរ ទើបបានរៀនសូត្រមើលស្ដាប់
ចេះដឹងទាន់ចំណេះវិជ្ជានោះៗ បើយើងជាអ្នកដេកនិយម
មុខជារស់នៅក្រៅសម័យមិនខាន ។

ពេលដើរ ឈរ អង្គុយ ម៉ែឪលោកបានប្រៀនប្រដៅ
អំពីសុជីវធម៌ ដូចជាពន្យល់ថាបើកូនដើរ ត្រូវដើរឲ្យមាន
កំណត់ពេលវេលា ទៅណាមកណាត្រូវប្រាប់អាណាព្យា-

www.elibraryofcambodia.org

បាល ឬស្វាមីករិយាខ្លួន កុំដើរឥតជំណើរ ដើរហួសពេល វេលា ដើរប្រេកបដោយអបាយមុខនោះឡើយ ។ បើឈរ មើលអ្វីៗ ត្រូវឈរឲ្យមានសុជីវធម៌ កុំឈរប្រចែងប្រចាំង កំបាំងមុខមនុស្សចាស់និងស្ត្រីភេទ គួរចេះលៃលកឲ្យ មនុស្សចាស់ និងស្ត្រីមានឱកាសឈរបានស្រួលផង ។ ចំណែកឯការអង្គុយក៏ដូចគ្នា បើយើងមានការប្រាស្រ័យ ទាក់ទងជាមួយនិងគេត្រូវគិតឲ្យសព្វគ្រប់ កុំនៅអង្គុយ និយាយផ្តេសផ្តាសគ្មានចប់ អង្គុយសំកុកហួសពេលវេលា នាំឲ្យរំខានដល់អ្នកដែលខ្លួនប្រាស្រ័យជាមួយ ត្រូវយល់ ពេលគេដេក ពេលគេបរិភោគអាហារ ឬពេលគេមានការ ចាំបាច់ ទើបឈ្មោះថាអង្គុយមានសុជីវធម៌ ។ មាតាបិតា លោកប្រៀនប្រដៅ អប់រំបុត្រធីតាគ្រប់វិស័យទាំងអស់ មិនអាចនាំមកនិយាយរៀបរាប់ ឲ្យបានសព្វគ្រប់ក្នុងទីនេះ បានទេ បើនិយាយរួមឲ្យខ្លីមក លោកប្រដៅកូនចៅឲ្យចេះ ដឹងយល់ស្គាល់អំពីសិទ្ធិករណីយកិច្ចរបស់ខ្លួន និងអ្នកដទៃ ឲ្យលះបង់អំពើអាក្រក់ខំសាងតែអំពើល្អ ។

www.elibraryofcambodia.org

## ភារកិច្ចមាតាបិតាក្នុងការសង្គ្រោះបុត្តធីតា

បន្ទាប់ពីបានអប់រំបុត្រធីតា ឲ្យមានចំណេះវិជ្ជាកើតសតិបញ្ញាស្គាល់ខុសត្រូវ ចេះធ្វើការចិញ្ចឹមជីវិតមក មាតាបិតាបានបំពេញភារកិច្ចមួយទៀតគឺ រៀបចំកូនឲ្យមានគូរស្វាមីភរិយាតាមគន្លងប្រពៃណីពីបុរាណ ដែលលោកបានគោរពកាន់ជាវៀងរហូតមក ។

តែមុននិងរៀបចំបុត្រធីតាឲ្យមានគូរស្វាមីភរិយានោះ មាតាបិតាខំពិនិត្យជ្រើសរើសសព្វយ៉ាង លៃថ្លឹងឲ្យមានតុល្យភាពស្មើគ្នា ឬប្រហាក់ប្រហែលគ្នា គឺជ្រើសរើសតាំងពីវង្សត្រកូល ទ្រព្យសម្បត្តិ ចំណេះវិជ្ជា ចរិយាមាយាទនិងរូបសម្បត្តិ រហូតដល់ថ្ងៃខែឆ្នាំថែមទៀតផង ដើម្បីឲ្យកូនទាំងពីរបានសុខចំរើនក្នុងដំណើរជីវិតទៅថ្ងៃអនាគត ។

ការជ្រើសរើសលៃថ្លឹងនេះ លោកចំណាយពេលវេលាជាច្រើន ដើម្បីសាកសួរប្រឹក្សាជាមួយក្រុមញាតិមិត្តនិងចាស់ព្រឹទ្ធាចារ្យ ទាល់តែមានយោបល់កាគច្រើនទៅ

www.elibraryofcambodia.org

ខាងណា ទើបសម្រេចចិត្តទៅខាងនោះ ជាពិសេសលោក តែងតែសាកសួរយោបល់ សួង់ចិត្តបុត្រធីតាជាមុន ។

តែទោះបីជាលោក ខំពិនិត្យពិច័យយ៉ាងនេះក៏ដោយ ក៏គង់តែមានឧបសគ្គខ្លះៗ នាំឲ្យលោកអាម៉ាសមុខ ខ្មាសញាតិសណ្ដាន កើតទុក្ខក្រៀមក្រំ ។ ចំណែកឯឧបសគ្គនោះ ច្រើនកើតមកតែអំពីបុត្រធីតា ដែលគ្មានការស្មោះត្រង់ស្វាមីភក្ដិចំពោះមាតាបិតា ដែលជាអ្នកបង្កើតក្បាលខ្លួន ។ គឺបុត្រធីតាទាំងនោះ បានលួចលាក់ប្ដេជ្ញាស៊ូស្លាប់រស់ជាមួយអ្នកដទៃរួចស្រេចទៅហើយ ដល់មាតាបិតាសាកសួរចិត្តនិងរកគូស្រករឲ្យ រឹតតែកុតករបោកបញ្ឆោតថែមទៀត ខ្លះថាមិនទាន់ចង់បានស្វាមី ឬភរិយាទេ ខ្លះទៀតថាស្អប់មិនចូលចិត្តអ្នកនោះ នាងនោះ ខ្លះទៀតនៅតែស្ងៀមធ្មឹង ដូចជារូបតុក្កតា មិនព្រមហាស្ដី ប្រាប់ការពិតដល់មាតាបិតាទាល់តែសោះ លុះពេលរៀបអាពាហ៍ពិពាហ៍ ឬកំពុងរៀបអាពាហ៍ពិពាហ៍ ឬមិនទាន់ដល់ពេលរៀអាពាហ៍ពិពាហ៍ផងស្រាប់តែលួចរត់ទៅតាមគូស្នេហាលួចលាក់របស់ខ្លួន បាត់ទៅ ឬមួយក៏លេបថ្នាំសំលាប់ខ្លួនក៏មាន ។ បុត្រធីតាដែល

www.elibraryofcambodia.org

ប្រព្រឹត្តដូច្នេះ ឈ្មោះថាជាកូនអកតញ្ញូជំណាស់ ធ្វើឲ្យមាតាបិតាលោកកើតទុក្ខមុខក្រៀមក្រំ បំបាក់មុខលោកឲ្យខ្មាសគេពាសពេញស្រុក ។

តែដើម្បីដោះស្រាយបញ្ហានេះឲ្យបានងាយ ហើយទាន់សម័យទៀតផងនោះ បុត្រធីតាទាំងឡាយ ត្រូវសង្កត់ចំណុចធ្ងន់មួយទៅក្នុងគំនិតថា នៅក្នុងលោកសន្និវាសនេះមានតែមាតាបិតាទេ ជាអ្នកបង្កើតខ្លួនយើង ហើយមិនប្រកាន់កំហុសគ្រប់យ៉ាងទាំងអស់ចំពោះយើង ថែមទាំងជាអ្នកផ្តល់នូវសេចក្តីសុខចំរើនទៀត ទោះបីជាលោកខឹងដល់វាយជេរយ៉ាងណា ក៏លោកនៅតែរាប់រកជានិច្ច មិនបោះបង់ចោលឡើយ ដូចសុភាសិតថា "ជេរទៅហៅមក"។

កាលបើបុត្រធីតាទាំងឡាយ កំណត់ក្នុងចិត្តដូច្នេះហើយ មុននឹងផ្តល់សេចក្តីស្នេហាទៅលើរូបអ្នកណាមួយត្រូវត្រិះរិះពិចារណា ដោយប្រាជ្ញារបស់ខ្លួនឲ្យបានគ្រប់ជ្រុងជ្រោយ ព្រោះមនុស្សលោក ដែលខំសិក្សាចំណេះវិជ្ជាគ្រប់យ៉ាងតាំងពីតូចមក មិនមែនយកប្រាជ្ញាទៅទុកធ្វើផ្កធ្វើមាំទេ ប្រាជ្ញានេះហើយសម្រាប់រចនាខ្លួនយើងឲ្យបានរុងរឿង

www.elibraryofcambodia.org

ឲ្យបានគាប់ចិត្តមាតាបិតាញាតិសណ្ដាន និងមហាជនទូទៅ ។

បើយើងមិនចេះជ្រើសរើសគូស្នេហា ឲ្យសមឋានៈខ្លួនទេ យើងនឹងអន់ជាងសត្វតិរច្ឆានទៅទៀត សូម្បីសត្វកុកនិងក្អែក ដែលមានលក្ខណៈដូចគ្នា គ្រាន់តែប្លែកសម្បុរគ្នាប៉ុណ្ណោះ ក៏វាមិនខ្វីស្នេហាគ្នាផង ចុះទំរាំយើងជាមនុស្សហេតុអ្វីក៏មិនយកសត្វទាំងនោះមកធ្វើជា គតិសំរាប់គិតពិចារណាផង ។

ដូច្នេះបុត្រធីតាទាំងឡាយ ត្រូវចេះគិតពិចារណាថ្លៃថ្លឹងចិត្តខ្លួនឯង និងចិត្តមាតាបិតាដោយខ្លួនឲ្យស្រេចជាមុនសិន កុំចេះតែឆ្មេចក្អែកបោះទម្លាក់ស្នេហាព្រាវៗនោះឡើយ គឺគិតថ្លៃថ្លឹងថាអ្នកនេះនាងនេះ សមឋានៈនិងអញឬទេ? មានវង្សត្រកូល ចំណេះវិជ្ជា ចរិយាមាយាទ និងពណ៌សម្បុរ ល្មមមាតាបិតាញាតិសណ្ដានអញរាប់អានកើតឬទេ ? បើយ៉ាងហោចណាស់ ក៏ក្នុងជប់ភាគឲ្យបានពាក់កណ្ដាលដែរ ។

កាលបើល្មមភាគ សមចិត្តគ្នាទៅវិញទៅមកហើយ ទើបគួរថ្កក់ស្នេហាគ្នាបាន ហើយអ្នកទាំងពីរត្រូវជំរាបដល់

www.elibraryofcambodia.org

មាតាបិតារៀងៗខ្លួនតាមការពិតភ្លាម រៀបរាប់ហេតុផលឲ្យលោកបានជ្រាបគ្រប់ចំណុច មិនត្រូវខ្មាសអៀនលោកទេ គួរតែខ្មាសអៀនគូរស្នេហាអ្នកនាង ដែលជាអ្នកដទៃនោះវិញ បើអ្នកដទៃមិនខ្មាសអៀនហ៊ានស្នេហាគ្នាហើយ តើទៅខ្មាសអៀនអ្វីចំពោះមាតាបិតាយើង ។ បើអ្នកទាំងពីរជំរាបគាត់ឲ្យជ្រាបសព្វគ្រប់សមហេតុផលហើយ លោកមុខតែទទួលស្គាល់នូវសេចក្ដីស្នេហានោះ ហើយថែមទាំងជួយឧបត្ថម្ភឲ្យបានសម្រេចជាគូស្វាមីភរិយា ដោយរកពាយជាមិនបាន ប្រសិនបើមាតាបិតានោះ ជាអ្នកសម័យនិយមផង លោកនឹងអនុញ្ញាតឲ្យអ្នកទាំងពីរ ទៅមករាប់រកគ្នាបណ្ដើរគ្នាលេងបានដោយសេរី មុនពេលរៀបអាពាហ៍ពិពាហ៍ថែមទៀតផង តែអ្នកទាំងពីរត្រូវរក្សាលក្ខណៈស្នេហាសម័យនិយមឲ្យបានម៉ត់ចត់ គឺរក្សាព្រហ្មចារីឲ្យបរិសុទ្ធដរាបដល់អាពាហ៍ពិពាហ៍ហើយ ។

ម្យ៉ាងទៀងបើអ្នកទាំងពីរគ្មានសមត្ថភាព នឹងរើសរកគូស្វាមីភរិយាដោយខ្លួនឯងឲ្យបានគាប់ចិត្តមាតាបិតាទេ កុំស្នេហាផ្ដេសផ្ដាសល្បួចលាក់ និងមាតាបិតាដែលហៅថា

www.elibraryofcambodia.org

ស្នេហាព្រៃផ្សៃ ឬស្នេហាបាតផ្កានោះឲ្យសោះ ត្រូវរក្សាព្រហ្មចារីឲ្យបរិសុទ្ធ ចាំមាតាបិតារើសគូស្វាមីភរិយាឲ្យ ទើបគាប់ប្រសើរ មិនខូចប្រពៃណី សមគួរតាមបុរាណនិយម ។

ការរៀបចំកូនឲ្យមានគូស្វាមីភរិយានេះ មាតាបិតាមានការបារម្ភច្រើនណាស់ ជាពិសេសក្រែងកូនមិនបានសុខសាន្តជាមួយគ្នាទៅថ្ងៃអនាគត ដរាបដល់អស់ជីវិត ទើបលោកខំរំលឹកទូន្មានអប់រំកូន តាំងពីនៅលីវ ឲ្យរៀនច្បាប់ស្រី ច្បាប់ប្រុស តាមបុរាណនិយម និងច្បាប់សុជីវធម៌ក្នុងគ្រួសារ តាមសម័យនិយម ។

ឯច្បាប់ទាំងអស់នេះ មានចំណុចសំខាន់តែម្យ៉ាង គឺអប់រំស្វាមីភរិយា ឲ្យមានសេចក្ដីសន្ដោស ចេះគោរពស្ដាប់គ្នា ចេះអត់ឱនឲ្យគ្នាទៅវិញទៅមក កុំឲ្យមានការឈ្លោះទាស់ទែងខ្វែងគំនិតគ្នា ។ ម្យ៉ាងទៀត ហេតុដែលនាំឲ្យមានការឈ្លោះគ្នារវាងស្វាមីភរិយា បើតាមការពិសោធន៍ តាំងពីព្រេងនាយមក និងតាមការពិនិត្យអង្កេតតាមដានទៅឃើញថា ច្រើនបណ្ដាលកើតមកពីភរិយា ដែលខ្វះលក្ខណៈ

www.elibraryofcambodia.org

សម្បត្តិប្រកបដោយស្រីគ្រប់លក្ខណ៍ និងជាស្រីដែលមិនមានលក្ខណៈជាស្រីមេផ្ទះ ។

ចំណែកស្រីនៅក្នុងពិភពលោកនេះ លោកចែកចេញជា៤ ប្រភេទដូច្នេះគឺ ៖

ប្រភេទទីមួយ គឺស្រីដែលខឹងតែនិងរឿងរ៉ាវកំប៉ិកកំប៉ុកធម្មតា មានចិត្តរាយមាយសាវ៉ា មានចិត្តលោភលន់ប្រណែនបែនទាលឈ្នានីស និងសុភមង្គលរបស់អ្នកឯទៀតគ្មានសមានចិត្តចំពោះសេចក្តីខ្វះខាតនៃអ្នកឯទៀតឡើយ ។

ប្រភេទទីពីរ គឺស្រីដែលខឹងនិងរឿងកំប៉ិកកំប៉ុក មានចិត្តសាវ៉ា ហើយមានចិត្តលោភលន់ តែមិនចេះប្រណែនបែនទាលឈ្នានីសនិងសុភមង្គលរបស់អ្នកដទៃទៀត មានចិត្តចេះឈឺឆ្អាលនិងការខ្វះខាតរបស់អ្នកដទៃ ។

ប្រភេទទីបី គឺស្រីដែលមានចិត្តទូលាយមិនសូវចេះខឹងសម្បារទេ ចេះបង្ក្រាបចិត្តលោភលន់ ប៉ុន្តែមិនចេះចៀសវាងចិត្តប្រណែនបែនទាលឈ្នានីសនិន្ទា ហើយមិនចេះឈឺឆ្អាលនិងការខ្វះខាតរបស់អ្នកដទៃទៀតទេ ។

ប្រភេទទីបួនគឺស្រីដែលមានចិត្តទូលាយ ចេះបង្ក្រាប

www.elibraryofcambodia.org

ចិត្តលោភលន់ ចេះរក្សាចិត្តឲ្យបានស្ងប់ មិនប្រាថ្នាដណ្តើមយកសុភមង្គលរបស់អ្នកដទៃ ចេះឈឺឆ្អាលនិងការខ្វះខាតនៃអ្នកដទៃទៀត ។

លក្ខណៈសម្បត្តិរបស់ស្ត្រីទាំងបួននេះ គួរស្ត្រីគ្រប់រូបពិចារណា ហើយរើសយកមកប្រតិបត្តិ ដើម្បីឲ្យសមលក្ខណៈសម្បត្តិជាស្រី ដែលប្រកបដោយភាពវៃឆ្លាត និងឲ្យពេញលក្ខណៈជាស្រីមេផ្ទះពិតប្រាកដ ។

ឯលក្ខណៈធំបំផុតរបស់ស្ត្រីមេផ្ទះនោះ គឺសេចក្តីអត់ធន់ ព្រោះអីធម្មជាតិបានបង្កើតស្ត្រីភេទមក ប្រកបដោយធាតុទន់ខ្សោយ ហើយសុភាពរាបសា មានរូបរាងអវយវៈទន់ភ្លន់ ស្លូតបូត សមរម្យ ជាជម្រកដ៏ត្រជាក់ត្រជុំរបស់ជនក្នុងគ្រួសារ និងជាឱសថ ឬជាសាស្ត្រាចារ្យប្រចាំគ្រួសារ សម្រាប់អប់រំបន្ទោរបង់នូវកំហុស និងសេចក្តីក្តៅក្រហាយទុក្ខព្រួយរបស់ស្វាមី និងបុត្រធីតា ទើបមាននាមដ៏ឧត្តមថា "មេផ្ទះ" គឺជាមេជម្រក សម្រាប់ស្វាមីបុត្រធីតាជ្រកនៅបានសុខសាន្ត ។

ហេតុដូច្នេះហើយ ស្រីមេផ្ទះគ្រប់រូបត្រូវតែមាន

www.elibraryofcambodia.org

សេចក្តីអត់ធន់ជាចាំបាច់ ដើម្បីរក្សាភាពធម្មជាតិរបស់ខ្លួន ឲ្យមានប្រក្រតីរបស់រីករាយល្អជានិច្ច លះបង់នូវសេចក្តីក្រេវក្រោធ ប្រណែនប្រច័ណ្ឌ មើលងាយបន្ថោកបង្អាប់ យកឈ្នះលើស្វាមីខ្លួន ដែលជាឧបសគ្គចំពោះធម្មជាតិរបស់ខ្លួននោះចេញ ។

កាលល្អរីករាយ ដែលប្រកបដោយសេចក្តីអត់ធន់នេះហើយ ដែលជាអាវុធរបស់ភរិយា គឺជាព្រនង់ទិព្វមួយយ៉ាងធំ សម្រាប់សំពងកំទេចបោលនូវអំពើអាក្រក់ អំពើពុតត្បុតរបស់ស្វាមីឲ្យអន្តរធាន បាត់បង់ទៅដោយស្វ័យប្រវត្តិ ។ ទោះបីស្វាមីនោះ ជាមនុស្សពាល ដែលមាតាបិតាគ្រូអាចារ្យប្រដៅមិនបានតាំងពីកំណើតមក ក៏ត្រូវបាក់បបខូបខ្វាចលះបង់នូវអំពើអាក្រក់ចោលចេញ ដោយខានមិនបាន ។ បើជាអ្នកខិលខូចខ្លាំង ដល់ពេលប្រែចិត្តគំនិតល្អវិញ ច្រើនតែបន្ទន់ខ្លួនសម្រក់ទឹកភ្នែក ថ្លែងកំហុសខ្លួនចំពោះមុខភរិយាទៀត ដោយឥទ្ធិពលព្រនង់ទិព្វនេះឯង ។ ប៉ុន្តែមានបុរសគម្រក់មួយចំនួន ដែលព្រនង់ទិព្វនេះមិនអាចកែឡើងទាល់តែសោះ គឺមនុស្សពាលខូច អាក៏សែ

www.elibraryofcambodia.org

មិនចិញ្ចឹមកូនប្រពន្ធ ប្រព្រឹត្តតែអំពើអបាយមុខ ឆបោក លួចឆក់ប្លន់ ទ្រព្យសម្បត្តិមាសប្រាក់ប្រពន្ធកូនយកទៅ បំផ្លាញ ក្បត់គ្រួសារឯងនោះ ស្ត្រីជាភរិយាគប្បីលែង ចោលឲ្យដាច់ស្រឡះពីខ្លួន ។ ព្រោះការលះលែងបុរសធុន នេះ ហាក់ដូចជាបន្ទោរបង់លាមកចោលទៅក្នុងបង្គន់ដូច្នោះ ដែរ ។

ស្ត្រីមេផ្ទះដែលចេះអត់ធន់ មានសេចក្តីសន្តោស មិនចង់បានឈ្នះពីស្វាមី មានចរិយាល្អសមហេតុផល នេះ ហើយហៅថាស្រីមានលក្ខណ៍ គឺស្រីល្អ ។ ស្រីល្អក្នុងទីនេះ មិនមែនល្អតែរូបរាងនោះទេ គឺល្អទាំងចរិយាមាយាទ ខ្ជាត ខ្ជាវ ចេះអត់ធន់ មិនដែលយកឈ្នះប្តីដោយកំលាំងបាយ ព្រមចាញ់ដោយរីករាយជានិច្ច ហើយអាចយកជ័យជំនះ ពីប្តីបានដោយសន្តិភាព ។

ធម្មតាស្ត្រីដែលល្អ ឬស្រីដែលប្រកបដោយលក្ខណៈ សម្បត្តិជាស្រីគ្រប់លក្ខណ៍ កាលណាបើមានប្តីហើយ នាង តែងតែប្តេជ្ញាចិត្តខ្លួនដូច្នេះថា ៖

www.elibraryofcambodia.org

អាត្មាអញត្រូវតែគោរពបម្រើម្ដាយឪពុកក្មេក ឲ្យបានម៉ត់ចត់ បម្រើគាត់ដោយសេចក្ដីស្រលាញ់ ដូចដែលអាត្មាអញបម្រើម្ដាយឪពុកបង្កើតរបស់ខ្លួនអញដែរ ។ ព្រោះគាត់បានផ្ដល់គ្រប់អត្ថប្រយោជន៍ដល់យើង គាត់ជាអ្នកឧបត្ថមយើងដោយព្រហ្មវិហារធម៌ ។ ដូច្នេះអាត្មាអញត្រូវតែបម្រើគាត់ដោយកក្ដី ហើយប្រុងប្រៀបខ្លួនជានិច្ចដើម្បីជាំជួយការងារគាត់ឲ្យអស់ពីសមត្ថភាព ។ អត្មាអញត្រូវគោរពរាប់អានញាតិមិត្តរបស់ស្វាមីឲ្យបានច្រើន ដែលជាហេតុបង្កើតឲ្យមានបរិយាកាសស្និទ្ធស្នាល និងសប្បាយរីករាយនៅក្នុងគេហដ្ឋានថ្មីរបស់ខ្លួន ។

អាត្មាអញ ត្រូវតែគោរពគ្រូអាចារ្យរបស់ស្វាមី ពីព្រោះលោកបានផ្ដល់ចំណេះដឹងយ៉ាងពិសិដ្ឋ ដល់ស្វាមីអាត្មាអញ ហើយមនុស្សយើងមិនអាចប្រកបជីវិតរស់នៅបានជាមនុស្សពេញលេញទេ ប្រសិនបើអត់ចំណេះវិជ្ជាពិសិដ្ឋទាំងនោះ ។ អាត្មាអញត្រូវខំយកចិត្តទុកដាក់ឲ្យបានយល់កិច្ចការរបស់ស្វាមី ដើម្បីនឹងអាចជួយធ្វើការងារគាត់ ។ អាត្មាអញមិនត្រូវព្រងើយកន្ដើយជាដាច់ខាត និង

www.elibraryofcambodia.org

ផលប្រយោជន៍របស់ស្វាមី ដោយគិតថាជារឿងរបស់គាត់តែម្នាក់ឯងគត់នោះទេ គឺត្រូវតែចាត់ទុកថាជារឿងរបស់យើងទាំងពីរនាក់ ។ អាត្មាអញត្រូវចេះសង្កេតឲ្យស្គាល់នូវសកម្មភាព អត្តចរិត សន្ដានចិត្ត អធ្យាស្រ័យ សមត្ថភាព និងដឹងពីម្ហូបអាហារដែលជាចំណង់ចំណូលចិត្តរបស់ស្វាមី និងអ្នកដែលនៅក្នុងផ្ទះ ហើយត្រូវចេះថែទាំអ្នកទាំងនោះឲ្យបានសមរម្យ ។ អាត្មាអញត្រូវចេះថែរក្សាទុកដាក់ទ្រព្យសម្បត្តិ ដែលស្វាមីរកបានមក មិនត្រូវចាយវាយខ្ជះខ្ជាយ ទ្រព្យទាំងនោះក្នុងបំណងអត្តទត្ថបុគ្គល សម្រាប់សេចក្តីសប្បាយតែម្នាក់ឯងនោះទេ ។ អាត្មាអញគប្បីជាមនុស្សស្លុតភាពរាបសារ មានសណ្ដានចិត្តល្អ និងប្រុងប្រយ័ត្នក្នុងការប្រាស្រ័យទាក់ទងជាមួយបាវព្រាវ និងត្រូវទុកដាក់ថែរក្សាមាសប្រាក់ ដែលស្វាមីរកបាន ឲ្យបានល្អព្រមទាំងត្រួតពិនិត្យឲ្យបានច្បាស់ថា ចំណាយសព្វបែបយ៉ាងនៅក្នុងផ្ទះសម្បែង ត្រូវបានរៀបចំចាត់ចែងត្រឹមត្រូវហើយ ។

www.elibraryofcambodia.org

ឯបុរសមានភេទខ្ពស់ និងកំលាំងកាយខ្លាំងជាង ភេទស្ត្រី ដូច្នេះស្ត្រីជាភរិយា មិនអាចតតាំងយកជ័យជំនះពីស្វាមីខ្លួនបានដោយកំលាំងបាយ មានការជេរប្រទេចផ្តាសា ខ្វារ ខ្វាំ ខាំ ក្តិច ប្រច័ណ្ឌ ឡូឡា យំស្រែកនោះឡើយ ។ ឯការឃោឃៅកាចសាហាវជាដើមនោះ ជាលក្ខណៈរបស់ស្ត្រីខាតលក្ខណ៍ទេតើ ។ ធម្មតាស្ត្រីខាតលក្ខណ៍ មានតែការឃោឃៅកាចសាហាវ ប្រច័ណ្ឌប្តីជាចាំបាច់ មិនសូវគិតគូរពីទ្រព្យសម្បត្តិមានក្រ ល្អអាក្រក់ និងធ្វើម្ហូបចំណីទេ មានតែចិត្តជោគជាំទៅដោយកាមរាគ មួយថ្ងៃៗរកតែរឿងប្រច័ណ្ឌប្តី បើប្តីទៅណាម្តងៗ ពេលត្រឡប់មកវិញក្នុងចិត្តពុះពោរដោយកំហឹង ក្រឡេកដើមភ្នែកចុងភ្នែកមើលសង្កេតរូបកាយសំលៀកបំពាក់ប្តី ដើម្បីរកលេសចាប់ពិរុទ្ធចោទប្រកាន់ប្រច័ណ្ឌបៀតបៀន នាំឲ្យមានរឿងរ៉ាវក្តៅក្រហាយក្នុងគ្រួសារ ។ បើមានទរណាមកទាក់ទងនិងប្តីខ្លួន លើកប្តីប្រច័ណ្ឌនិងគេភ្លាម ហើយដើរនិយាយហែកកេរ្តិ៍ស៊ែអុយឈ្មោះប្តី ប្រាប់គេឯងរហូតដល់កញ្ជះគេក៏ប្រាប់ដែរ ឲ្យតែជាប់ស្គាល់មុខ ហ៊ាននិយាយមើលងាយ

www.elibraryofcambodia.org

ប្តីពេញទីថា អាក្បាលខូច អាឆ្កែ អាក្បាលកញ្ចាស់ គំនិតដូចកូនក្មេង អាទន្ទះបាញ់ អាឡានបុក អាត្រូវគ្រាប់......... ជាដើម ។ ជក់មាត់ល្អណាស់គ្មានញញើតទេ និយាយមិនចង់ឈប់ ភ្លេចពេលបាយទឹកអស់ ។ មានខ្លះទៀតនិយាយផងយំផង ធ្វើអាការៈយ៉ាងថោកទាបប្រាប់គេឯងឲ្យជួយឈឺក្បាលខ្លួន ។ បើនិយាយទៅចំលើស្រីខាតលក្ខណ៍ដូចគ្នានោះ ត្រូវជើងគ្នាម៉ាំងតែម្តង តាំងបើកចាកបង្ហូរ ហែកកេរ្តិ៍ប្តីតែរៀងខ្លួន មួយឈុតទៅមួយឈុតមក ចេះតែជក់មាត់ឡើងៗ រហូតដល់កូនយំនៅចំពោះមុខក៏មិនញ្ញើដែរ ។

ប៉ុន្តែ បើនិយាយទៅចំលើស្រីគ្រប់លក្ខណ៍វិញនោះ ដូចជាអាក្រាតកាយនៅខ្លួនទទេ ឲ្យគេស្គាល់ច្បាស់ថា មេនេះជាស្រីខាតលក្ខណ៍ទេតើ ហើយគេអាចស្គាល់ជ្រៅដល់ទៅថ្លើមប្រមាត់បេះដូងទៀត ថាស្រីលោភមេថុន ពោរពេញទៅដោយសេចក្តីស្រេកឃ្លាន អន្ទះសារខ្លាក ទើបចេះតែខំប្រចែប្រច័ណ្ឌ ការពារទុក ក្រែងមិនបានឆ្អែតស្កប់ស្កល់ ។ ព្រោះការប្រច័ណ្ឌនេះ ជានិមិត្តរូប ឬជាឃីហោនៃមហាកាមរាគ មានគោលបំណងបាញ់ពោះទៅរកតែមេ-

www.elibraryofcambodia.org

ជូនផ្ទាល់ខ្លួន តែម្នាក់ឯង ។ គួរឲ្យអាម៉ាស់មុខណាស់ មិនគួរស្រីខាតលក្ខណ៍ ពាក់មុខប្រច័ណ្ឌ ឲ្យគេស្គាល់យីហោ អាសគ្រោមអាស្រូវនេះសោះ ជាពិសេស គួរខ្មាសចំពោះមុខស្វាមីខ្លួន ឬកូនខ្លួនដែលធំក្តីហើយ ។ ហេតុដូច្នេះ គួរស្ត្រីមេផ្ទះ និងនារីជាអនាគតមេផ្ទះទាំងឡាយ ចៀសវាងនូវតម្រាប់អាក្រក់របស់ស្រីខាតលក្ខណ៍នេះ ជាដាច់ខាត ព្រោះតម្រាប់ដ៏អាក្រក់នេះ អាចរុញច្រានស្វាមី ឲ្យរឹតតែធ្លាក់ចុះទៅក្នុងអំពើមិនគាប់ចិត្តរបស់ខ្លួនថែមទៀត នាំឲ្យវិនាសអន្តរាយក្តៅក្រហាយវេទនាខ្លួនឯងទេ ដូចគេបំពក់ផ្សែងដេញឃ្មុំឲ្យហើរចោលសម្បុកដូច្នោះដែរ ។

នៅលើលោកយើងនេះ មានស្ត្រី ៧ប្រភេទខុសៗ គ្នា ដូចតទៅនេះ ៖

១-វធកាភរិយា គឺស្ត្រីដូចជាឃាតករ មានចិត្តមិនបរិសុទ្ធ រង់ចាំតែរករឿងឈ្លោះប្រកែក មិនមានចិត្តត្រាប្រណី ហាក់ដូចជាពេជ្ឈឃាត ដែលមិនដែលមានចិត្តត្រាប្រណី ចំពោះអ្នកទោសរបស់ខ្លួន មិនគោរពប្តីរបស់ខ្លួន មានចិត្តបែរទៅរកប្រុសឯទៀត ។

www.elibraryofcambodia.org

២-ចោរីភរិយា គឺភរិយាដូចជាចោរ ចិត្តមិនត្រង់និងស្វាមីរបស់ខ្លួន មិនចេះយល់ដល់កិច្ចការរបស់ស្វាមី គិតតែពីប្រណិតភាពរបស់ខ្លួន ចាយវាយទ្រព្យខ្ជះខ្ជាយឥតមានការអាណិតអាសូរ ដល់ការខិតខំប្រឹងប្រែងរករបស់ស្វាមី គិតតែដើម្បីបំពេញចំណង់របស់ខ្លួន ។ ភរិយារបៀបនេះ គឺចាំតែលួចបំបាត់ទ្រព្យសម្បត្តិរបស់ស្វាមី ដូចជាចោរដែលចាំតែលួចទ្រព្យគេ និងលាក់បំបាត់រឿងអាក្រក់របស់ខ្លួនមិនឲ្យគេដឹង ។

" ពួកចោរកំណាច តែងលួចប្លន់យកទ្រព្យសម្បត្តិលើផ្ទះ ឲ្យវិនាសហិនហោចទៅ មានឧបមាយ៉ាងណា ស្ត្រីដែលក្បត់ចិត្តប្តី តែងតែលួចបណ្តាក់ទ្រព្យ ដែលប្តីរកបានមកដោយរហេមរហាមនោះ យកទៅចិញ្ចឹមសាហាយ យកទៅបញ្ចាំចិត្តសង្សារ ទ្រព្យក៏អន្តរាយរលាយបាត់ទៅ រាល់វេលាមានឧបមេយ្យយ៉ាងនោះឯង " ។

៣-អយ្យាភរិយា ភរិយាដូចជាចៅហ្វាយ ឬដូចជាម្ចាស់ចាំតែបង្គាប់បញ្ជា ខុសសីលធម៌មើលងាយស្វាមី

www.elibraryofcambodia.org

ខ្ទួនជានិច្ចកាល ធ្វេសប្រហែសនិងកិច្ចការក្នុងផ្ទះជេរប្រទេចប្ដីដោយពាក្យគ្រោតគ្រាតជានិច្ច ។

៤-មាតាភរិយា ភរិយាដូចជាម្ដាយ មានចិត្តស្រលាញ់ស្វាមី ដូចជាម្ដាយដែលមានចិត្តស្រលាញ់ថ្នាក់ថ្នមកូន មើលការខុសត្រូវចំពោះកូន រវាំងប្រយ័ត្នមិនឲ្យកូនធ្វើខុស ប្រព្រឹត្តអំពើផ្ដេសផ្ដាស ការពារកូនមិនឲ្យប្រព្រឹត្តអាក្រក់ដូច្នោះដែរ និងចេះថែរក្សាទុកដាក់ទ្រព្យសម្បត្តិដែលស្វាមីរកបានមកមិនឲ្យអន្តរាយ ។

៥-ភគិនិភរិយា ភរិយាដូចជាបងស្រី មានចិត្តស្មោះត្រង់និងប្ដី ស្រលាញ់ថ្នាក់ថ្នមថែទាំប្ដី ដូចជាបងស្រីដែលស្រលាញ់ការពារប្អូនដូច្នោះដែរ ។

៦-សខីភរិយា ភរិយាដូចជាមិត្តភក្ដិ ចេះធ្វើឲ្យស្វាមីបានសប្បាយរីករាយ ដូចជាមិត្តដែលបែកគ្នាយូរបានអ្វីក៏បែកគ្នា តាមនាទីមិត្តគោរពមិត្ត មានចរិយាសុភាពរម្យទម ចេះកាន់មាយាទត្រឹមត្រូវ ចេះបម្រើស្វាមីដោយគោរព និងចេះរួមសុខរួមទុក្ខជាមួយគ្នា ។

www.elibraryofcambodia.org

៧-ទាសីភរិយា ភរិយាដូចជាខ្ញុំបម្រើ ចេះបម្រើស្វាមីយ៉ាងត្រឹមត្រូវ និងដោយចិត្តស្មោះត្រង់ ចេះគោរព និងចេះស្តាប់បង្គាប់ស្វាមី គ្មានបំណងចង់បានសុខស្រួលតែម្នាក់ឯង ចេះមានការពេញចិត្តនិងស្វាមីជានិច្ច មិនចេះគុំគួន ចេះខំប្រឹងផ្តល់សេចក្តីសុខដល់ស្វាមីជានិច្ច ។

ភរិយាទាំង ៧ ជំពូកនេះ ភរិយា៣ ជំពូកខាងលើ មិនល្អឡើយ លោកឲ្យយើងវៀរចាកចោលចេញកុំប្រព្រឹត្តឲ្យសោះ និងឲ្យរើសយកភរិយាណាមួយក្នុងចំណោម ៤ ខាងក្រោម ដែលសុទ្ធតែជាភរិយាដ៏ល្អវិសេស ។

ចំណែកឯបុរសវិញ ក៏មានបុរសខ្វះប្រចណ្ឌប្រពន្ធដូចជាស្ត្រីដែរ ដូច្នេះគួរបុរសស្វាមី និងអ្នកកំឡោះជាអនាគតស្វាមីទាំងឡាយ កុំត្រាប់តាមបុរសធុននេះឡើយ ។ ម្យ៉ាងទៀតបុរសជាស្វាមី ដែលមានភេទ និងកំលាំងកាយខ្ពង់ខ្ពស់ខ្លាំងពូកែពីធម្មជាតិមកនោះ ត្រូវកាន់កិរិយាមាយាទឲ្យសមឋានៈខ្លួនជាស្វាមីរបស់គេ កុំអាងកំលាំងបាយវាយប្រក ខ្ពស់ទល់មេឃ និងកុំឲ្យទាបពេកស្មើរ ដី ដកបដល់កិរិយា រកគោរពប្រតិបត្តិ បំពេញឋានៈជាស្រីលផងមិនកើត ។

www.elibraryofcambodia.org

មានបុរសខ្លះបន្ទាបខ្លួនឲ្យទាបថោកហួសដល់ទៅ ធ្វើកញ្ជះបាទជើងកិរិយាខ្លួន បណ្ដាលឲ្យកិរិយាឡើងមានះ មើលងាយដូចសត្វតិរច្ឆាន ។

ឯចំណុចសំខាន់របស់ស្វាមី ដែលត្រូវប្រព្រឹត្តកាន់ឲ្យបានជានិច្ចនោះ គឺសេចក្ដីសន្ដោសចំពោះកិរិយា និងត្រូវស្គាល់សេចក្ដីទុក្ខរបស់កិរិយា ក្នុងឋានៈនាងជាស្រី និងជាភេទទន់ខ្សោយ ដែលមានអ្វីៗខុសពីបុរសភេទដូច្នេះ ៖

១- កិរិយាមានសេចក្ដីទុក្ខ ព្រោះការព្រាត់ប្រាស់ពីបងប្អូន ម្ដាយឪពុក ស្រុកកំណើតមកនៅនិងស្វាមី ទីកន្លែងថ្មី មនុស្សចម្លែកថ្មី ដែលធ្វើឲ្យគ្នាមិនស្រណុកចិត្ត ឬខាចៗធ្វើនេះមិនសម ធ្វើនោះមិនសម ព្រោះប្លែកកន្លែង ។ ស្វាមីត្រូវជើងនូវវិបត្តិផ្លូវចិត្តនេះ និងព្យាយាមសម្រួលការណ៍ឲ្យកិរិយាបានស្រួលផង ។

២- ស្រីតែងមានសេចក្ដីទុក្ខខាងផ្លូវកាយ និងផ្លូវចិត្តនៅពេលចុងខែ ដែលនាងមានឈាមរដូវ ។ ក្នុងរដូវកាលនេះ និងធ្វើឲ្យឈឺចុកចាប់ដល់ពោះ ឬឈឺក្បាល ឬទៅជាខ្យល់ចាប់ បើជួនជាមានឈាមរដូវដើរមិនទៀងផង ឬមាន

www.elibraryofcambodia.org

ធ្លាក់សផងនោះ ក៏និងកើតតែជាបញ្ហាឡើង ។ ម្យ៉ាងទៀត ក្នុងវេលាលនេះ អារម្មណ៍របស់ស្រីក៏មានភាពមិននឹងន ងាយខឹង មិនសប្បាយចិត្តជាដើម ។ ស្វាមីត្រូវយល់ពីបញ្ហានេះ ជួយរួមចំណែកក្នុងការឈឺចាប់ផងដែរ និងមិនធ្វើអ្វីដែលជាការលំបាកដល់នាង ឬបើមិនស្រួលក៏ប្រញាប់ប្រញាល់រកថ្នាំសង្កូវមកព្យាបាលភ្លាម ។

៣- កិរិយាតែងមានសេចក្តីទុក្ខ ពេលដែលនាងមានគភ៌ ការមានគភ៌ ជាការមួយដែលនាងជាកិរិយាទ្រាំទាំងអៀនខ្មាស ទាំងត្រូវទ្រាំថែមទៀតនូវទម្ងន់ ដែលកូនក្នុងផ្ទៃបន្ថែមជារៀងរាល់ថ្ងៃ ។ នាងមិនអាចឈរបានស្រួល ដើរបានស្រួល ឬប្រកបកិច្ចការបានស្រួល ដូចកាលដែលមិនទាន់មានកូនក្នុងផ្ទៃនោះទេ ។ ទាំងចំណីអាហារក៏ដូចគ្នាដែរ មានស្រីខ្លះរហូតដល់ចាញ់កូន ឬទឹកចង់ចំណីផ្តេសផ្តាស ដែលរកមិនបានក៏មាន ។ ក្នុងសម័យពុទ្ធកាល មហេសីព្រះបាទពិម្ពិសារ ពេលដែលព្រះនាងទ្រង់គភ៌ កូនក្នុងព្រះឧទរបានបណ្តាលឲ្យព្រះនាង ចង់តែសោយព្រះលោហិតរបស់ព្រះស្វាមី រហូតទាល់តែសមសាំង ព្រោះ

www.elibraryofcambodia.org

ពុំហ៊ានប្រាប់ ។ លុះក្រោយមក ព្រះបាទពិម្ពិសារលោក ចេះតែជម្រិតសួរ ព្រះនាងទ្រាំមិនបានក៏ទូលប្រាប់ទៅ ។ ព្រះបាទពិម្ពិសារ លោកយកព្រះខ័នមកអារព្រះហស្ត សម្រក់ព្រះលោហិតឲ្យមហេសីសោយទៅ ។ គ្រាន់តែសោយហើយ ព្រះនាងក៏ឈប់ឃ្លាន ហើយក៏ជាសះស្បើយចាប់តាំងពីថ្ងៃនោះទៅ ។ ពេលមានគភ៌ពិបាកណាស់ ដូច្នេះស្វាមីត្រូវយល់ទុក្ខធុរៈភរិយាឲ្យមែនទែន ។

៤-ភរិយាតែងមានសេចក្តីទុក្ខ ព្រោះត្រូវបម្រើខាងភេទរបស់ស្វាមី ។ ចំណុចត្រង់នេះ សំខាន់ណាស់ចំពោះអ្នកជាស្វាមី ដែលត្រូវតែយល់ទុក្ខធុរៈរបស់ភរិយាខ្លួន និងអារម្មណ៍របស់ភរិយាខ្លួនដែរ មិនមែនចេះតែត្រូវការពេលណា ផ្ទើរណា ក៏ចេះតែប្រព្រឹត្តសេពផ្ទើរនោះ អាងតែគ្នាមិនហ៊ានប្រកែកនោះទេ ។ ពេលមានរដូវ ពេលមានគភ៌ពេលប្រសូត្របុត្រ សុទ្ធតែជារយៈពេលដែលស្រីគ្នាមានបញ្ហាទាំងផ្លូវកាយ និងចិត្ត ដូច្នេះស្វាមីគួរចេះតម ឬវៀរលើកលែងខ្លះ ។

www.elibraryofcambodia.org

៥-ករិយាតែងមានសេចក្ដីទុក្ខ ពេលដែលនាងឆ្លងទន្លេ ប្រសូត្របុត្រ ។ ការឆ្លងទន្លេមានគ្រោះថ្នាក់ធំណាស់ ដូចជាយើងឆ្លងទូកអញ្ចឹងដែរ ស្វាមីគប្បីនៅថែទាំ និងជួយផ្ដល់ជាកម្លាំងចិត្តដល់នាងនូវគ្រប់កិច្ចការទាំងពួង ជាពិសេសបើនាងមានការមិនសប្បាយចិត្ត ឬធ្វើការធ្ងន់អាចនិងឲ្យទៅជាទាស់ស្ដូមរីងរៃដោចទឹកដោះ ឬដល់នូវការបាត់បង់ជីវិតក៏មានដែរ ស្វាមីគប្បីសាកសួរចាស់ៗ ឲ្យបានដឹងក្នុងរឿងនេះផងចុះ មិនអាចពណ៌នាជូនឲ្យអស់នូវសេចក្ដីពិតរបស់ស្រីបានឡើយ ។

ម្យ៉ាងយើងជាស្វាមី ត្រូវប្រៀបធៀបខ្លួននិងករិយាខ្លួន ហើយលៃឲ្យមានតុល្យភាពជានិច្ច កុំអាងតែខ្លួនប្រុសមានកំលាំង ចេះតែប្រព្រឹត្តរម៉ុងរមាំងតាមតែអំពើចិត្តរំលោភចំពោះករិយានោះឡើយ ។ បើករិយាជាស្រីខាតលក្ខណ៍ពាលាកាចសាហាវ មាតាបិតាប្រដៅមិនបាន ហាមប្រាមមិនឈ្នះ យើងត្រូវអប់រំតាមដោយពាក្យចាស់លោកពោលទុកមកថា “ឈ្នះអ្នកខ្សោយ ដោយឲ្យសម្ភបាយ” ពាក្យថា សម្ភបាយនេះ គឺឲ្យទូទៅគ្រប់យ៉ាង តាំងពីឲ្យ

www.elibraryofcambodia.org

សម្ភារបោយ សម្លៀកបំពាក់ មាសប្រាក់ រហូតដល់កិត្តិយស និងសេចក្ដីសរសើរជាដើម លៃលកសម្រួលតាមចរិតមនុស្ស ។ ធម្មតាអ្នកទន់ខ្សោយ ដូចជាស្ត្រីដែលខ្សោយកេទជាដើម តែងតែចាញ់នូវអំណាចអំណោយ គឺការឲ្យនូវរបស់ផ្សេងៗនេះឯង ។ ប៉ុន្តែមានករិយាខ្លះ ដែលអាក្រក់ហួសហេតុ ដរាបដល់ផិតក្បត់ប្ដីជាដើមនោះ សូម្បីឲ្យទតរសោយរាជ្យ ក៏មិនស្កប់ស្កល់ចិត្តដែរ ត្រូវតែលែងចោលឲ្យស្រឡះប្រសើរជាងទុកនៅ ។

អ្នកកំលោះនិងនាងក្រមុំទាំងឡាយ ជាអនាគតស្វាមីករិយា ចូរប្រុងប្រយ័ត្នកាយវាចាចិត្ត ក្នុងពេលដែលទើបនិងបានជួបគ្នាជាស្វាមីករិយាថ្មោងថ្មី កុំគប្បីបញ្ចេញអាការឡេះឡោះប្រឡូកប្រឡែងគ្នា ដូចសាហាយស្មន់នោះឡើយ នាំឲ្យមានការមើលងាយគ្នាទៅវិញទៅមក ខូចកិត្តិយសស្វាមីករិយា ដែលជាគូប្រចាំជីវិតរបស់ខ្លួនទៅថ្ងៃអនាគត ត្រូវកាន់ចរិយាមារយាទឲ្យសមហ៊ានៈរៀងៗខ្លួន ល្មមគោរពស្ដាប់បង្គាប់កោតខ្លាច ស្រលាញ់រាប់អានគ្នាបានអស់មួយជីវិត ។

www.elibraryofcambodia.org

ដូច្នេះបុរសស្វាមី ត្រូវស្គាល់ភរិយារបស់ខ្លួនឲ្យបានច្បាស់ ថាការរួមរស់នៅជាមួយគ្នា មិនមែនជាការស្រួលទេ បើគេពុំបានស្គាល់គ្នា ឲ្យបានច្បាស់លាស់ ។ ស្វាមីស្គាល់ភរិយា ភរិយាស្គាល់ស្វាមី ជាពាក្យដែលមានន័យថា ស្វាមីភរិយាខ្លួនមិនមែនជាអ្នកដទៃ មិនមែនជាមនុស្សប្លែកមុខ ឬសត្រូវទេ ។ ការស្គាល់នេះសោតទៀតមិនមែនស្គាល់គ្នាដូចស្គាល់គោក្របីនោះទេ គឺស្គាល់ចរិត ស្គាល់កិរិយាមាយាទ ស្គាល់ការចូលចិត្ត ស្គាល់សុខ ស្គាល់ទុក្ខរបស់អ្នកម្ខាងទៀត ។ មួយ៉ាងទៀត បើយើងស្គាល់ហើយចំណាំបានថា ស្វាមីភរិយារបស់យើង ធ្លាប់មានការប្រព្រឹត្តយ៉ាងនេះៗ លុះដល់យើងឃើញខុសពីប្រក្រតី ក៏និងអាចឲ្យយើងពិចារណា ឬតាមមើលថា មានអ្វីកើតឡើងចំពោះស្វាមីភរិយាខ្លួន ហើយអាចនិងការពារបានចំពោះអន្តរាយណាមួយ ដែលនិងកើតឡើងចំពោះដៃគូខ្លួនជាមិនខាន ឬបើមានរឿងកើតឡើងនោះ ក៏និងមិនធ្ងន់ធ្ងរពេក ។

មាតាបិតា ដែលអាចនិងចិញ្ចឹមកូនទាំងឡាយបានក៏ព្រោះតែអ្នកទាំងពីរនោះ មានចិត្តប្រកបដោយការវនា៤

www.elibraryofcambodia.org

យ៉ាងគឺ មេត្តា ករុណា មុទិតា ឧបេក្ខា ប្រព្រឹត្តចំពោះទៅត្រង់កូនប្រុសស្រីទាំងឡាយជានិច្ច ឥតមានអាក់ មិនដែលលះបង់គំនិតទាំង៤ប្រការនេះ ចេញឲ្យឆ្ងាយអំពីកូនខ្លួនឡើយ ប្រៀបឧបមាដូចជាមហាព្រហ្មទាំងឡាយ ដែលរក្សាឈានរបស់ខ្លួនទុកមិនឲ្យវិនាសទៅដែរ ជម្មតាមហាព្រហ្មទាំងឡាយ ដែលនឹងរក្សាឈានទុកបាននោះ ក៏ព្រោះមហាព្រហ្មទាំងនោះ មានចិត្តប្រកបដោយព្រហ្មវិហារធម៌៤ប្រការគឺ មេត្តា ករុណា មុទិតា និងឧបេក្ខា មហាព្រហ្មទាំងឡាយរក្សានូវព្រហ្មវិហារធម៌ទាំង៤យ៉ាង នេះឯងទើបរក្សាឈាននោះទុកបាន ។

ចំណែកមាតាបិតា លោកមានធម៌៤នេះចំពោះកូនដែរ ទើបព្រះសម្មាសម្ពុទ្ធជាម្ចាស់លោកឲ្យបញ្ញត្តិនាមថាមាតាបិតាជាមហាព្រហ្ម ដែលមានធម៌ មេត្តា ករុណា មុទិតា ឧបេក្ខា គ្របដណ្តប់ទៅលើកូនគ្រប់គ្នា ។ មាតាបិតាលោកមានមេត្តាធម៌កើតឡើងដល់កូន តាំងពីថ្ងៃខែដែលមាតាដឹងប្រាកដក្នុងខ្លួនថា ខ្លួនអញមានសត្វគឺ កូនមកអាស្រ័យនៅក្នុងផ្ទៃហើយៗ អ្នកទាំងពីរ តែងមានគំនិតគិត

www.elibraryofcambodia.org

ថា កាលណា វេលាណា យើងនឹងបានឃើញនូវកូនតូច របស់យើងជាកូនមានរោគ ឬឥតរោគ ។

គំនិតនេះឯង ទើបបានឈ្មោះថា មេត្តាចិត្ត ឬមេត្តាព្រហ្មវិហារ កើតឡើងដល់មាតាក្នុងកាលនោះឯង ។ មេត្តាចិត្តនេះ បានសេចក្តីថា មាតាបិតា មានចិត្តដ៏ល្អទៅកាន់កូន ឬថាមានចិត្តរាប់អានស្រឡាញ់កូន។

ម្យ៉ាងទៀត មាតាបិតាលោកមានករុណាចិត្ត កើតឡើងចំពោះកូននោះ តាំងតែពីពេលដែលកូននោះ បានសម្រាលចេញចាកផុតអំពីទ្វារមាសនៃមាតាមកក្រៅ ហើយ ៗ ស្រែកយំយ៉ាងខ្លាំង ដោយសេចក្តីទុក្ខព្រួយឯណាមួយដែលមកប៉ះពាល់ត្រូវកាយ ។ លុះអ្នកទាំងពីរ បានឮសំលេងយំនោះហើយ អ្នកក៏មានចិត្តអាណិតអាសូរករុណាយ៉ាងខ្លាំងទៅដល់កូននោះ ។ ករុណាចិត្តនេះបានសេចក្តីថា មាតាបិតា មានចិត្តប្រកបដោយសេចក្តីអាណិតអាសូរទៅកាន់កូន។

បន្ទាប់មកមាតាបិតា លោកក៏បានមានធម៌មួយមកទៀតដែល មានឈ្មោះថាមុទិតាកើតឡើងចំពោះកូន ក្នុង

www.elibraryofcambodia.org

វេលាដែលកូននោះចេះដើរ ចេះលេង និងក្នុងកាលដែលកូននោះបានចម្រើនដោយគុណដ៏ល្អ ទើបមាតាបិតា មានសេចក្ដីរីករាយស្រស់ស្រាយទៅដល់កូននោះ ក៏បានឈ្មោះថាមុទិតាចិត្ត ។ មុទិតានេះ បានសេចក្ដីថា មានចិត្តប្រកបដោយសេចក្ដីរីករាយទៅកាន់កូន ។

មិនតែប៉ុណ្ណោះសោត លោកនូវមានធម៌មួយទៀតបានកើតឡើងដល់កូននោះគឺ ឧបេក្ខា ក្នុងកាលដែលកូននោះបានចំរើនឡើង មានផ្ទះសម្បែង មានប្ដីប្រពន្ធ ចេះរកស៊ីធ្វើការចិញ្ចឹមជីវិត តាមទំនើងខ្លួនឯងបាន ។ មាតាបិតាមានចិត្តជាកណ្ដាល មិនសូវព្រួយពេក ព្រោះកូនអាចរក្សាខ្លួនឯងបានហើយ ។ ឧបេក្ខា បានសេចក្ដីថា មាតាបិតាមានចិត្តតាំងនៅក្នុងអារម្មណ៍ជាកណ្ដាលទៅរកកូន ឯមាតាបិតាទាំងពីរនេះ តែងតាំងនៅក្នុងធម៌៤ប្រការនេះ មិនដែលដាច់ជាធម្មតា ។

មាតាបិតា កាលណាបើបានចាត់ចែងរៀបចំផ្សំផ្គុំបុត្រធីតា ឲ្យមានគូស្វាមីភរិយាស្របតាមប្រពៃណីនិយមបានរស់នៅយ៉ាងសុខសាន្តនិងគ្នាហើយ លោកសប្បាយ

www.elibraryofcambodia.org

ចិត្តណាស់ ហាក់ដូចជាបានបំពេញករណីយកិច្ច ចំពោះជីវិតរបស់លោកអស់ហើយ តែលោកនៅមិនព្រមលះបង់ចោលបុត្រធីតាត្រឹមនេះទេ លោកនៅតែគិតគូរ បន់ស្រន់ឲ្យកូនបានសុខចំរើនតរៀងទៅ ។ លោកបានចែកកេរ្តិ៍មត៌កឲ្យ ហើយខ្លួនលោកនៅតែរ៉ាប់រងបម្រើ ទំនុកបំរុងកូនឥតធុញទ្រាន់ ដរាបដល់បានចៅរឹតតែស្រលាញ់ថ្នាក់ថ្នមបំរើចៅមួយភាគធំថែមទៀត ។ បើលោកបានរស់នៅដរាបដល់មានចៅទួតចៅលួតទៀតនោះ រឹតតែស្រលាញ់ថ្នាក់ថ្នម បំរើថែមច្រើនភាគទៅទៀត ។ នេះហើយជាទំហំហឫទ័យនៃមាតាបិតា ដែលពោរពេញទៅដោយព្រហ្មវិហារធម៌ ចំពោះបុត្រធីតាយ៉ាងទូលំទូលាយ ឥតមានព្រំដែន ។ គួរពួកបុត្រធីតាទាំងឡាយ តស៊ូប្តូរផ្តាច់គ្រប់យ៉ាងចំពោះលោកឲ្យលើសលុបជាងជីវិតខ្លួនទៅទៀត ទើបជួនល្មមព្រោះថា ៖

តាំងពីចាប់បដិសន្ធិមក មាតាបិតាបានប្រគល់ខ្លួនលោកធ្វើជា ទាសកម្មកររបស់កូនដោយរែកពាយអស់មួយជីវិត ឥតគិតថៃឈ្នួល ខំបម្រើយ៉ាងថ្នាក់ថ្នម លើសលប់

www.elibraryofcambodia.org

ជាងទាសកម្មករទាំងអស់ក្នុងលោក ។ បម្រើគ្មានឈប់សម្រាក គ្មានស្គាល់ថ្ងៃសៅរ៍ អាទិត្យ គ្មានគិតយប់ថ្ងៃ គ្មានច្បាប់ឈប់ថ្ងៃបុណ្យទាន គ្មានកំណត់ថ្ងៃខែឆ្នាំរ៉ៃត្រែត ។ បម្រើហើយបម្រើទៀត បម្រើតាំងពីកូនដល់ចៅ បម្រើដល់ចាស់សក់ស្កូវ ខ្នងកោង ជ្រុះធ្មេញអស់ បម្រើដល់ស្វិតសាច់ ស្រកឈាម ស្បែកយុរយារ បម្រើទាល់តែដល់ថ្ងៃស្លាប់ ។ ទោះបីស្លាប់ទៅកើតជាខ្មោចហើយ នៅតែកូនទៅអុចទៀនធូបសំបូងសង្រ្វង អន្ទងកោះហៅមកប្រើឲ្យជួយរកសេចក្ដីសុខចម្រើនឲ្យទៀត ។ នេះបានចំជាមានសំណាងមែន កូនប្រុសស្រីទាំងឡាយ ដែលបានកើតមកក្នុងគ្រួសារ ជាមួយនិងមាតាបិតានេះ ។

ការដឹងគុណមាតាបិតា ការតបស្នងសងគុណមាតាបិតា គឺជាការស្រឡាញ់លោក ការខិតលំទោនគោរពប្រតិបត្តិលោក ថ្នមពាក្យថ្នមសម្ដីចំពោះលោក ត្រងត្រាប់តាមឱវាទគ្រប់យ៉ាង មិនចចេស មិនរឹងរូស មិនធុញទ្រាន់រីករាយក្នុងការថែរក្សាសុខភាពលោក ជូនម្ហូបអាហារ ទឹកក្ដៅទឹកត្រជាក់ ជូនទំចំណី ផ្ដត់ផ្ដងសំលៀកបំពាក់ ប្រាក់

www.elibraryofcambodia.org

កាស ទំនុកបំរុងថ្នាំបង្ការរោគ និងថ្នាំព្យាបាលរោគ គក់ប្រាប់ជូនលោក មិនមានការនឿយណាយ ជួយជម្រុញ ឬញុំាងចិត្តលោកឲ្យបានជ្រះថ្លាទៅក្នុង សទ្ធា សីល ចាគៈ និងបញ្ញា ។ ចំពោះម្ហូបអាហារ នំចំណី ដែលគិតថាធ្វើជាចង្ហាន់យកទៅប្រគេនព្រះសង្ឃនៅឯវត្ត បុត្រធីតាគួរគប្បីរៀបចំចាត់ចែងទុកដាក់ដោយឡែក សម្រាប់ជូន មាតាបិតាពិសារជាមុនសិន សឹមយកមួយចំណែកទៀតទៅឯវត្ត ជាក្រោយ ទើបសមជាកូនកតញ្ញូ ។

បុត្រធីតាទាំងឡាយសូមអ្នកជ្រាបថា ជនណាដែលជាកតញ្ញូកតវេទីបុគ្គល ឬជនណាដែលគោរពតបស្នងសងគុណមាតាបិតា ជននោះរមែងបានទទួលកុសលផលានិសង្សគឺ : មានអាយុវែង មានមនុស្ស និងទេវតាកោតសរសើរ ទេវតានឹងជួយថែរក្សាឲ្យបានសេចក្តីសុខក្សេមក្សាន្ត រមែងបានស្ថិតនៅក្នុងអរិយធម៌គឺ សីល៥ រមែងបានគេចផុតអំពីឧបសគ្គចង្រៃផ្សេងៗ ទាំងនៅក្នុងបច្ចុប្បន្ននិងទៅបរលោក រមែងបានសម្រេចពុទ្ធញាណ បានសម្រេចបច្ចេកពោធិញាណ បានសម្រេចសាវកពោធិញាណ

www.elibraryofcambodia.org

ជាងទាសកម្មករទាំងអស់ក្នុងលោក ។ បម្រើគ្មានឈប់សម្រាក គ្មានស្គាល់ថ្ងៃសៅរ៍ អាទិត្យ គ្មានគិតយប់ថ្ងៃ គ្មានច្បាប់ឈប់ថ្ងៃបុណ្យទាន គ្មានកំណត់ថ្ងៃខែឆ្នាំវ៉ែត្រ ។ បម្រើហើយបម្រើទៀត បម្រើតាំងពីកូនដល់ចៅ បម្រើដល់ចាស់សក់ស្កូវ ខ្នងកោង ជ្រុះធ្មេញអស់ បម្រើដល់ស្វិតសាច់ ស្រកឈាម ស្បែកយុរយារ បម្រើទាល់តែដល់ថ្ងៃស្លាប់ ។ ទោះបីស្លាប់ទៅកើតជាខ្មោចហើយ នៅតែកូនទៅអុចទៀនធូបសំបូងសង្រែង អន្ទងកោះហៅមកប្រើឲ្យជួយរកសេចក្ដីសុខចម្រើនឲ្យទៀត ។ នេះបានចំជាមានសំណាងមែន កូនប្រុសស្រីទាំងឡាយ ដែលបានកើតមកក្នុងគ្រួសារ ជាមួយនិងមាតាបិតានេះ ។

ការដឹងគុណមាតាបិតា ការតបស្នងសងគុណមាតាបិតា គឺជាការស្រឡាញ់លោក ការឱនលំទោនគោរពប្រតិបត្តិលោក ថ្នមពាក្យថ្នមសម្ដីចំពោះលោក ត្រងត្រាប់តាមឱវាទគ្រប់យ៉ាង មិនចចេស មិនរឹងរូស មិនធុញទ្រាន់រករាយក្នុងការថែរក្សាសុខភាពលោក ជូនម្ហូបអាហារ ទឹកក្ដៅទឹកត្រជាក់ ជូនទំចំណី ផ្ដត់ផ្គងសំលៀកបំពាក់ ប្រាក់

www.elibraryofcambodia.org

កាស ទំនុកបំរុងថ្នាំបង្ការរោគ និងថ្នាំព្យាបាលរោគ គក់ប្រាប់ជូនលោក មិនមានការនឿយណាយ ជួយជម្រុញ ឬញាំុងចិត្តលោកឲ្យបានជ្រះថ្លាទៅក្នុង សទ្ធា សីល ចាគៈ និងបញ្ញា ។ ចំពោះម្ហូបអាហារ នំចំណី ដែលគិតថាឆ្ងាញ់ជាបង្អែមយកទៅប្រគេនព្រះសង្ឃនៅឯវត្ត បុត្រធីតាគួរគប្បីរៀបចំចាត់ចែងទុកដាក់ដោយឡែក សម្រាប់ជូន មាតាបិតាពិសារជាមុនសិន សឹមយកមួយចំណែកទៀតទៅឯវត្ត ជាក្រោយ ទើបសមជាកូនកតញ្ញូ ។

បុត្រធីតាទាំងឡាយសូមអ្នកជ្រាបថា ជនណាដែលជាកតញ្ញូកតវេទីបុគ្គល ឬជនណាដែលគោរពតបស្នងសងគុណមាតាបិតា ជននោះរមែងបានទទួលកុសលផលានិសង្សគឺ ៖ មានអាយុវែង មានមនុស្ស និងទេវតាកោតសរសើរ ទេវតានឹងជួយថែរក្សាឲ្យបានសេចក្ដីសុខក្សេមក្សាន្ត រមែងបានស្ថិតនៅក្នុងអរិយធម៌គឺ សីល៥ រមែងបានគេចផុតអំពីឧបសគ្គតូចធំផ្សេងៗ ទាំងនៅក្នុងបច្ចុប្បន្ននិងទៅបរលោក រមែងបានសម្រេចពុទ្ធញាណ បានសម្រេចបច្ចេកពោធិញ្ញាណ បានសម្រេចសាវកពោធិញ្ញាណ

www.elibraryofcambodia.org

ក្រោយពេលស្លាប់ទៅ រមែងបានទទួលសេចក្ដីរីករាយ ជាកយោភាពក្នុងបរលោក ព្រមទាំងបានចូលកាន់ព្រះនិញ្វនសមគួរតាមវាសនាបារមីដែលបានកសាង ពុំសាបសូន្យឡើយ ។

លើសពីនេះទៅទៀត នៅពេលដែលកតញ្ញូកតវេទីបុគ្គល មានកូនមានចៅ កូនចៅទាំងនោះ ក៏យកតម្រាប់តាមឪពុកម្ដាយរបស់គេ គ្មានខ្វះគ្មានចន្លោះអ្វីឡើយ ព្រោះគេធ្លាប់បានយល់ គេធ្លាប់បានដឹង គេធ្លាប់បានឃើញផ្ទាល់នឹងភ្នែក នូវសកម្មភាពតបស្នងសងគុណរបស់ឪពុកម្ដាយគេ ចាប់តាំងពីពេលដែលគេដឹងក្ដីមក ។ កូនទាំងនោះ ក៏ក្លាយទៅជាកតញ្ញូកតវេទីបុគ្គល ដូចឪពុកម្ដាយគេមិនលំបាកទូន្មានប្រៀនប្រដៅ ដូចជាអ្នកសបូស្សបញ្ចោសចុងឡើយ ។ កូនទាំងនោះ មានចិត្តត្រជាក់ មានចិត្តបុណ្យមានចិត្តកុសល ហើយព្យាយាមគោរពប្រតិបត្តិឪពុកម្ដាយគេមិនឲ្យមានល្ហៀង រីឯឪពុកម្ដាយគេហាក់បីដូចជាបានសោយសម្បត្តិទិព្វនាឋានសួគ៌លោកិយនេះឯង ។

ចំពោះកូនអកតញ្ញូវិញ តែងតែយល់ឃើញថា " បើ

www.elibraryofcambodia.org

កុំតែឪពុកម្ដាយរួមរ័កស្នេហាគ្នា ធ្វើម្ដេចកូនទិនកើតមកបាន កូនកើតមកហើយ ឪពុកម្ដាយមានករណីយកិច្ចត្រូវចិញ្ចឹម ពីព្រោះកូនមានករណីយកិច្ច ត្រូវចិញ្ចឹមកូនរបស់វាតៗ គ្នា ជាលំដាប់លំដោយទៀត ចំពោះការប្រព្រឹត្តបញ្ច្រាស ឲ្យកូនចិញ្ចឹមឪពុកម្ដាយវិញ វាជាការប្រឆាំងនឹងធម្មជាតិ ។ ដូច្នេះឪពុកម្ដាយ មិនគួរទាមទាឧបការគុណអ្វីអំពីកូនប្រុសស្រីឡើយ " ។ ពាក្យសម្ដីដ៏អប្បលក្ខណ៍អប្រិយទាំងអស់នេះ ពិតជាពាក្យសម្ដីដែលធ្លាប់ភ្លាត់ចេញពីប្រអប់មាត់កូនអកតញ្ញូពិតប្រាកដមែន ។

កូនអកតញ្ញូ ទោះបីជាខ្លួនមានទ្រព្យសម្បត្តិច្រើនយ៉ាងណាក៏ដោយ ក៏តែងតែចង្អៀតចង្អល់ចិត្ត ហើយចេះតែទឹកស្ដាយជានិច្ច ក្នុងការផ្ដត់ផ្ដង់បាយទឹក នំចំណីត្រីសាច់ សំលៀកបំពាក់ ថ្នាំសង្កូវ និងលុយកាក់ប្រាក់ដល់មាតាបិតា ។ ក៏ប៉ុន្តែនៅរដូវចូលឆ្នាំ ឬបិណ្ឌភ្ជុំ គេបែរជាខំសម្រិតសម្រាំងម្ហូបអាហារពិសេសៗ សុទ្ធតែសាច់មាន់ សាច់ទាសាច់គោ កាន់យួរជ្រែកដៃយកទៅវត្ត លុះសល់ពីវត្តទើបហៅឪពុកម្ដាយឲ្យបរិភោគ ដល់ឪពុកម្ដាយសាប់ទៅ ក៏

www.elibraryofcambodia.org

តាំងនាំគ្នាសែនព្រេន ដោយម្ហូបអាហារពោរពាស ដុតធូប បួងសួងខ្មោយៗ ឲ្យព្រលឹងម៉ែឪ មកសេពសោយ ។

កូនអកតញ្ញូខ្លះ ប្រើពាក្យសម្ដីទ្រគោះបោះបោក គម្រោះគម្រើយ ដាក់ឪពុកម្ដាយគ្មានកោតក្រែងបន្ដិចណាសោះ ហ៊ានជេរប្រមាថឪពុកម្ដាយ រហូតដល់ហ៊ានប្រមាថអាយុជីវិតគាត់ថែមទៀត ។ កូនអប្បលក្ខណ៍អប្រិយខ្លះ លួចជម្រិតប្រាក់កាសទ្រព្យសម្បត្តិឪពុកម្ដាយ យកទៅចាយវាយខ្ជះខ្ជាយជាមួយស្រីញី ឬប្រុសឈ្មោល ឬយកទៅលេងល្បែងស៊ីសងអស់គ្មានសល់ រួចហើយបណ្ដេញឪពុកម្ដាយឲ្យចុះចេញពីផ្ទះ ត្រូវសោតអណ្ដែតទៅរស់នៅតាមសំយាបផ្ទះគេ ត្រដាបត្រដួសដរាបដល់ថ្ងៃស្លាប់ ។ កូនអប្រិយខ្លះទៀត មិនគ្រាន់តែធ្វើបាបឪពុកម្ដាយឯងឲ្យចម្បែងគ្រាំគ្រាចិត្តប៉ុណ្ណោះទេ ថែមទាំងទៅបង្កទុក្ខលំបាកដល់អ្នកដទៃ មានលួចឆក់ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ យកកេរ្តិ៍ឈ្មោះឪពុកម្ដាយ ទៅជាន់ឈ្លីធ្វើឲ្យអាប់ឱន ធ្វើឲ្យលោកទទួលនូវភាពអាម៉ាស រហូតលែងហ៊ានអើតមុខចេញក្រៅផ្ទះ ។កូនអកតញ្ញូខ្លះ រកស៊ីធ្លាប់មានបានស៊ីចាយ

www.elibraryofcambodia.org

សប្បាយហ៊ឹហាតែគ្រួសារខ្លួនឯងផ្ទាល់ មិនព្រមយកម្តាយឪពុកទៅនៅជាមួយទេ ខ្លាចក្រែងធុញ ស៊ីយ ដាក់ខ្លួន ថែមទាំងមិនព្រមផ្គត់ផ្គង់ចិញ្ចឹមគាត់ទៀត បណ្តោយឲ្យលោកវេទនាអនាថាជាមួយអ្នកដទៃ ដល់ពេលលោកស្លាប់ទៅទើបបោះសំបុត្រអញ្ជើញភ្ញៀវមកចូលបុណ្យកុះករ ដើម្បីជៀសវាងពាក្យគេនិន្ទាផង លុះដល់ពេលមានទុក្ខមានអាសន្ន ក៏តាំងលើកដៃសំពះបួងសួង ស្រែកហៅខ្ញីយៗរកខ្មោចម៉ែឪឲ្យជួយ ។

ម៉ែឪដែលមានកូនរបៀបនេះ ពិតជាអកព្វមែន ពផ្ទៃកូនអប្រិយ៩ខែ ១០ខែ ធូន់ពោះឥតប្រយោជន៍ ដូចពដុំភ្លើងនាំឲ្យក្តៅរោលរាលម្ទោម្ទេញគ្រប់ដង្ហើមចេញចូល ។ ពពោះកូនទរកអកុសល ដូចពដុំលាមក ដុំគម្រង់ ដែលធ្វើឲ្យតែកេរ្តិ៍ឈ្មោះឪពុកម្តាយស្អុយអសោចតែប៉ុណ្ណោះ ។ ចិញ្ចឹមកូនអកតញ្ញូទាំងវេទនា ត្រជាបត្រដួស ឲ្យវាដុះស្លាបរឹងប៉ឹង វាហាក់បីដូចជាចិញ្ចឹមកូនខ្លា កូនក្រពើ ដែលវាលោតមកត្របាក់បំពង់ក សម្លាប់ម្តាយឪពុកឯងទៅវិញ ។

ជាលទ្ធផលកូនអកតញ្ញូ មិនត្រូវបានទទួលការ

www.elibraryofcambodia.org

ស្រលាញ់រាប់អាន ពីសំណាក់ឪពុកម្ដាយផង ពីសំណាក់ជនគ្រប់រូបផង ជាជនក្រញាតិមិត្តផង ជាជនអាប់កិត្តិយសផង និងអាប់ឱនសិរីសួស្ដីផង ។ ជនអកតញ្ញូ តែងបានទទួលក្ដីអកតញ្ញូអំពីកូនចៅរបស់ខ្លួនវិញ មិនលែងឡើយ ហើយថែមទាំងត្រូវទទួលរងនូវក្ដីទុក្ខលំបាកណាមួយ នាពេលបច្ចុប្បន្នជាតិនេះមិនសូវខាន ។ជនអកតញ្ញូ និងក្លាយទៅជាអ្នកបំផ្លាញលោក ពីព្រោះតែខ្លួនគេបានបង្កើតឡើងបានសាបព្រោះជាំពូជមនុស្សអាក្រក់ទុកក្នុងលោក ។ ពេលស្លាប់ទៅ កូនអកុសលរមែងធ្លាក់ទៅកាន់អបាយភូមិ គឺធ្លាក់ទៅកាន់ទីកន្លែងដែលពោរពេញទៅដោយទុក្ខ គ្មានសេចក្ដីសុខ ធ្លាក់ទៅអវចីនរក បាតាល តាមកម្រិតស្រាលឬធ្ងន់ ដែលគេបានកសាង ឬធ្លាក់ទៅអនន្តរិយកម្ម ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រោសមិនរួច ។

ហេតុដូច្នេះហើយ កូនប្រុសស្រីទាំងឡាយ មិនត្រូវបណ្ដែតបណ្ដោយឲ្យពេលវេលាកន្លងផុតទៅ ទើបនឹកស្ដាយក្រោយនោះទេ ។ ដូចបុរាណលោកពោលថា " ធ្វើបុណ្យឲ្យបានទាន់ខែភ្លឺ កុំចាំគាត់ឈឺស្លាប់មរណា ទើបនាំ

www.elibraryofcambodia.org

បងប្អូនមកវេរ ដល់គុណបុព្វការីគាត់ ។ ធ្វើបុណ្យដូច្នេះហៅខែងងឹត កាលនៅជីវិតមិនមានមាត់ ដល់ពេលស្លាប់ហើយទើបទឹកគាត់ យកធាតុដាក់វត្តឲ្យស្អាតបំធម៌ ។

ដូច្នេះ កូនត្រូវតែគោរពបូជាមាតាបិតាឲ្យបានច្រើន ដូចជាជូនភោជនាហារទាំងឡាយ មានបាយទឹកនំចំណីត្រីសាច់និងគ្រឿងឧបភោគបរិភោគ ព្រមទាំងគ្រឿងប្រើប្រាស់ មានសម្លៀកបំពាក់ជាដើម ឲ្យដល់មាតាបិតាតាមធនធានដែលខ្លួនមាន ។ បើសិនជានៅក្នុងរដូវត្រជាក់ កូនប្រុសស្រីត្រូវរកទឹកក្តៅជូនលោកងូត និងរកភួយសម្រាប់ជូនលោកដណ្តប់ ព្រោះមនុស្សចាស់ចាញ់រងាណាស់ ។ ចំណែកឯនៅក្នុងរដូវក្តៅវិញ កូនប្រុសស្រីទាំងឡាយ ត្រូវឲ្យទូរទឹកត្រជាក់សម្រាប់ងូតនិងផឹក ហើយត្រូវតម្កល់ទឹកសម្រាប់លាងដៃលាងជើង ឲ្យមាននៅជាប់ក្នុងពាងជានិច្ច ។ ត្រូវប្រកបកិច្ចការថែរក្សាទាំងឡាយ មានគក់ប្រដាប់ ចាប់សរសៃតាមជើងដៃជាដើម ជូនលោកអ្នកមានគុណទាំងនោះ ក្នុងកាលដែលលោកមិនមានសុខភាពល្អផង ។ ព្រោះធម្មតាមនុស្សចាស់ មិនសូវមានសុខភាពល្អមាំមួន ដូចយើងនៅ

www.elibraryofcambodia.org

ក្មេងនោះឡើយ ចេះតែប្រែប្រួល មួយថ្ងៃកាត់មួយថ្ងៃកោរ ។ អាស្រ័យហេតុនេះ កូនប្រុសស្រីទាំងឡាយ មិនត្រូវព្រងើយកន្តើយចំពោះមាតាបិតារបស់ខ្លួននោះទេ ។ ទោះបីជាមាតាបិតាស្ថិតនៅក្នុងសភាពជាអ្នកប្រម៉ឹក ឬជាអ្នកមិនមានសតិគ្រប់គ្រាន់យ៉ាងណាក៏ដោយ ។ ក្នុងឋានៈយើងជាកូន ត្រូវតែគោរពប្រតិបត្តិបម្រើទាំងយប់ទាំងថ្ងៃ ដូចកាលដែលលោកបានផ្ញើមកលើយើង ក្នុងកាលដែលយើងនៅតូចមិនទាន់ដឹងក្តីមកនោះ អញ្ចឹងទើបលោកហៅថា ជាកូនកតញ្ញូ ជាកូនប្រកបដោយធម៌ ជាកូនដែលមនុស្សម្នាមហាជនតែងគោរពរាប់អាន តែងកោតសរសើរ ។

www.elibraryofcambodia.org

# បណ្ដាំមាតា[១]

រឿងនេះខ្ញុំឯងតែងចងលើក   ជាកាព្យល្បិចល្បើកពាក្យនេះណា
សម្រិទ្ធសម្រាំងដោយបញ្ញា   ទុកជាទំនងតរឿងទៅ ។
ជាច្បាប់មាតាទុកទូន្មាន   កូនស្រីគ្រប់ប្រាណដែលល្ងង់ខ្លៅ
ពុំដឹងកិច្ចកល់ការរកក់ជ្រៅ   ប្រដៅឲ្យដឹងក្ដីគួរសម ។
តែងតាមពាក្យចាស់លោកលើកមក   គ្រាន់តែលៃលករកបទរ្យំ
គ្រប់ពាក្យប្រាំពីរតាមនិយម   បញ្ចូលពាក្យផ្សំតាមបរិយាយ ។
និងតែងចរចាថាហៃស្ងួន   ពន្លកខ្ញីមខ្លួនសំលាញ់ម្ដាយ
ចូរនាងស្ដែងស្ដាប់អភិប្រាយ   ចោមចាយកុំនាងគិតផ្ដេសផ្ដាស ។
ដ្បិតនាងនេះធំក្រមុំពិត   កំពុងចូលចិត្តកញ្ចូកក្រាស
ក្រមួនប្រេងម្សៅទូវចារ៉ុមាស   ចិញ្ចៀនកងពាសពាក់ជើងដៃ ។
ខ្លួននាងក្រមុំត្រូវគិតក្រែង   កុំស្រើបដោយល្បែងទោះយប់ថ្ងៃ
កុំដើរមើលល្ខោនកុនអាយ៉ៃ   ចង្រៃដល់ខ្លួនស្ងួនពុំងារ ។
កុំលោតអន្ទាក់លាក់កន្សែង   រត់ចាប់កូនខ្លែងបញ្ចូលទា
ឈរមើលយីកេបែរបៀតគ្នា   ពុំងារយ៉ាងនេះប្រុសមើលងាយ ។
កុំលេងបៀរប៉ាផូស៊ីសង   លេងនោះខុសច្បងណាស់ស្ងួនម្ដាយ
ជក់អាភៀនផឹកស្រាផងទាំងឡាយ   ខូចកាយកុំធ្វើអំពើថ្នោះ ។

---

១-ស្រង់ចេញពីកម្ពុជសុរិយា លេខ ០២ ឆ្នាំ ១៩៤៩ រៀបរៀងដោយ បទសិរីមេធិ ស្រី អ៊ូ ។

www.elibraryofcambodia.org

រីសោតឯល្បែងឯងស្រីញី កុំទៅរកវីក្បែរឲ្យសោះ
នាំឲ្យថោកថយអាប់កេរ្តិ៍ឈ្មោះ គឺមោះពុំត្រូវនិងច្បាប់ស្រី ។
ធម្មតាកំលោះនិងក្រមុំ កុំលេងលាយឡំនៅជោយជី
ពុំដែលត្រង់ទេមេកុំបី ជឿថ្វីចិត្តប្រុសនោះណានាង ។
ខ្លួននាងក្រមុំសមរាងរូប កាយក្លិនក្រអូបសព្វសព៌ាង្គ
ប្រុសព្រើលនិងទប់ឈប់ភាំសភាំង ឃើញនាងញញឹមញាក់រកគ្នា ។
ហើយចូលមកលេងនិងឯងឥត មានកោតក្រែងចិត្តក្រែងចិន្តា
លួកឡុកឡឹមឡុំសុំដល់ស្លា ហត្ថាអង្អែលឱបអង្គឯង ។
ព្រោះគេឃើញខ្លួនទន្ទួនពិសី ដើរលេងដោយជីឥតឯក្រែង
ទំនើងតែចិត្តចង់ប្រឡែង ចំបែងទីងអ្វីស្រើស្រើបស្រាល ។
ម្លោះហើយទីងកើតកេរ្តិ៍អាស្រូវ កាចខ្មាសគេកូវត្ថុដាលរាល
គេដឹងសព្វសុសប្រុសពេញពាល កុំស្គាលស្នេហ៍ស្និទ្ធជិតមេត្រី ។
នាងនៅខកសល់ដល់ស្ងៅកែ គ្មានប្រុសមួយស្នេហ៍ស្និទ្ធបេតី
លេងពាក្យពេចន៍ពុំគប្បី ឮល្បីជាក់ជាអ្នកលេងរេច ។
ហេតុនោះឯងមិញសំឡាញ់ម្តាយ កុំគិតសប្បាយហើយបំភ្លេច
អស់ច្បាប់ទម្លាប់សព្វសេចគ្រេច រេះគេចដើរលេងមិនឧស្សាហ៍ ។
ជាស្រីកុំលេងល្បែងទាំងអស់ ទីងខូចកេរ្តិ៍យសខុសលក្ខណា
ឧបទ្រពចង្រៃក្រៃមហិមា ទុក្ខាដល់ប្រាណមាន់ប្រាកដ ។
ខ្លួនកើតជាស្រីស្រែចម្ការ រៀនធ្វើការងារឲ្យមានបទ
រៀនត្បាញរវៃឲ្យហ្មត់ចត់ កុំគិតទៀយហត់ខំឲ្យម្ទួន ។

www.elibraryofcambodia.org

រៀនដេរខោអាវនូវខ្នើយខ្នល់   ពូកកែបកើយកល់ជាទ្រព្យខ្លួន
គ្រឿងប៉ាក់ស្រែះស្រាក់ជាក្បាច់ក្បួន   ជួសជុលចូរស្ងួនរៀនឲ្យគ្រប់ ។
ចងគោមគាត់កែប្រែឲ្យស្រេច   រំលើករំលេចឲ្យសុសសព្វ
ចងជាផ្កាព្កុលផ្កាយីហ៊ុប   ជរជាប់ជាយស៊ប់គួរយង់យល់ ។
ចងជាបុប្ផាផ្កាទទឹម   តម្រង់តម្រឹមឲ្យអស់កល់
ក្នក់ពេជ្ររំលេចដោយយោបល់   កុំឲ្យមានសល់សោះជាម្តង ។
រៀនចងជាហង្សពង់ពេទពើត   ជំទាញជំទើតទំផ្អៀងផ្អង
ហិចហោះផ្ទកផ្ទោះរកផលផង   ហើយចងជារូបសត្វបក្សី ។
ចងជាចាបពូកចាបជង្គូរ   ឬចាបស៊ីស្រូវណាកូនស្រី
ចងជារូបជៀបកប្បាសទ្ទី   ពិសីចងជាផ្កាក្រចាប់ ។
រឿងខានឯហូលរៀនឲ្យចេះ   ឲ្យស្ទាត់រឿងនេះរហ័សឆាប់
ចងរូបជ្រលក់គក់ប្រញាប់   ផ្គូផ្គាប់ត្បាញទៅពៅពុំងា ។
ឯព្រៃរៀនកែគិតលៃលើក   ជាតិជាល្បិចល្បើកតាមប្រាថ្នា
កុំឲ្យមានទាល់សល់ត្រង់ណា   ឧស្សាហ៍សន្សំខំកុំធ្វោយ ។
សង្វាតខ្មីឃ្មាតឲ្យមាំមួន   ធ្វើហើយថែធួនមើលមុខក្រោយ
ក្រែងក្តែប្រខាំទាំដាចដោយ   ប្រយ័ត្នកុំឲ្យពិបាកម្តាយ ។
ធ្វើការដៃទេទោះថ្ងៃយប់   សំងំស្ងៀមស៊ប់កុំនិយាយ
ពីនេះពីនោះសុសសព្វសាយ   ហើយសើចក្អាកក្អាយពៅពិសី ។
មួយទៀតខំធ្វៀតរៀនអក្សរ   រៀនធម៌រៀនអាថ៌រៀនសំដី
រៀនសព្វសេចគ្រចពាក្យពេចន៍ក្តី   លោកិយនេះទើបប្រឡូគេ ។

www.elibraryofcambodia.org

មួយខ្លួនក្រមុំកុំធ្វើការ　　អង្គុយមាត់ទ្វារណាមាសមេ
ទោះយប់ទោះថ្ងៃចង្រៃទ្វេ　　ពុំនោះសោតទេខាតលក្ខណា ។
កុំធ្វើឫកពាបែបឡេះឡោះ　　ប្រុលពាសពេញនោះហើយយាត្រា
បង់បោយគ្រវែងគ្រលែងស្មា　　ចរចាញញឹមធ្វើសំដី ។
ចំអន់ចំអកឡកនេះនុះ　　មិនទញ់មិនតុះធ្វើប្រិមប្រិយ
សំឡឹងសំឡក់ដូចឃើញអ្វី　　សំដីក៊យ៉ក៊ប់គ្មានទីងទួន ។
នាងធ្វើយ៉ាងនេះគេរិះគិត　　ទុកជាចោរចិត្តទៅហើយស្ងួន
គេនឹងប្រមាទជាបដល់ខ្លួន　　គេក្លួនវែងកើតអាស្រូវក្រៃ ។
កុំសើយកុំលាត់ពត់ទ្វពាតបា　　កុំចរយាត្រាចូលព្រៃផ្សៃ
ពាក់អាវគ្របខ្លួនកួនមាសថ្លៃ　　កុំធ្វើវិស័យស្រីអ្នកលេង ។
ធ្វើឫកសង្ហាឥតខ្មាសសោះ　　ស្លៀកពាក់ឃើញពោះអស់ក្ដីផេង
ឫកពាមារយាទដូចកូនក្មេង　　ពេលគេងលែងដោះអស់ចេញក្រៅ ។
ស្រីនោះពិតពុំប្រពៃទេ　　មាសមេកុំបៀតណាពាលពៅ
កុំតាមកុំត្រាប់រាប់ជាផៅ　　ពុំហៅត្រូវច្បាប់ទេណានាង ។
ក្នុងលោកសព្វថ្ងៃស្រីក្នុងក្រៅ　　បែរមៀងមើលទៅសព្វសព៌ាង្គ
ឥតលក្ខណ៍ក្នុងប្រាណមានតែរាង　　បើខាងធ្វើខ្លួនទុកងារចុះ ។
មួយថ្ងៃធ្វើខ្លួនបួនដប់ដង　　កាច់កកាច់ស្រង្កសើចហិះហុះ
ផាត់ម្សៅសិតសក់កញ្ចក់ឆ្លុះ　　រើរុះរើរើតសិតបន្ទែ ។
លាបប្រេងក្រមួនជួនថែមទៀត　　ផាត់ម្សៅរមៀតមើលឥតល្ហែ
កន្ទ្រាក់កញ្ចក់ស្ទុះសើរតែ　　រលំផ្ទះគ្រែផ្ទឹកសុក្រំ ។

www.elibraryofcambodia.org

មកចុះសព្វសុសដប់ដងគត់ ចាប់យកសំពត់ស្លៀកសក្តិសម
ពាក់អាវថ្នាន់ថ្មីដែលមានចំ បន្ទំចរចុះឲ្យប្រុសមើល ។
ឈានជើញាំញើញញាប់រន្ទូញ លលេញងើកងោកដើរងើល
រប៉ិលរប៉ូចដូចគេផ្អើល ធ្វើព្រើលជាក្អកឲ្យប្រុសដឹង ។
គ្រប់ហាមណោះណោះប្រុសមិនបែរ ធ្វើជាត្អូញត្អែរស្តីដូចខឹង
ឥតកេរ្តិ៍ឥតខ្មាសផ្តាសមិនដឹង តានតឹងស្ទើរតែទឹងដាច់ខ្យល់ ។
ខ្លួនទាន់ក្រមុំកុំធ្វើផ្តាស ក្បាក់ឡើងចំអាសអស់កិច្ចកល់
កេរ្តិ៍ខ្មាសក្នុងប្រាណមិនមានសល់ ហូសដល់លោកសង្ឃនៅឯវត្ត។
វីវឿងជ្រលូសជួសវាចា ចិត្តស្ម័គ្រចង់ជាថែមប្រាកដ
ពុំត្រង់ស្លូនស្លូតរបូតមាត់ ពិតជាបំក្បត់តាមសញ្ញា ។
ដូច្នោះចំពោះពិតប្រាកដ មិនជឿឲ្យស្បថចុះរាល់គ្នា
ជាក់ជាក្នុងចិត្តគិតចង់ថា នរណាមិនដឹងដំណើរនោះ ។
នេះឯងខាតលក្ខណ៍ជាក់ជាជន ជូរពេកពន់ពិតចំពោះ
ចង្រៃក្រៃពេកពុំគោះ ហេតុព្រោះដ្បិតខ្លួនមិនតាមច្បាប់ ។
ដេកយប់ទាស់ទ្វារបិទបង្អួច សឹកទាស់ទាល់រូចឲ្យសព្វគ្រប់
ថែទាំរៀបចំរបស់ទ្រព្យ រិះរាប់ឲ្យដឹងជាដើមចុង ។
មើលសព្វភ្លើងផ្សែងក្រែងព្យុះខ្យល់ បក់បោកមកដល់ក្លីប៉ប្លុង
វត្តកាត់ឧសប្រុះព្រោងក្នុង ជើងក្រានក្រែងផុងឆោឆេះផ្ទះ ។
បើស្ងួនបណ្តូលចូលទៅហើយ បោកពូកខ្នល់ខ្នើយមើលឲ្យជ្រះ
ថែឲ្យស្អាតស្អំសំទាន់ប្រេះ ដេកទៅរហ័សចាប់ភ្ញាក់ឡើង ។

www.elibraryofcambodia.org

លុបមុខខ្ពរមាត់មាសស៊ីស្វា  រួចហើយម្ទីម្នាកុំកន្ទ្រើង
ក្រោកឡើងទន្ទ្រំផ្ទះទឹងជើង  ចរចឹងចរចេញមកក្រៅហាន ។
រំសាយទាំងសក់អាក្រក់ក្រៃ  ពេញហៅចង្រៃពន់ប្រមាណ
ខាតអស់ទលេក្ខណ៍សក្តិយសប្រាណ  គល្យាណកុំធ្វើដូច្នោះណា។
កុំទាងលីលាទៅលេងឆ្ងាយ  កំបាំងពីម្ដាយទៅមិនថា
ស្រែកច្រៀងរំពងពុំទឹកនា  វែកងគេទិទ្ទាទៅផ្តេសផ្តាស ។
ប្រុសប្រាណបានឃើញដូច្នោះឯង  មិនលែងឡូកឡើយណាកូនមាស
ម្ដាយឃើញម្ដាយយល់តែអំពាស  កាច់ខ្ទាស់មេបាមកច្រើនហើយ ។
កុំនាំជាលដោយប្រុសល្ងង់លោម  រូមរសេរូបរចោមជាតិជាត្រើយ
តែចោតតាមវាពុំជាឡើយ  កូនអើយប្រយ័ត្នកុំឲ្យផ្ដោយ ។
បើឃើញកំឡោះដោះដៃចេញ  កុំទៅលលេញក្រែងក្រក្រោយ
កុំឃើញតែប្រុសចុះចង់ដោយ  ឡូកលយឡែបឡបប្រែបព្រមភ្លើង។
ប្រឡែងប្រឡូកលូកបីបម  ប្រឡោមថ្នាក់ថ្នមបោសព្រលឹង
មិនមានក្រែងចិត្តឥតកំជឹង  រំពឹងឲ្យជ្រៅទៅក្រោយមុខ ។
កែទ្រង់ប្រុងឡើងល្អចំណាប់  ធ្វើការគាន់កាប់ចុះបានសុខ
ធ្លាព្រៃពនជីធ្វើស្រែស្រុក  ទៀតទុកកេរ្តិ៍ក្រោយឲ្យកូនចៅ។
ប្រុសខូចមិនដូចឯងស្រីទេ  ហេតុនោះកុំមេជឿស្គង់ស្ទៅ
ធ្វើចោតលលោតដោយគេទៅ  ពាលពៅពុំត្រូវតាមពាក្យម្ដាយ ។
នាងខំប្រព្រឹត្តគិតប្រយ័ត្ន  កុំឲ្យភ្លេចភ្លាត់ពាក្យបរិយាយ
ចូរចាំឲ្យមាំណាកូនម្ដាយ  គិតគាយ [illegible] ចិត្ត ។

www.elibraryofcambodia.org

ធម្មតាយកគ្នាចិត្តនឹងចិត្ត ពុំដែលថេរបិតដល់អស់ផុត
ច្រើនតែលែងចោលទៅពត្រន់ ពិបាកចិត្តលន់លើសគេឯង ។
ហេតុព្រោះថ្ងស់ឆ្ងាយដោយពាក្យព្រាង បញ្ឆោតឲ្យនាងលុះការល្បែង
វាកុតមុសាថាមិនលែង ធ្វើក្លែងស្បថស្បែតែមាត់ក្រៅ ។
គឺមោះក្អេងពោះមិនមែនសោះ ធម្មតាកំឡោះមិនដែលខ្លៅ
ប្រាជ្ញាកុងកាប់ចាប់សំដៅ មិនដឹងស្អាប់ទៅចូលចិត្តជោគ ។
ទាល់តែផុតប្រាណបានដៃវា រួមសេរបាមិនអធ្យាក
មិនមានអាណិតគិតយល់យោគ ដល់កើតស្អាក់ស្អោកតាំងដាល់តប់ ។
វាប្រែក្រឡះលែងព្រងើយ ធ្វើជាតោះតើយពិតពុំរាប់
មិនមានលើកលែងប្រែជាស្អប់ ត្រឡប់ធ្វើជាមិនដឹងខ្លួន ។
ឯងនៅកំព្រាជាមេម៉ាយ សង្ស័យសហាយគេចវេះពួន
បង់កេរ្តិ៍ខូចឈ្មោះខុសក្រៅក្បួន មាសស្ងួនកើតកូនអត់ឪសអាំង ។
លំបិនលំបាកទ្រូងស្ទើរបែក សម្រក់ទឹកភ្នែកមុខក្រៀមក្តាំង
ព្រោះតែថ្ងស់ឆ្ងាយដោយមោហ៍បាំង ស្អោកតាំងគំនិតគិតទញ់តុះ ។
យ៉ាងនេះពុំគាប់ស្អាប់មិនខាន កុំធ្វើដូចបាននិយាយនុះ
ម្តេចៗខំទ្រាំអត់សិនចុះ កុំធ្វើឲ្យលុះខុសខូចប្រាណ ។
បើទោះបីជាល្អអាក្រក់ គឺរកគំរក់ក៏គង់មាន
ប្រុសឈ្លោលចូលស្តីមិនដែលខាន ប្រុងប្រាណកាន់កេរ្តិ៍តាមច្បាប់ស្រី ។
ហៃកូនសំឡាញ់ពេញចិត្តម៉ែ នាងនែបើនាងទៅមានប្តី
កុំទឹងក្រេវក្រោធឥតមេត្រី ចរស្រីស្រុសស្រួលទទួលទៅ ។

www.elibraryofcambodia.org

បើប្តីខេរខឹងសំឡឹងមុខ　　នាងខំអត់ទុកឲ្យស្ងៀមនៅ
កុំឆ្លើយតបតបោះបោកទៅ　　ស្រីពៅខាំមាត់សង្កត់ចិត្ត ។
កុំខឹងបោះបោកគំហកតប　　ឲ្យប្តីខ្លាចខ្លបមិនមានគិត
ខ្លួនឯងជាស្រីស្រោលគំនិត　　ពេកពិតពុំដឹងខុសត្រូវអ្វី ។
ស្ងួនម្តាយនាងផ្ដន់តម្រង់ចិត្ត　　ផ្ចត់ផ្ចង់គំនិតប្រតិបត្តិប្តី
នាងបៀកស្លាម្លូរបារី　　កុំបីធ្វើធ្វេសប្រហែសខ្លួន ។
យប់ព្រឹកបាយទឹករៀបបំរុង　　ប្រដាប់ប្រៀបប្រុងមើលថែជួន
រៀបរួចសិតទឹកមកមែនមួន　　ហើយស្ងួនលើកបាយជាបន្ទាប់ ។
បៀកស្លាបារីដាក់ជើងពាន　　ភ្លើងផ្សែងសោតមានគ្រប់ប្រដាប់
យកមកឲ្យសព្វគ្រប់ស្រេចស្រាប់ កុំឲ្យប្តីប្រាប់ញយៗផង ។
លើកបាយដល់មករកហៅប្តី　　សំណេះមេត្រីកុំបីធ្ងន់
អញ្ជើញពិសាណាអ្នកបង　　ស្ងួនគ្រង់រូសោភយទៅកាន់ប្តី ។
ប្តីមកដល់ប៉ោកអង្គុយប៉ុក　　នាងទៅពីមុខគាល់ស្វាមី
មើលបេះឆ្អឹងឆ្អែងក្រែងប្តីសី　　ទឹងអស់អ្វីៗត្រូវជួសដាក់ ។
ថែមទៀតជាថ្មីកុំបីខ្វល់　　ប្តីទាញម្ហិលថាសចេញជាក់
នាងហុចពានស្លាថាហែអ្នក　　វរលក្ខណ៍ធ្វើឈ្មោះណាពាលពៅ ។
ប្តីហូបរួចកល់សល់ប៉ុន្មាន　　សឹមកូនកល្យាណនាងលើកទៅ
រៀបរកស៊ីចុកចែកកូនចៅ　　ទើបហៅកោតខ្លាចស្វាមីភក្តិ ។
ថាបើប្តីប្រាណមានមេត្តា　　ឲ្យញុំាផងគ្នាស្ងួនវរលក្ខណ៍
ឲ្យប្តីហូបបានបីម៉ាត់ជាក់　　ស្រេចហើយទើបអ្នកនាងញុំាក្រោយ

www.elibraryofcambodia.org

អង្គុយបត់ជើងឲ្យត្រឹមត្រង់ រៀបអង្គឲ្យគួរកុំបីឆ្វោយ
មានស្បៃពាតបានាងកុំឲ្យ ខាតខុសតាមដោយច្បាប់តម្រា ។
ចំពូកមួយទៀតរើដំណេក បើនាងចូលដេកឲ្យឧស្សាហ៍
បោសពូកខ្នើយខ្នល់ហើយនិទ្រា ពុំងាកុំគេងត្រឹមទីងប្ដី ។
ត្រូវប្ដីចូលដេកមុនប្រពន្ធ ហើយសឹមស្រីតន់តូចពិសី
ចូលទៅនិទ្រាជាក្រោយខ្ចី ទើបត្រូវឥតបីមានខុសច្បាប់ ។
ដេកកុំឲ្យលក់លុះព្រឹកព្រាង ចង្រៃដល់នាងពិតពុំគាប់
ក្រោកឡើងមុនប្ដីស្រីប្រញាប់ ផ្គួផ្គាប់សិតទឹកទុកឲ្យប្ដី ។
រៀបស្លាម្លូថ្នាំប្រចាំនៅ ក្នុងហិបណាពៅកែវពិសី
ដល់ថ្ងៃរៀងរះពេញតិថី ហើយស្រីតណ្ដាំបាយទឹកទៅ ។
ប្រយ័ត្នក្រែងជូនជាប្ដីសី ចេញទៅកទដីឬវាយផ្ដៅ
កាប់ឧសឬស្សីអ្វីណាពៅ ការក្រៅដទៃក្ដីណាទូទ ។
កុំស្ដីដើមប្ដីត្អូរខ្អារ ដូចគេដេកផ្សារស្ដោះលើខ្លួន
ខូចជាយ៉ាងណារក្សាសួន បំពួនបំពាក់លាក់ទៅជា ។
បើប្ដីមានយសខ្ពស់បុណ្យសក្ដិ មានមនុស្សពឹងពាក់បុណ្យវាសនា
នាងកុំវាយដំបន្ទឹក នោះនឹងរួញភពុំលែងឡើយ ។
ថាបើមានខ្ញុំកំដរផង នាងយកចិត្តចងកុំតោះតើយ
កុំវាយកុំជេរវានោះឡើយ ពៅអើយនាងស្ដាប់ម្ដាយឧបមា ។
បើនាងមានចិត្តគិតយោគយល់ ដូចកល់ទឹកជ្រៅត្រជាក់ថ្លា
អស់ទាំងទាសាសតមថា ប្រាថ្នាពឹងពាក់សំណាក់នោះ ។

www.elibraryofcambodia.org

ថាបើទឹកក្តៅនៅពុំបាន ទីងគិតប្រែប្រាណចៀសចេញទៅ
នៅពុំបានសោះព្រោះទឹកក្តៅ គេហៅគង្គាអាប់ឥតបទ ។
រីទឹកឧបមាដូចកូនស្ងួន ពទ្ធកខ្ទីមខ្លួនកែវកំសត់
រីឯម្ដានោះប្រាកដ សន្ធត់ទុកដូចជាមនុស្សផង ។
ដែលខ្សត់ពិបាកយ៉ាកជន្ទជាក់ រត់មកពឹងពាក់លើទូនល្អង
បើនាងមេត្តាភ៌ជាម្តង ផ្គិផ្គងដូចជាទឹកត្រជាក់ ។
ថាបើនាងធ្វើកញ្ញូករោគ មិនមានអធ្យាគភ៌យប្រចំជាក់
យប់ព្រឹកស្ទឹកឥតមានអាក់ រលាក់រលើធ្វើពុំគិត ។
បើធ្វើដូច្នោះភ៌លែងនៅ រត់ចេញចោលទៅបង់គំនិត
អស់ពីអង្គាភ៌ពុំស្បិត ព្រោះជ្រិតនាងធ្វើក្រៃលែងច្បាប់ ។
នេះឯងដូចជាគង្គាក្តៅ ត្រីពីងពុំនៅភ័យក្រែងស្លាប់
ហេតុនោះកូនស្ងួនទូននាងស្តាប់ ម្តាយប្រាប់ប្រដៅដោយមាត្រា ។
កុំឃើញប្រុសល្អចរចោលប្តី ដើមនោះឥតបីបើទឹកនា
ស្រឡាញ់ថ្នាំងថ្មីផ្ទាប់មូស្ហា ចិត្តភ៌មិនគិតកេរ៍ខ្មាស់ខ្លួន ។
លុះដល់ខ្លួនប្រាណបានទៅភ៌ ល្អិកណាប្តីដឹងថាទឹមទូន
ប្រព្រឹត្តផិតក្តាសលាក់បំពួន ជាប់ជួនជិតដល់សហាយស្មន់ ។
ប្តីដឹងគេភ៌យប្រចំជាក់ផង គេចាប់គេចងធ្វើទោសទណ្ឌ
គេលក់គេលែងឯងអៀនអន់ ទទ្រទន់ទទ្រកអ្វីគ្មាន ។
ពិបាកដល់ក្ស័យនៃជីពជន្ម នៅរងទុក្ខធ្ងន់ឥតស្រាកស្រាន្ត
ស៊ីខ្ទះឈាមសាច់អាចម៍ខ្លួនប្រាណ ពុំបានបាយទឹកដល់តិចតួច ។

www.elibraryofcambodia.org

យមបាលអ្នកចាប់បានកាយា ឲ្យឡើងកោបន្ទាស្រួច
មុតអស់ខ្លួនប្រាណប្រែពុំរួច ស្រែកយំគ្រលួចព្នរំពេន ។
ត្មាតក្អែកប្រញើកចឹកស៊ីពាស សាច់ដាច់ជាប់ដាសចំពុះផង
ឈាមហូរសស្រាក់ធ្លាក់រាយរង ទុក្ខធ្ងន់កន្លងឈឺខ្លោចផ្សា ។
ទោះទាំងថ្ងៃយប់គ្រប់ពេលពិត ពុំមានស្បើយស្បិតដល់តិចណា
គ្មានទាំងសំពត់វណ្ឌអាត្មា កាយាទទេទំនេរនៅ ។
ស្លាប់កើតមួយថ្ងៃមួយរយដង ពិបាកកន្លងរងទុក្ខជ្រៅ
ទោះអស់បងប្អូនកូនញាតិផៅ ធ្វើបុណ្យជូនទៅពុំរដោះ ។
ព្រះពុទ្ធត្រាស់ថាអម្បាលខ្សាច់ ប្រោសប្រាណពុំដាច់ពុំរួចសោះ
ពីព្រោះស្រីចោរផិតប្តីនោះ រងគ្រោះកំណត់ប្រាំរយជាតិ ។
គ្រាន់តែរដោះពីទីជ្រៅ មករងទុក្ខនៅពិតពុំឃ្លាត
កើតជាប្រែតប្រាណព្រោះប្រមាទ ផិតប្តីជាអាទ៏ឲ្យវេទនា ។
ហេតុនោះឯងមិញសំឡាញ់ម្តាយ ខំផ្ចិតផ្ចង់កាយរាល់ទិវា
កុំឲ្យខូចកេរ្តិ៍ណាស្ងួនភ្ងា គ្រប់ពេលវេលាតទៅទៀត ។
ប្រយ័ត្នប្រាណប្រុងអង្គកាយកល់ គិតក្នុងយោបល់ឲ្យចង្អៀត
កុំឃើញតែងាយហើយឈ្លបឈ្លៀត សឹកសៀតណេះណោះណា
មាសមិត្រ ។
កាលដើមខ្លួនម្តាយនៅក្រមុំ ប្រុសផងចោមជុំម្តាយមិនស្និត
ឲ្យពាក្យសំដីស្តីមកស្និទ្ធ ម្តាយពុំលង់ចិត្តចោតដោយគេ ។
តែពួនរណាថាណេះណោះ ម្តាយចៀសចេញស្មោះមិនជ្រាលជ្រ

www.elibraryofcambodia.org

មិនជិតមិនស្និទ្ធស្នាលទៀតទេ នឹករេរ៉ែប្រប្រាណដើរចេញទៅ ។
ម្ដាយរក្សាប្រាណដល់មានប្ដី មិនមានមោះអ្វីទេណាពៅ
គ្មានប្រុសណាមួយមកធាតៅ ប្រាជ្ញខ្លៅសរសើរសើធគ្រប់មាត់ ។
ឥឡូវនេះម្ដាយចាស់ម៉្លេះហើយ ស្រីថ្លៃម្ដាយអើយចាំកុំភ្លាត់
ធ្វើតាមពាក្យម្ដាយឲ្យប្រាកដ តាមដោយបូរបទកុំឲ្យឃ្លាត ។
ទោះបីស្រីណាបើបានស្ដាប់ ធ្វើតាមបង្ដាប់នេះដាច់ខាត
ស្រីនោះនឹងបានស្ថានសួគ៌ស្អាត ប្រាសាទប្រសើរសើធសុវណ្ណា ។
ប្រកបស្រីស្នំក្រមការផង មាសប្រាក់កែវកងច្រើនត្រៀបត្រា
សឹងសុខឥតទុក្ខក្នុងអាត្មា ទាល់រួចដល់មហានិព្វានហោង ។

www.elibraryofcambodia.org

# សង្គហៈធម៌មាតាបិតា

អហឺរខ្ញុំ ក្រាបថ្វាយបង្គំ អង្គព្រះភគវា
សម្មាសម្ពុទ្ធ ឈ្នះផុតអស់មារ ទេព្តាសួគ៌ា
គោរពថ្វាយជ័យ ។

ព្រះអង្គបានត្រាស់ ជាព្រះពុទ្ធច្បាស់ ទ្រង់បានលកលៃ
ទេសនាប្រោសសត្វ ឲ្យរួចទុក្ខភ័យ បានលុះញាណញេយ្យ
និព្វានសួគ៌ា ។

ព្រះអង្គប្រទាន ឱវាទទូន្មាន ដល់ជនទនទា
សែប្រាំវស្សា ឥតមានរុញោភ បែងចែកវេលា
ជាប្រាំប្រការ ។

ពេលព្រឹកសង្ឃាត ទ្រង់យាងបិណ្ឌបាត្រ សត្វគ្រប់ទិសា
ទោះជាឆ្ងាយជិត ព្រះអង្គមិនថា ឲ្យតែសត្វណា
ជាប់មាននិស្ស័យ ។

រសៀលសូរិយា ព្រះអង្គទេសនា ធម៌អាថ៌ថ្លៃ
ប្រោសបរិស័ទ ជាអចិន្ត្រៃ ទ្រង់មិនសំចៃ
កំលាំងសោះឡើយ ។

លុះពេលព្រលប់ ទ្រង់មិនឈរឈប់ ព្រងើយកន្តើយ
ទ្រង់ឲ្យឱវាទ ពួកភិក្ខុហើយ យប់ស្ងាត់ចូងឆ្ងើយ
ប្រស្នាទេព្តា ។

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ ផាន់ រចនា
ខែ វិច្ឆិកា ឆ្នាំ២០១៦
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តរទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ចៅ យុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org